# ក្រឡេកមើល

## ការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា







cambodian center for independent media

ROSA LUXEMBURG STIFTUNG SOUTHEAST ASIA

# តារាងមាតិកា

## សេចក្តីសង្ខេប


១. ទិដ្ឋភាពទូទៅអំពីការអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជា ៣

២. តើការផ្តល់ដីសម្បទានសេដ្ឋកិច្ចបានផ្តល់ផលប្រយោជន៍ដល់ប្រជាជនកម្ពុជាដែរឬទេ? ៤

៣. ផលប៉ះពាល់ចំពោះប្រជាពលរដ្ឋពីគម្រោងអភិវឌ្ឍន៍ ៧


## របាយការណ៍ស៊ើបអង្កេត


១. ការផ្តល់ដីសម្បទានទ្រង់ទ្រាយធំកំពុងធ្វើឱ្យជនជាតិដើមភាគតិចកួយនៅខេត្តព្រះវិហារធ្លាក់ចូលក្នុងបំណុល ៩

២. ជនជាតិចិនគ្រប់គ្រងមុខរបរដែលខ្មែរធ្លាប់ធ្វើអាជីវកម្មនៅខេត្តព្រះសីហនុ ១៣

៣. អតីតសមាជិកព្រឹទ្ធសភាបក្សកាន់អំណាចជំរុញគម្រោងវិនិយោគតំបន់ឆ្នេរបំពានលើសហគមន៍នេសាទនៅកំពត ១៩

៤. ជនជាតិដើមភាគតិចព្នងនៅភូមិចក់ចារបាត់បង់ចំណូល ក្រោយក្រុមហ៊ុនវៀតណាមវិនិយោគទាំងភាពចម្រូងចម្រាស់ ២៦

៥. ជម្លោះកំពុងកើតមានជុំវិញសំណើបង្កើតព្រលានយន្តហោះអេកូទេសចរណ៍ ៣២

# សេចក្ដីសង្ខេប

# ១. ទិដ្ឋភាពទូទៅអំពីការអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជា

នៅកម្ពុជា មានការលើកឡើងតិចតួចណាស់ អំពីការអភិវឌ្ឍប្រកបដោយចីរភាពសង្គម។ ពាក្យតម្លាភាព និងគណនេយ្យភាពសង្គម មានតែនៅលើក្រដាស់មួយសន្លឹកប៉ុណ្ណោះ។ ដើម្បីច្បាស់រឿងនេះគេត្រូវក្រឡេកមើលឲ្យឆ្ងាយបន្តិចពីគោលនយោបាយជាតិ និងកម្មវិធីសហភិវឌ្ឍន៍ សហវត្សរបស់រដ្ឋាភិបាល។

ថ្វីត្បិតមកដល់ពេលនេះ រាជរដ្ឋាភិបាលនៅតែរក្សាបានពីកំណើនសេដ្ឋកិច្ចរបស់ខ្លួនក្នុងកម្រិត៧,៥ភាគរយក្នុងមួយឆ្នាំក្តីបើគេក្រឡេកមើលពីរបាយការណ៍ស្តីពីផែនការអភិវឌ្ឍន៍សម្រាប់កម្ពុជា ពីឆ្នាំ២០១៤-២០១៨របស់សហគមន៍អ៊ឺរ៉ុបបង្ហាញថាគ្រួសារភាគច្រើនបានងើបផុតពីភាពក្រីក្រក្នុងកម្រិតទាប។ ការរកចំណូលបានជាមធ្យមក្នុងមួយថ្ងៃ១,២០០.០០ រៀល (ប្រហែល $ 0.30 USD) នឹងនាំឲ្យពលរដ្ឋខ្មែរប្រហែល ៣លាននាក់ដែលក្បែរនឹងក្រ ធ្លាក់ចូលក្នុងភាពក្រីក្រវិញ ហើយនឹងធ្វើឲ្យអត្រានៃភាពក្រីក្ររបស់ប្រទេសកម្ពុជាកើនឡើងទ្វេរចាប់ពី ២០,៥ភាគរយទៅ ៤០ភាគរយ។ បើយើងពិនិត្យពីច្បាប់ដែលអនុម័តនៅអំឡុងខែកក្កដា ឆ្នាំ២០១៤ ស្តីពីផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិរបស់រដ្ឋាភិបាលបង្ហាញថា កម្រិតនៃអត្រាភាពក្រីក្ររបស់ប្រជាជនកម្ពុជា សរុបនៅទូទាំងប្រទេសបានធ្លាក់ចុះពី ១៣,៩ភាគរយកាលពីឆ្នាំ២០១៧ មកនៅត្រឹម ១២,៩ភាគរយក្នុងឆ្នាំ២០១៨។ ដោយឡែករបាយការណ៍របស់ធានាគាពិភពលោក World Bank(WB)ចេញផ្សាយនៅអំឡុងខែសីហា ឆ្នាំ២០១៧ដែលនិយាយអំពី «រក្សាកំណើននឹងនាំសម្រាប់អត្ថប្រយោជន៍ សម្រាប់ទាំងអស់គ្នា» បង្ហាញថា ប្រទេសកម្ពុជាមាន អត្រាក្នុងកំណើនគិតជាមធ្យម ៧,៦% ពីឆ្នាំ១៩៩៤ ដល់ឆ្នាំ២០១៥ ហើយបានក្លាយជាប្រទេសដែលមានចំណូលជាមធ្យមជាកម្រិតទាបនៅក្នុងឆ្នាំ២០១៥។ កំណើននេះត្រូវបានជំរុញដោយការនាំចេញទំនិញ និងសេវាកម្ម ដែលភាគច្រើនតាមរយៈសម្លៀកបំពាក់ និងទេសចរណ៍ ហើយបានកើនឡើង១៩,៦% ក្នុង១ឆ្នាំ ក្នុងរយៈពេលដូចគ្នា។

របាយការណ៍ដែលចេញផ្សាយដោយធនាគារពិភពលោក World Bank(WB)ដែរបង្ហាញថាផលទុនសរុបក្នុងស្រុក (ផ.ស.ស) នៃប្រទេសកម្ពុជាក្នុងឆ្នាំ២០១៨មានចំនួន ២៤.៤៤៤ពាន់លានដុល្លារអាមេរិក។ តួលេខនៃផលទុនសរុបនេះ បើប្រៀបធៀបនឹងឆ្នាំ២០១៧ មានចំនួន ២២.១៦ពាន់លានដុល្លារអាមេរិក។ ចំណូលប្រជាជនកម្ពុជាក្នុងម្នាក់សម្រាប់ឆ្នាំ២០១៨ មានចំនួន ១,៥១២.១២៧ដុល្លារអាមេរិក។ ចំនួននេះបើប្រៀបធៀបឆ្នាំ២០១៧ប្រជាជនកម្ពុជាអាចរកចំណូលបានក្នុងម្នាក់១,៣៨៥.២៦ ដុល្លារអាមេរិក។

របាយកាណ៍នេះបង្ហាញទៀតថា ផលទុនសរុបក្នុងស្រុក ឬ GDP នៃប្រទេសកម្ពុជាបើធៀបនឹងប្រទេសក្នុងតំបន់រួមមាន ប្រទេសឡាវ ប្រទេសថៃ ប្រទេសភូមា និងប្រទេសវៀតណាម គឺប្រាក់ចំណូលប្រជាពលរដ្ឋកម្ពុជាលើស បា នតែប្រទេសភូមាមួយប៉ុណ្ណោះក្នុងចំណោមប្រទេសទាំង៤នេះ។ ផលទុនសរុបក្នុងស្រុករបស់ប្រជាជននៃប្រទេសភូមា សម្រាប់ ឆ្នាំ២០១៨ក្នុងម្នាក់អាចរកចំណូលបាន ១,៣២៦.០០ ដុល្លារក្នុងមួយឆ្នាំ។

ងាកមកពាក្យថា « អភិវឌ្ឍន៍ ឬការវិនិយោគ » នៅក្នុងសម័យទំនើប នាពេលបច្ចុប្បន្ននេះ ហាក់មិនបានធ្វើឲ្យកំណើនសេដ្ឋកិច្ចគ្រួសាររបស់ប្រជាជន បានធូរធារដូចផែនការអភិវឌ្ឍន៍នេះទេ។ តាមរយៈគោលនយោបាយសម្បទានដីសេដ្ឋកិច្ច ដីរបស់ប្រជាពលរដ្ឋត្រូវបានក្រុមហ៊ុនដកហូតយកទៅប្រើប្រាស់ និងមិនបានផ្តល់សំណងសមរម្យដល់ពួកគេឡើយ។ផ្ទុយទៅវិញ អ្នកតស៊ូមតិរឿងដីធ្លីដោយអហឹង្សា ត្រូវបានចោទប្រកាន់តាមផ្លូវតុលាការ និងជាប់ពន្ធនាគារជាបន្តបន្ទាប់ទៅវិញជាដើម។

# ២. តើការផ្តល់ដីសម្បទានសេដ្ឋកិច្ចបានផ្តល់ផលប្រយោជន៍ដល់ប្រជាជនកម្ពុជាដែរឬទេ?

មានការសិក្សាជាច្រើនរបស់បណ្តាញអង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា រកឃើញថា ការអភិវឌ្ឍន៍តាមរយៈសម្បទានដីសេដ្ឋកិច្ច មិនបានផ្តល់ផលចំណេញដល់ប្រជាជនក្នុងតំបន់នៃការអភិវឌ្ឍន៍ប៉ុន្មានទេ។ មានតិចតួចប៉ុណ្ណោះដែលទទួលបានផលប្រយោជន៍ ពីការវិនិយោគ ដែលជារួមគេឃើញថាមានតែអាជ្ញាធរ និងភាគីដែលពាក់ព័ន្ធ ឬមនុស្សដែលស្និតនឹងអាជ្ញាធរដែលត្រូវបានគេរៀបចំអោយទទួលផល។ នៅអំឡុងឆ្នាំ២០០០ រដ្ឋាភិបាល ចាប់ផ្តើមផ្លាស់ប្តូរគោលការណ៍ពីការផ្តល់ដីក្នុងទំហំខ្នាតតូចមកមកជាទំហំខ្នាតធំរហូតលើសពីការកំណត់នៅក្នុងច្បាប់ភូមិបាលក៏មានដែរ។ របាយការណ៍ដែលចេញផ្សាយនៅលើគេហទំព័រនៃកាសែតភ្នំពេញប៉ុស្តិ៍បញ្ជាក់ថា រហូតមកដល់ពេលនេះសម្បទានដីសេដ្ឋកិច្ច ជិត១,២លានហិកតា ត្រូវបានរដ្ឋាភិបាលផ្តល់ឲ្យទៅក្រុមហ៊ុនចំនួន ១១៧ក្រុមហ៊ុន។ គម្រោងជាច្រើនត្រូវបានគេវិនិយោគទៅលើវិស័យកសិ-ឧស្សាហកម្ម ដែលដាំណាំភាគច្រើនផ្តោតទៅលើអំពៅ និងដើមអាកាស្យាព្រមទាំងដើមកៅស៊ូ។ ប៉ុន្តែ ភាគច្រើននៃដំណាំកសិ-ឧស្សាហកម្មទាំងនោះ ត្រូវបានក្រុមហ៊ុនមួយចំនួនដាំដំណាំផ្សេងជំនួសវិញ មានដំណាំចេក និងដំណាំស្រូវជាដើម។

ម្យ៉ាងវិញទៀត គេសង្កេតឃើញថា ក្រោយពីរដ្ឋាភិបាលចេញគោលការណ៍ជួលដីក្នុងរយៈពេលវែង៩៩ឆ្នាំ ហើយក្រោយមករយៈពេលនៃការជួលនេះ រដ្ឋាភិបាលតាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រេចចិត្តកាត់មកនូវត្រឹម ៥០ ឬ៧០ឆ្នាំ ហើយករណីនេះបានបង្កឲ្យមានវិវាទ ដែលផ្តើមចេញពីគោលនយោបាយសម្បទានដីសេដ្ឋកិច្ចជាហូរហែរ។

ងាកមកមើលរបាយការណ៍ ដែលផលិតដោយមញ្ឈមណ្ឌល់ម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅឆ្នាំ ២០១៩នេះ ដែលបានចុះសិក្សាស្រាវជ្រាវ និងប្រមូលព័ត៌មាន នៅតាមគោលដៅខុសៗគ្នាចំនួន៩ទីតាំងដែលពាក់ព័ន្ធនឹងគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចរបស់រដ្ឋាភិបាល និងគម្រោងវិនិយោគផ្សេងទៀត បង្ហាញថា ប្រជាជននៅក្នុងសហគមន៍មូលដ្ឋានស្មើរ១០០ភាគរយ ត្រូវរងគ្រោះពីការអភិវឌ្ឍន៍នេះ។

## គម្រោងអភិវឌ្ឍន៍ដីសម្បទានសេដ្ឋកិច្ច នៅខេត្តព្រះវិហារ

នៅក្នុងខេត្តព្រះវិហារយើង រកឃើញថាជនជាតិដើមភាគតិចកួយទាំង២៥ភូមិចំណុះឲ្យឃុំទាំង១០ ក្នុងស្រុក៣រួមមានស្រុកត្បែងមានជ័យ ស្រុកជ័យសែន និងស្រុកឆែបនៃខេត្តព្រះវិហារត្រូវបាត់បង់ដីព្រៃសហគមន៍ព្រៃកប់សព ព្រៃបម្រុងទុក និងព្រៃអាស្រ័យផលជាដើម។ ក្រុមហ៊ុន ហេងហ្វូ ទទួលបានសិទ្ធិវិនិយោគពីរដ្ឋាភិបាលនៅអំឡុងឆ្នាំ២០១១។ ក្រុមហ៊ុនរបស់ចិនដែលដាំអំពៅសម្រាប់ផលិតស្ករសរនាំទៅអឺរ៉ុប និងឥណ្ឌានេះមានបុត្រសម្ព័ន្ធរបស់ខ្លួនចំនួន៥ទៀតដូចជា ក្រុមហ៊ុនហេងរ៉ូយ រ៉ូយហ្វេង ឡានហ្វេង ហេងណុង និងហេងយូ ទទួលបានដីពីរដ្ឋាភិបាលក្នុងទំហំផ្ទៃដី៤ម៉ឺន២ពាន់៤២២ហិកតា។ ប្រជាជនប្រមាណ ២០០០គ្រួសារស្មើប្រមាណ១ម៉ឺននាក់ ក្លាយជាជនរងគ្រោះពីការវិនិយោគនេះ។

ការសិក្សារកឃើញថា ក្រុមហ៊ុនចិនដ៏ធំមួយនេះ មិនបានសិក្សាពីហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ មុននឹងត្រូវដាក់ផែនការវិនិយោគរបស់ខ្លួនទេ។ក្រុមហ៊ុន ហេងហ្វូនេះទើបតែសិក្សាពីហេតុប៉ះពាល់បរិស្ថាន និងសង្គមនៅអំឡុងឆ្នាំ២០១៦ប៉ុណ្ណោះមានន័យថា ៥ឆ្នាំបន្ទាប់ពីឈូសឆាយរួចទើបនៅអំឡុងឆ្នាំ២០១២ ក្រុមហ៊ុន ចាប់ផ្តើមចេញរបាយការណ៍ពីការសិក្សាហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ។

វីអូឌី បានចុះសិក្សានៅអំឡុងខែកក្កដាឆ្នាំ២០១៩ រកឃើញថា ការឈូសឆាយនេះ ក្រុមហ៊ុនមិនបានផ្តល់សំណងឲ្យប្រជាជនដែលត្រូវបានក្រុមហ៊ុនឈូសឆាយទេ។ ហើយប្រជាជនតិចតួចប៉ុ-

ណ្ណោះ ដែលទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍន៍នេះ ប៉ុន្តែតំណាងសហគមន៍ដែលបានផ្តល់សម្ភាសន៍បញ្ជាក់ថា ក្នុងចំណោមពួកគេទាំងនោះបានឈប់អស់វិញហើយ ដោយសារតម្លៃនៃកម្លាំងពលកម្មតិចតួច។

សព្វថ្ងៃនេះពលរដ្ឋនៅភូមិប្រើសក្អក និង អ្នកភូមិផ្សេងទៀតត្រូវបង្ខំចិត្តខ្ចីលុយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឯកជនដើម្បីបង្កើនមុខរបរផ្សេងសម្រាប់ ទ្រទ្រង់ជីវភាពក្រោយពេ លអនុផល ព្រៃ ឈើត្រូវបាត់បង់ជាពិសេស ដើមជ័រច្បោះ ដែល ជាប្រភពចំ ណូ លដ៏សំខាន់របស់សហគមន៍។

## ការវិនិយោគរបស់ជនជាតិចិន នៅខេត្តព្រះសីហនុ

ចំណែកគម្រោងវិនិយោគនៅខេត្តព្រះសីហនុវិញ ការចុះសិក្សារកឃើញថា ការផ្តល់សិទ្ធិផ្តាច់មុខពេញលេញឲ្យជនជាតិចិនអភិវឌ្ឍ បានជំរុញឲ្យពលរដ្ឋនៅក្នុងមូលដ្ឋានប្រឈមមុខនឹងការបាត់-បង់មុខរបរ។

ការចុះសិក្សារកមិនឃើញពីកាលបរិច្ឆេទពិតប្រាកដ នៃការផ្តល់សិទ្ធិវិនិយោគ របស់រដ្ឋាភិបាលកម្ពុជាឲ្យវិនិយោគិនចិនបានធ្វើឡើងតាំងពីពេលណាមកទេ។ ប៉ុន្តែតាមរយៈបទសម្ភាសន៍ ដែលវីអូឌី ឮ បានជួបដោយផ្ទាល់ជាមួយនិងប្រភពប្រមាណ៣០នាក់ នៅតាមវិស័យផ្សេងៗគ្នា នៅអំឡុងខែ សីហា ឆ្នាំ២០១៩ ឲ្យដឹងថា លំហូរជនជាតិចិនទាំងអ្នករកស៊ី និងទេសចរណ៍ បានកើនឡើងខ្លាំងនៅអំឡុងចុងឆ្នាំ២០១៧ និងដើមឆ្នាំ២០១៨។

តាមរយៈកំណើនវិនិយោគិនចិននេះ ប្រភពដែលបានផ្តល់សម្ភាសន៍ពីគោលដៅផ្សេងៗពីគ្នា បានប៉ាន់ប្រមាណថា យ៉ាងហោចណាស់មានពលរដ្ឋ ៦០ភាគរយកំពុងទទួលរងផលប៉ះពាល់អវិជ្ជមានពីការអភិវឌ្ឍនៅក្នុងខេត្តនេះ។ ពួកគេប៉ាន់ប្រមាណថា ពលរដ្ឋប្រ-ហែលជា៤០ភាគរយបានទទួលផលខ្ពស់ពីការអភិវឌ្ឍ។ លោក ជួន ណារិទ្ធ ស្នងខេត្តព្រះសីហនុ លើកឡើងថា អាជីវកម្មស្ទើរ៩០ភាគរយត្រូវគ្រប់គ្រងដោយជនជាតិចិន។ យោងតាមទិន្នន័យរបស់រដ្ឋបាលខេត្តព្រះសីហនុកាលពីថ្ងៃទី២៩ ខែ សីហា ឆ្នាំ២០១៩ មានក្រុមហ៊ុនចំនួន៥២ក្រុមហ៊ុន កំពុងតែវិនិយោគនៅក្នុងខេត្តនេះ។ របាយការណ៍ដដែលបញ្ជាក់ថា ប្រហែល៩០ភាគរយគឺជាក្រុមហ៊ុនមកពីប្រទេសចិន។

របាយការណ៍វិនិយោគចិនដែលវីអូឌីទទួលបានពីទីចាត់ការផែនការនៃរដ្ឋបាលខេត្តព្រះសីហនុ គិតត្រឹមខែមេសា ឆ្នាំ២០១៩ បង្ហាញថា ការវិនិយោគមានទឹកប្រាក់ជាង ៨ពាន់៤៦០លានដុល្លារអាមេរិក(៨.៤៦០.៤១៨.៣៦៤$)។ ទំហំទឹកប្រាក់ដែលគ្រប់ដណ្តប់គម្រោងទាំង៥២គម្រោងនេះ គឺក្តោបទៅលើវិស័យសំខាន់ៗក្នុងខេត្តព្រះសីហនុដូចជា វិស័យសេវាកម្មទេសចរណ៍ អចលនទ្រព្យ តំបន់សេដ្ឋកិច្ចពិសេស ហេដ្ឋារចនាសម្ព័ន្ធ និងវិស័យឧស្សាហកម្ម។

តាមរយៈកំណើនជនជាតិចិននេះ បានបង្ខំចិត្តឲ្យអ្នកស៊ី ឬធ្វើពាណិជ្ជកម្មនៅខេត្តព្រះសីហនុ ដែលជាពលរដ្ឋមូលដ្ឋាន ត្រូវចាកចេញទៅតំបន់ផ្សេងវិញ។ ការធ្វើចំណាកស្រុកនេះ ពួកគេលើកឡើងថា ដោយសារគ្មានលទ្ធភាពក្នុងការប្រកួតប្រជែងជាមួយ និងចិនបាន។ មូលហេតុសំខាន់ចិនមានលុយច្រើន អាចជួលផ្ទះ ឬអាគារក្នុងតម្លៃថ្លៃ។ ផ្ទះល្វែងដែលមានទំហំ៥គុណ២០ម៉ែត្រ ធ្លាប់ជួលក្នុងតម្លៃ៥ទៅ៦០០ដុល្លារអាមេរិក ក្នុង១ខែ តម្លៃនេះហក់ឡើងដល់ ១ម៉ឺនទៅ១ម៉ឺន៥ពាន់ដុល្លារអាមេរិកក្នុងមួយខែ។

ក្រៅពីតម្លៃផ្ទះជួលឡើងថ្លៃ ទន្ទឹមនឹងនេះតម្លៃទំនិញនៅលើទីផ្សារក៏ឡើងថ្លៃទ្វេរដងដែរ។ បញ្ហាកាន់តែស្មុគស្មាញរបស់អ្នកខេត្តព្រះសីហនុ គឺជនជាតិចិនមានសិទ្ធិប្រកបមុខរបរស្វ័យនិយោជ(សេដ្ឋ-កិច្ចក្រៅប្រព័ន្ធ) ដូចពលរដ្ឋខ្មែរដែរ។ ចិនអាចបើកហាងម៉ាស្សា ហាងលក់បាយ លក់គ្រឿងសំណង់ ខារ៉ាអូខេ ហាងដូរលុយ ហាងកាត់សក់ រត់តាក់ស៊ី ជាងជួសជុលឡាន លក់ត្រី សាច់ និងលក់បន្លែជាដើម។

នៅក្នុងរបាយការណ៍បូកសរុបការងារឆមាសទី១ ដើមឆ្នាំ២០១៩ លោកយន្ត មីន បញ្ជាក់ថា ដោយសារការរីកចំរើនយ៉ាងឆាប់រហ័សលើគ្រប់វិស័យនេះហើ យ ជំរុញឲ្យខេត្តព្រះសីហនុកាត់បន្ថយ

ភាពក្រីក្រធ្លាក់ចុះមក នូវត្រឹម១០,៧២ភាគរយក្នុងមួយឆ្នាំ។ លោក យន្ត មីន មានប្រសាសន៍ថាប្រជាពលរដ្ឋក្នុងខេត្តព្រះសីហនុ ទទួលបានចំណូលគិតជាមធ្យម៣ពាន់៣៥៨ដុល្លារអាមេរិកក្នុងមួយឆ្នាំ។

## គម្រោងអភិវឌ្ឍន៍ដីសម្បទានសេដ្ឋកិច្ច ខេត្តកំពត

គម្រោងវិនិយោគមួយទៀត នៅស្រុកទឹកឈូខេត្តកំពត។ តាមរយៈលិខិតអនុញ្ញាតរបស់រដ្ឋាភិបាល ចុះកាលបរិច្ឆេទកាលពីថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០១៥ បានបើកផ្លូវឲ្យក្រុមហ៊ុន ជីងគ័រ (Ching Kor Import Co.,Ltd) ដែលមាន អ្នកស្រី កែវ ម៉ាលីជាម្ចាស់ក្រុមហ៊ុន អភិវឌ្ឍដោយលប់សមុទ្រជិត ៧រយហិកតាក្នុងទិសដៅជួយឲ្យពលរដ្ឋនៅក្នុងសហគមន៍មានការងារធ្វើ និងអាចទទួលប្រាក់ចំណូលខ្ពស់ពីការអភិវឌ្ឍនេះដែរ។

យោងតាមសំណើររបស់ក្រុមហ៊ុនជីងគ័របានស្នើសុំគោលការណ៍វិនិយោគពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីបង្កើតតំបន់សមុទ្រនេះ ឲ្យប្រែក្លាយទៅជា « មហាសមុទ្រទេសចរណ៍កំពត» ដោយសាងសង់សណ្ឋាគារ និងស្ប៉ា វីឡាទំនើប ផ្ទះវិស្សមកាល អាគារស្នាក់នៅ និងភោជនីយដ្ឋានជាដើមក្រុមហ៊ុន ជីងគ័រ ដែលគ្រោងនឹងយកទៅអភិវឌ្ឍន៍នេះ គ្រប់ដណ្តប់តំបន់នេសាទរបស់ សហគមន៍ចំនួន ២គឺសហគមន៍នេសាទត្រពាំងរពៅ និង សហគមន៍ព្រែកត្នោត សហគមន៍ទាំងពីរនេះ ស្ថិតនៅក្នុងស្រុកទឹកឈូខេត្តកំពត។ សហគមន៍ត្រពាំងរពៅបង្កើតឡើងតាំងពីឆ្នាំ២០០២ ហើយត្រូវបានចុះបញ្ជីទទួលស្គាល់ពីរដ្ឋាភិបាលក្នុងឆ្នាំ២០០៩ ។ សហគមន៍នេះ មានផ្ទៃដីសមុទ្រសរុប ១ពាន់២៥១ហិកតា។

ដោយឡែក សហគមន៍ព្រែកត្នោតវិញបង្កើតឡើងតាំងពីឆ្នាំ ២០០២ ហើយចុះបញ្ជីទទួលស្គាល់ពីរដ្ឋាភិបាលក្នុងឆ្នាំ២០១១។ សហគមន៍នេះមានផ្ទៃសមុទ្រសរុប១១៦៨ហិកតា។ ប្រសិនបើផែនការវិនិយោគចាប់អនុវត្តដូចការគ្រោងទុក ប្រជាជននៅក្នុងសហគមន៍ទាំងពីរនេះជាង១ពាន់គ្រួសារ(១,៤៧០) នឹងត្រូវរងផលប៉ះពាល់ខ្លាំងផ្នែកជីវភាព។ កត្តាគំរាមកំហែងផ្នែកជីវភាពនេះ នៅមិនទាន់គិតដល់អ្នកនេសាទដោយប្រយោលរាប់ពាន់គ្រួសារផ្សេងទៀត ក្រៅពី-សហគមន៍មកពីកំពង់សោម និ ងផ្នែកខ្លះទៀតនៃខេត្តកំពតនៅឡើយផង។

## គម្រោងអភិវឌ្ឍន៍ដីសម្បទានសេដ្ឋកិច្ច ខេត្តមណ្ឌលគីរី

សម្រាប់គម្រោងវិនិយោគតាមរយៈសម្បទានដីសេដ្ឋកិច្ចមួយទៀត នៅក្នុងស្រុកកែវសីមា នៃខេត្តមណ្ឌលគិរីវិញ ក៏ជាផ្នែកមួយនៃការបង្ខំឲ្យជនជាតិដើមភាគតិច ក្នុងខេត្តមួយនេះត្រូវប្រឈមមុខទៅនឹងការបាត់បង់ដីធ្លី និងមុខរបរដែរ។ មុនពេលក្រុមក្រុមហ៊ុនវៀតណាមឈ្មោះ ប៊ិញភឿកមួយចូលមកវិនិយោគនៅអំឡុងខែតុលា ឆ្នាំ២០១១ ជនជាតិដើមភាគតិចព្នងអាចរកចំណូលបានពីអនុផលព្រៃឈើ គិតជាមធ្យម២លានរៀល ($៥០០ UDS) ក្នុង១ខែ។ ចំណូលនេះ នៅមិនទាន់គិតដល់អនុផលព្រៃឈើផ្សេងទៀត ដូចជា ដកផ្សិត រើសជ័រចុង និងផ្កាអ័រគីដេនៅឡើយផង។

យោងករណីសិក្សាបានបង្ហាញថា តំណាងសហគមន៍ជនជាតិដើមភាគតិចព្នងលោក ប្រប់ ជីប អាចរកចំណូលបានក្នុង១ខែៗ គិតជាមធ្យមចន្លោះពី ៤លានទៅ ៨លានរៀល (ខ្ពង់ $២០០០ UDS) ដែលទទួលបានពីអនុផលព្រៃឈើនេះ។ ប៉ុន្តែចំណូលនេះ ត្រូវធ្លាក់-ចុះ និងបាត់បង់ទាំងស្រុងវិញ ក្រោយពេលក្រុមហ៊ុនចូលទៅអភិវឌ្ឍដាំដំណាំកៅស៊ូ។ ដោយជំនួសមកវិញ សហគមន៍មួយចំនួន ត្រូវជាប់បំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលពួកគេលើកឡើងថា ពុំធ្លាប់មានទេពីមុនមករឿងបំណុលនេះ។ មេឃុំស្រែ លោក ឃិត ខិត អះអាងថា សព្វថ្ងៃនេះពិតជាមានអ្នកជាប់បំណុលមីក្រូហិរញ្ញវត្ថុមែន។ ប៉ុន្តែលោក ខិត លើកឡើងថាអ្នកជាប់បំណុលនេះមានប្រហែល២០ភាគ-រយប៉ុណ្ណោះ ក្នុងចំណោមប្រជាជនសរុបជាង៩០០គ្រួសារ។

នៅអំឡុងឆ្នាំ២០១៣ ក្រុមហ៊ុនចាប់ចូលឈូសឆាយដីព្រៃកប់សព ព្រៃបំរុងទុក ព្រៃសែនព្រេន ព្រៃជំនឿ ព្រៃអារក្ស និងដើមជ័រទឹកជាដើម របស់ពល រដ្ឋស្មើផ្ទៃដីជិត៩ពាន់ហិកតា(៨.៨៩០)ដើម្បីដាំដំណាំកៅស៊ូ។ នៅថ្ងៃទី៣១ ខែ មិថុនា ឆ្នាំ២០១៥ ក្រុមហ៊ុន ប៊ិញភឿក១នេះ បានផ្តើមឈូសឆាយបង្ហើយដីដែលនៅសល់ចុងក្រោយចំនួន ១៥00ហិកតាបន្ថែមទៀត។ កាលពីថ្ងៃទី២១ ខែ សីហា ឆ្នាំ ២០១៤ ដើម្បីបញ្ចប់ជម្លោះ ភាគីក្រុមហ៊ុន និងអាជ្ញាធរដោះស្រាយទំនាស់ដីធ្លីថ្នាក់ខេត្ត បានសម្រេចកាត់ដីចំនួន ៣៧៥ហិកតា ពីក្រុមហ៊ុនឱ្យសហគមន៍វិញ។ បើទោះជាបែបនេះក្តី ទាំងអង្គការមិនមែនរដ្ឋាភិបាល និងតំណាងសហគមន៍ដែលរងគ្រោះ បានប្រាប់ វីអូឌី ថា ដីដែលក្រុមហ៊ុនកាត់ចេញនេះ គឺមិនបានទៅប្រជាពលរដ្ឋរងគ្រោះពិតប្រាកដទេ។ បើតាមប្រភពដដែលអះអាងថា អ្នកដែលទទួលបានដីភាគច្រើនគឺអាជ្ញាធរមូលដ្ឋាន និងអ្នកចំណូលពីខាងក្រៅ ដែលក្រុមអាជ្ញាធរចាត់ចែង និងរៀបចំឱ្យប៉ុណ្ណោះ៕

## គម្រោងបង្កើតព្រលានយន្តហោះ អេកូទេសចរណ៍នៅខេត្តមណ្ឌលគីរី

នៅខេត្តមណ្ឌលគីរីនេះដូចគ្នាគម្រោងបង្កើតព្រលាណយន្តហោះអេកូទេសចរណ៍ ដែលគ្របដណ្តប់លើផ្ទៃដីចំនួន 300 ហិចតា ថ្វីត្បិតតែគម្រោនេះ នៅមិនទាន់មានព័ត៌មានច្បាស់លាស់អំពីវិសាលភាពផ្ទៃដី តែក៏កំពុងមានសកម្មភាពឈូឆាយដីបណ្តើរៗហើយ ហើយប្រជាពលរដ្ឋក៏កំពុងតែមានការព្រួយបារម្ភ ដោយការឈូសឆាយនេះវាកាន់តែខិតមកកៀកនឹងដីព្រៃកប់សពរបស់ជនជាតិព្នង លើសពីនេះទៅទៀត កម្មករដែលឈូសឆាយដីនោះបានគម្រាមប្រជាពលរដ្ឋថាពួកគេនឹងបង្ក្រាប ប្រសិនបើមានការតវ៉ាកើតឡើង។ ប្រជាពលរដ្ឋព្រួយបារម្ភផងដែរអំពីសុវត្ថិភាពដីធ្លីរបស់ពួកគាត់ ដោយសារតែពួកគាត់មានប្លង់ទន់ពេលដែលទិញពីម្ចាស់មុនៗ ហើយប្រជាពលរដ្ឋខ្លះបានយំស្រែកនៅពេលដែលមន្ត្រី ដែលមិនស្គាល់អត្តសញ្ញាណបាននិយាយក្នុងកិច្ចប្រជុំមួយជាមួយអ្នកភូមិថា ដីរបស់ពួកគាត់នឹងត្រូវប្រមូលទិញវិញដោយរដ្ឋក្នុងតម្លៃ ១000 ដុល្លារក្នុងមួយហិចតា។

## ៣. ផលប៉ះពាល់ចំពោះប្រជាពលរដ្ឋតាមរយៈគម្រោងអភិវឌ្ឍន៍

ផលប៉ះពាល់ពីគម្រោងអភិវឌ្ឍនៅក្នុងឯកសារនេះ គឺឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្តែងដែលវីអូឌីបានរកឃើញ។ ជាមូលដ្ឋាននិងភាពជាក់ស្តែងនៅតាមគោលដៅនីមួយៗ យើងរកឃើញថាការអភិវឌ្ឍនេះ បានជះឥទ្ធិពលអវិជ្ជមានច្រើនដល់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋច្រើនជាង៩0ភាគរយ ដែលស្ថិតនៅចំគោលដៅនៃការវិនិយោគ ក្លាយជាជនរងគ្រោះ មិនថាជនជាតិដើមភាគតិច ឬប្រជាជនខ្មែរទេ។

ប្រជាជនខ្មែរ ដែលមានទាំងជនជាតិដើមភាគតិចផង តែងអាស្រ័យផលពីព្រៃឈើ សមុទ្រ អូរ ស្ទឹង ទន្លេ ថ្លុកត្រពាំង បឹងបួរធម្មជាតិ ដើម្បីចិញ្ចឹមជីវិត និងដោះស្រាយការរស់នៅប្រចាំថ្ងៃ។ ក្រៅពីនេះ អនុផលព្រៃឈើតួយ៉ាង ដកជ័រទឹក រើសជ័រចុង បោចវល្លិ៍ បេះផ្លែឈើ នេសាទ បរបាញ់សត្វតាមប្រពៃណី មុខរបរទាំង នេះ អាចជួយឲ្យពួកគេរកចំណូលបានគិតជាមធ្យម២ លានរៀលក្នុង១ ខែដែរ។ ប្រជាពលរដ្ឋខ្មែរនៅខេត្តព្រះសីហនុ ដែលធ្លាប់ប្រកបមុខរបរខ្លួនឯងបានជួលអោយទៅជនជាតិចិន និងមុខរបរតូចតាចជាច្រើនទៀតក៏ត្រូវជនជាតិចិនបញ្ជៀតចូល រហូតធ្វើអោយប្រជាពលរដ្ឋខ្មែរដែលប្រកបមុខរបរតូចតាច បានកាត់បន្ថយប្រាក់ចំណូល និងប្រជាពលរដ្ឋមួយចំនួនបង្ខំចិត្តធ្វើចំណាកស្រុកទៀតផង។

នៅតំបន់អភិវឌ្ឍផ្សេងទៀត អាជ្ញាធរ និងក្រុមហ៊ុនដោះស្រាយសំណងពីការប៉ះពាល់ដល់ប្រជាពលដ្ឋ តែសំណងមិនសមរម្យ ហើយសំណងខ្លះក៏ត្រូវទទួលផលពីសាច់ញាតិ ឬអ្នកស្និតនឹងអាជ្ញាធរច្រើនជាងប្រជាពលរដ្ឋដែលរងផលប៉ះពាល់ជាក់ស្តែង ។

# របាយការណ៍ស៊ើបអង្កេត

# ១. ការផ្តល់ដីសម្បទានទ្រង់ទ្រាយធំកំពុងធ្វើឱ្យជនជាតិដើមភាគតិចកួយនៅខេត្តព្រះវិហារធ្លាក់ចូលក្នុងបំណុល



*ពលរដ្ឋសហគមន៍ប្រមេរុ នៅក្នុងខេត្តព្រះវិហារ ពិភាក្សាគ្នាពីក្តីបារម្ភបាត់បង់មុខរបរ ខណៈគ្រួសារខ្លះបានធ្លាក់ខ្លួនចូលទៅក្នុងបំណុលធនាគារ កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ (រូបភាព៖ ជន ចាន់រ៉េន)*

ស្រុកឆែប ខេត្តព្រះវិហារ៖ ជនជាតិដើមភាគតិចកួយរាប់ពាន់នាក់នៅក្នុងខេត្តព្រះវិហារ កំពុងតែបាត់បង់មុខរបររបស់ពួកគេ ហើយគ្រួសារខ្លះបានធ្លាក់ខ្លួនចូលទៅក្នុងបំណុល ខណៈពេលដែលមានក្រុមហ៊ុនដាំដើមអំពៅ ដែលមានជាប់ពាក់ព័ន្ធនឹងក្រុមហ៊ុនចិនបានឈូសឆាយដីប្រមាណជា ២ម៉ឺនហិកតា។ ការត្រួសត្រាយនេះបានធ្វើឱ្យប៉ះពាល់ដីព្រៃ និងដីចម្ការរបស់អ្នកភូមិនៅក្នុងតំបន់នោះ។

យោងតាមការជួបសម្ភាសន៍ជាមួយនឹងអ្នកភូមិនៅក្នុងតំបន់ចំនួន ២៥នាក់ និងការទទួលបានព័ត៌មានពីការសិក្សាស្រាវជ្រាវរបស់តំណាងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងតំបន់នោះអ្នកយកព័ត៌មាន VODរកឃើញថាក្រុមហ៊ុនចំនួន៥ជាប់ពាក់ព័ន្ធនឹងគ័ងដុងឆាយណា ហេងហ្វូ អ៊ីនធើណេស៊ិនណល ស៊ុគ័រ (Guangdong, China's Hengfu International Sugar) ប៉ុន្តែ ក្រុមហ៊ុននោះត្រូវបានដាក់ក្នុងបញ្ជីថា ហេងហ្វូ គ្រុប ស៊ុគ័រ អ៊ិនដាស្រ្ទី (Hengfu Group Sugar Industry)។

បើយោងតាមច្បាប់របស់កម្ពុជា ក្រុមហ៊ុននេះ បានទទួលដីសម្បទានដល់ទៅ ៤ដងនៃទំហំដីសម្បទានសេដ្ឋកិច្ចដែលត្រូវបានអនុញ្ញាតដោយរដ្ឋាភិបាលសម្រាប់ក្រុមហ៊ុនមួយ។ ក្រុមហ៊ុននេះបានធ្វើសកម្មភាពឈូសឆាយនៅមុនពេលដែលមានការសិក្សាស្រាវជ្រាវពីផលប៉ះពាល់បរិស្ថាននិងសង្គម។ ក្រុមហ៊ុនក៏មិនបានផ្តល់ព័ត៌មានដល់សហគមន៍ ឬផ្តល់សំណងចំពោះពលរដ្ឋដែលរងផលប៉ះពាល់ ហើយបានឈូសឆាយដីរហូតដល់មាត់ទឹក។ យើងបានទាក់ទងទៅក្រុមហ៊ុនដើម្បីទទួលបានការបំភ្លឺ។

ស្រ្តីម្នាក់ដែលជាតំណាងរបស់ក្រុមហ៊ុន បានបដិសេធផ្តល់ការអត្ថាធិប្បាយដល់អ្នកសារព័ត៌មាន។ នាងបានប្រាប់ថា ក្រុមហ៊ុនបានប្រឈមមុខនឹងបញ្ហានៅក្នុងការដោះស្រាយបញ្ហាដែលត្រូវបានលើកឡើង ប៉ុន្តែមិនបានចេញផ្សាយរបាយការណ៍ជាសាធារណៈ។

លោក អៀម អោន អាយុ ៦០ឆ្នាំ អ្នករស់នៅក្នុងសហគមន៍ភូមិប្រើសក្តុកឃុំម្លូរព្រៃ២ស្រុកឆែបបានប៉ាន់ប្រមាណថាមានអ្នកភូមិប្រហែលជា ៩០ភាគរយ បានធ្លាក់ខ្លួនជំពាក់បំណុល។ លោក អៀម អោន និយាយថា៖ «កាលពីក្រុមហ៊ុនមិនទាន់ចូល ពួកខ្ញុំអាចរកសត្វព្រៃតិចតួចអាចលក់ដូរខ្លះៗទិញប្រេង ដូចជាជ័រទឹក ជ័រចុង ឬក៏អ័រគីដេ ឬក៏យ៉ិនស៊ីន ឬក៏បាយដំណើបជាដើម យកមកលក់បាន»។ គាត់និយាយទៀតថា៖ «ឥឡូវនេះ រកអត់បានទេ មានតែខ្ចីធនាគារ។ កាលបើរាំងស្ងួត ធ្វើស្រែមិនបានទៀត ពេលនោះយើងអាចលក់ធនធានក្នុងផ្ទះ តែសម្រាប់អ្នកមាន បើអ្នកអត់មានលំបាកតិច»។

លោក ហេង ភួន មេឃុំម្លូរព្រៃ១ ដែលស្ថិតនៅជិតនោះដែរ បាននិយាយថា កាលពីឆ្នាំកន្លងទៅ ប្រជាពលរដ្ឋនៅក្នុងឃុំរបស់លោកទទួលរងនូវផលប៉ះពាល់ដោយការផ្លាស់ប្តូរដីដាំដុះដែលបានធ្វើឱ្យមានការកើនឡើងនូវបំណុល។

គាត់និយាយថា៖ «នៅមុនការវិនិយោគរបស់ក្រុមហ៊ុនចិនមកដល់ ប្រជាពលរដ្ឋមិនដែលជាប់បំណុលធនាគារ ដូចនៅពេលនេះទេ»។ នៅឆ្នាំ២០១១ រដ្ឋាភិបាលបានផ្តល់ដី សម្បទានសេដ្ឋកិច្ច

ដល់ក្រុមហ៊ុន ៥ មានក្រុមហ៊ុន ហេង ណុង ក្រុមហ៊ុន ហេង រ៉ូយ ក្រុមហ៊ុន ហេង យូ ក្រុមហ៊ុន ឡាន ហ្វេង និងក្រុមហ៊ុន រ៉ូយ ហ្វេង ដែលមានទំហំរវាង ៦៤៨៨ហិកតា ទៅ ៩១១៩ហិកតា សម្រាប់ក្រុមហ៊ុននីមួយៗ។

យោងតាមកំណត់ត្រារបស់អង្គការមិនមែនរដ្ឋាភិបាលក្រុមហ៊ុន ចំនួន៣ គឺមានក្រុមហ៊ុន ហេង ណុង ក្រុមហ៊ុន ហេង រ៉ូយ ក្រុមហ៊ុន ហេង យូ បានទទួលកិច្ចសន្យានៅថ្ងៃតែមួយ គឺនៅថ្ងៃទី៨ ខែវិច្ឆិកា។

ដោយរួមបញ្ចូលគ្នា ក្រុមហ៊ុនទាំង ៥នេះ ទទួលបាន ៤២៤២២ ហិកតា នៅក្នុងខេត្តព្រះវិហារ។ នេះបើយោងតាមកំណត់ត្រានៃអង្គការ ទិន្នន័យដើម្បីអភិវឌ្ឍកម្ពុជា និងរបាយការណ៍របស់អង្គការសិទ្ធិមនុស្សលីកាដូ។

ច្បាប់ភូមិបាលឆ្នាំ២០០១វិញ ចែងថា សម្បទានដីសេដ្ឋកិច្ចច្រើនបំផុតត្រឹម ១ម៉ឺនហិកតា។

លោក លីវ ហ្វេង (Liu Feng) ប្រធានក្រុមហ៊ុន ហេង ហ្វូ ប្រាប់សារព័ត៌មាន The China Daily នៅក្នុងឆ្នាំ២០១៦ថា ដោយមិនគិតក្រុមហ៊ុនទាំង ៥នោះទេ គឺក្រុមហ៊ុនរបស់លោកទទួលបានដីសម្បទានចំនួន ៤២៤២២ហិកតាសម្រាប់ការអភិវឌ្ឍនេះ។ គាត់និយាយបន្តថា ក្រុមហ៊ុនរំពឹងថា នឹងពង្រីកផ្ទៃដីទៅដល់ ១៨០០០០ ហិកតានៅពេលអនាគត។

យោងតាមការចេញផ្សាយដោយសារព័ត៌មានភ្នំពេញប៉ុស្តិ៍កាលពីឆ្នាំ២០១៤ ឱ្យដឹងថា ក្រុមហ៊ុនទាំង ៥នោះ មានអាសយដ្ឋាន និងលេខទំនាក់ទំនងដូចគ្នា។

អសយដ្ឋានដែលបានដាក់បង្ហាញនៅក្នុងបញ្ជីឈ្មោះក្រុមហ៊ុនតាមអនឡាញរបស់ក្រសួងពាណិជ្ជកម្ម ក៏បានកំណត់ដូចគ្នាដែរ ថាក្រុមហ៊ុន ហេង រ៉ូយ ក្រុមហ៊ុន ឡាន ហ្វេង និងក្រុមហ៊ុន រ៉ូយ ហ្វេង គឺស្ថិតនៅអាគារ Prince Tower ដែលជាអតីតអគារ Phnom Penh Tower ស្ថិតនៅតាមផ្លូវមុន្នីវង្ស ក្នុងរាជធានីភ្នំពេញ។

ក្រុមហ៊ុន ហេង ណុង មិនត្រូវបានដាក់បង្ហាញនៅក្នុងបញ្ជីនោះទេ។ ចំណែកអសយដ្ឋានក្រុមហ៊ុន ហេង យូ ដែលស្ថិតនៅក្នុងស្រុកឆែប ខេត្តព្រះវិហារ ត្រូវបានមន្ត្រីអង្គការមិនមែនរដ្ឋាភិបាលកំណត់ថា គឺជាក្រុមហ៊ុនដាំស្រូវ។

អ្នកយកព័ត៌មានបានទៅមើលក្រុមហ៊ុន ហេង ហ្វូ ដែលស្ថិតនៅក្នុងស្រុកឆែប ឃុំម្លូរព្រៃ១ ដែលដាំស្រូវ និងដើមអំពៅនៅក្នុងខែកក្កដា។ សន្តិសុខមិនបានអនុញ្ញាតិឱ្យអ្នកយកព័ត៌មានចូលទៅសម្ភាសន៍តំណាងក្រុមហ៊ុនទេ។ លេខទូរស័ព្ទដែលត្រូវបានមើលឃើញនៅរោងចក្រនោះ ក៏មិនអាចទាក់ទងបានដែរ ចំណែកអ្នកដែលលើកទូរស័ព្ទបាននិយាយថា គាត់លែងជាបុគ្គលិករបស់ក្រុមហ៊ុនទៀតហើយ។




*ក្រាហ្វិចបង្ហាញពី សហគមន៍ជនជាតិដើមភាគតិចនៅខេត្តព្រះវិហារធ្លាក់ខ្លួនជំពាក់បំណុលធនាគារ*

## ការបាត់បង់ដី

ដោយយោងតាមអ្នកភូមិការឈូសឆាយដីព្រៃបានធ្វើឡើងខ្លាំងនៅឆ្នាំ២០១១។

អ្នកស្រី ខៀវ ហិម រស់នៅភូមិប្រមេរុ ស្រុកត្បែងមានជ័យ មានប្រសាសន៍ថា៖ «**ក្រុមហ៊ុនចូលឈូសឆាយដីរបស់ប្រជាពលរដ្ឋស្រស់ៗតែម្តង ដោយពុំបានពិគ្រោះយោបល់ ឬជូនដំណឹងអ្វីនោះដែរ។ យើងបានព្យាយាមដើម្បីបញ្ឈប់ពួកគេ នៅពេលដែលយើងឃើញគ្រឿងចក្រកំពុងឈូសឆាយ**»។

មន្ត្រីចងក្រងសហគមន៍នៃអង្គការពន្លកខ្មែរ លោក ប៊ុក សោភ័ណ មានប្រសាសន៍ថា ភូមិ២៥ នៅក្នុងឃុំចំនួន១០ នៃស្រុកចំនួន ៣ រងផលប៉ះពាល់ខ្លាំងពីការឈូសឆាយនោះ។ លោកថា ក្រុម-

គ្រួសារជាច្រើនត្រូវបានបណ្ដេញចេញពីដីរបស់ពួកគេ ដើម្បីយកដីនោះទៅដាំដើមអំពៅ។ លោកបន្តថា ប្រហែលជាពាក់កណ្ដាលនៃដីដែលត្រូវបានផ្ដល់សម្បទាននោះ ឥឡូវនេះ ត្រូវបានឈូសឆាយអស់ហើយ។

អង្គការធ្វើការលើសិទ្ធដីធ្លីបានប៉ាន់ប្រមាណថា ប្រហែល ២៥ភាគរយនៃដីនោះ គឺប៉ះពាល់ដល់ពលរដ្ឋដែលមានប្រហែលជា ២០០០គ្រួសារ។ ពលរដ្ឋខ្លះក្នុងចំណោម១ម៉ឺននាក់បានទាមទារប័ណ្ណកម្មសិទ្ធិដោយសារតែពួកគេបានរស់នៅទីនោះតាំងពីកំឡុងឆ្នាំ១៩៨០ មក។

អង្គការមិនមែនរដ្ឋាភិបាល និងអ្នកភូមិបាននិយាយថា ទោះជាមានការតវ៉ាជាមួយក្រុមហ៊ុន ហេងហ្វូ តែអ្នកដែលរងផលប៉ះពាល់ជាច្រើន មិនទាន់ទទួលបានសំណងនៅឡើយ។

លោក សោភ័ណ និយាយថា៖ «អ្នកខ្លះមិនដែលទទួលបានសំណងទាល់តែសោះ»។

ហ្គ្រេន(Grain) ដែលជាអង្គការមិនរកផលកម្រៃ និយាយថា អ្នកភូមិខ្លះបានទទួលយកសំណង បន្ទាប់ពីដីរបស់ពួកគេត្រូវបានហ៊ុំព័ទ្ធដោយដើមអំពៅ ដោយមិនអាចមានផ្លូវដើម្បីចូលទៅកាន់ដីរបស់ពួកគេបាន។ អង្គការនេះនិយាយថា អ្នកភូមិបានទទួលសំណងតិចតួចគឺ ២៥០ដុល្លារក្នុងមួយហិកតា។

នៅក្នុងសេចក្ដីថ្លែងការណ៍រួមមួយជាមួយនឹងអង្គការពន្លកខ្មែរ និងអង្គការបីផ្សេងទៀត អង្គការហ្គ្រេន បានបញ្ជាក់ថា ក្រុមហ៊ុនបានរឹបអូសយកកម្មសិទ្ធិដីមួយចំនួនដោយមិនមានការផ្ដល់សំណងអ្វីទាំងអស់។

ដោយយោងតាមច្បាប់ ការដកយកកម្មសិទ្ធិដីរបស់ប្រជា-ពលរដ្ឋ គឺមិនត្រូវបានអនុញ្ញាតិនោះទេ លើកលែងតែវា គឺដើម្បីផលប្រយោជន៍សាធារណៈ និងក្រោយពេលដែលសំណងដោយយុត្តិធម៌ត្រូវបានផ្ដល់ជូនជាមុន។

បន្ថែមជាមួយនឹងការមិនបានផ្ដល់សំណងសមរម្យនេះ ក្រុមហ៊ុនក៏មិនបានរៀបចំធ្វើការសិក្សាពីហេតុប៉ះពាល់បរិស្ថាន និងសង្គមផងដែរ រហូតទាល់តែមានការឈូសឆាយចាប់ផ្ដើម។ នៅពេលនោះ ក្រុមហ៊ុនបានរៀបចំការសិក្សាពីផលបះពាល់បរិស្ថាន និងសង្គមដែលរៀបចំដោយ Green Environment Group នៅខែកក្កដា ឆ្នាំ២០១៦ ខណៈដែលជម្លោះបានបន្តកើតមានឡើងរយៈពេល ៥ឆ្នាំមកហើយ។

គម្រោងកសិកម្មដែលមានទំហំ ១ម៉ឺនហិកតា ឬច្រើនជាងនេះ ត្រូវបានទាមទាឱ្យដាក់របាយការណ៍វាយតម្លៃពីផលប៉ះពាល់បរិស្ថាន និងសង្គមនៅមុនពេលមានការសម្រេច នេះបើយោងតាមអនុក្រឹត្យចេញនៅឆ្នាំ១៩៩៩។ ការទាមទានេះ គឺត្រូវបានបញ្ចៀសដោយការបំបែកក្រុមហ៊ុនជា៥ នៃក្រុមហ៊ុន ហេង ហ្វូ។ នៅក្រោមច្បាប់កិច្ចការពារបរិស្ថាន អ្នកដែលបានប្រព្រឹត្តបទល្មើសនឹងត្រូវមានទោសជាប់ពន្ធនាគាររហូតដល់ ៥ឆ្នាំ។

ការវាយតម្លៃផលប៉ះពាល់បរិស្ថានពីក្រុមហ៊ុន រ៉ួយ ហ្វេង និងក្រុមហ៊ុន ឡាន ហ្វេង នៅក្នុងឆ្នាំ២០១៦ ដែលត្រូវបានពិនិត្យឃើញដោយអ្នកយកព័ត៌មាន VOD បាននិយាយថា ក្រុមហ៊ុននឹងត្រូវឈូសឆាយដីចម្ការរបស់អ្នកភូមិ ដើម្បីធ្វើផ្លូវចូលទៅកាន់ចម្ការអំ-ពៅ។ វាបន្ថែមថា អ្នកភូមិគួរត្រូវបានផ្ដល់សំណងសមរម្យ និងអាចទទួលយកបានសម្រាប់ពួកគេ។

អ្នកភូមិបាននិយាយថាក្រុមហ៊ុនមិនបានធ្វើតាមនោះឡើយ ទោះបីជាមានការចេញរបាយការណ៍ដូច្នេះក៏ដោយ។



*លោក សិទ្ធ សារ៉េន តំណាងសហគមន៍ព្រាហ្ម ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ ផ្ដល់បទសម្ភាសន៍ នៅខាងមុខរោងសហគមន៍ដែលបានបិទទ្វាររបស់វាជាច្រើនឆ្នាំមកហើយ។ (ម៉េង មុន្នីរ័ត្ន)*

លោក សិដ្ឋ សាវ៉ន តំណាងសហគមន៍ប្រមេរុ ស្រុកត្បែង មានជ័យលើកឡើងថាអ្នកភូមិបានបន្តដាក់ពាក្យបណ្តឹងទៅកាន់អាជ្ញាធរគ្រប់កន្លែងអំពីផលប៉ះពាលនេះ។

គាត់និយាយថាៈ «ក្រុមហ៊ុនមិនមានការផ្តល់សំណងនោះទេ។ អ្នកភូមិបានសួរថា តើយើងបានដាក់ពាក្យបណ្តឹងប៉ុន្មានដងហើយ ហើយហេតុអ្វីបានជាពួកគេមិនបានដឹងពីរឿងនេះ»។

ការវាយតម្លៃផលប៉ះពាល បាននិយាយដែរថា ព្រៃត្រូវតែត្រូវបានរក្សាទុកយ៉ាងហោចណាស់១០០ម៉ែត្រពីមាត់ស្ទឹងទាំងសងខាង។ វាគឺជាលក្ខខណ្ឌដែលក្រុមហ៊ុនមិនបានអនុវត្តតាមនោះទេ។

អ្នកភូមិប្រើសត្តក ឈ្មោះ អោន បាននិយាយថា ក្រុមហ៊ុនចម្ការអំពៅបានសម្អាតដីព្រៃ និងបានចូលទៅក្នុងដីដែលពួកគេធ្វើដំណើរទៅ មើលព្រៃ និងស្រែប្រហែលជា ១០ម៉ែត្រទៀតផង។ វាគឺទីកន្លែងមួយដែលអ្នកយកព័ត៌មានបានមើលឃើញនៅទីនោះ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លោក វេង សាខុន បានទទួលស្គាល់ថា មានពេលខ្លះ ក្រុមហ៊ុនក៏អនុវត្តបំពានគោលការណ៍ ដែលបានព្រមព្រៀងដែរ។

គាត់មានប្រសាសន៍ថាៈ « នីតិវិធីគេធ្វើត្រឹមត្រូវ។ ប៉ុន្តែដោ យឡែកជួនកាលអ្នកខ្លះចន្លោះតិចតួចដែរ ជួនកាលដែលយើងឈូសមុន អាចប៉ះពាល់អ៊ីចឹងទៅណា »។

បន្ទាប់ពីការព្យាយាមទាក់ទងទៅក្រុមហ៊ុន ដោយការធ្វើដំណើរទៅដល់ទីតាំងធ្វើការផ្ទាល់នៅក្នុងខេត្តព្រះវិហារ ទូរស័ព្ទការផ្ញើសារ និងសារអេឡិចត្រូនិចជាច្រើន នៅទីបំផុតអ្នកនាំពាក្យក្រុមហ៊ុន ហេងហ្វូ បានហៅអ្នកយកព័ត៌មានទៅជួបនៅការិយាល័យក្រុមហ៊ុននៅក្រុងភ្នំពេញ។ ការិយាល័យក្រុមហ៊ុនស្ថិតនៅជាន់ទី១៥នៃអាគារ Prince Tower លើផ្លូវមុន្នីវង្សនៅក្នុងខែតុលានេះ។

អ្នកនាំពាក្យក្រុមហ៊ុនលោកសៅ លីប ជិសេធផ្តល់ការឆ្លើយតបទៅសាធារណជនចំពោះបញ្ហាផ្សេងៗ ដែលត្រូវបានលើកឡើងដោយអ្នកភូមិ និងអង្គការមិនមែនរដ្ឋាភិបាល ក្រោយពេលដែលបាននិយាយប្រហែលជា ១៥នាទី។

# ឱកាសចុងក្រោយ

ដោយយោងតាមកាសែត The Cambodia Daily នៅថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០១៦ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានចូលរួមបើកសម្ពោធរោងចក្រស្ករអំពៅដែលមានតម្លៃ ៣៦០លានដុល្លារ។ លោកនាយករដ្ឋមន្ត្រី បានសន្យាផ្តល់ការងាររាប់រយកន្លែងសម្រាប់ពលរដ្ឋនៅមូលដ្ឋាន ដោយបាននិយាយថា អ្នកភូមិមានឱកាសបានលក់អំពៅរបស់ពួកគេឱ្យទៅក្រុមហ៊ុន។

ទោះយ៉ាងណា លោក ជាន ហេង មេឃុំប្រមេរុ ប្រាប់ VOD ថា មិនមាននរណាម្នាក់នៅក្នុងភូមិ-ឃុំរបស់លោក បានទទួលយកនូវការងារនោះទេ។

លោក ជាន ហេង បន្តថាៈ «ពីមុនក្រុមហ៊ុនចង់បានដែរ តែបងប្អូនយើងគេអត់ធ្វើ។ គិតទៅ ខ្ញុំមិននិយាយកាន់ជើងខាងក្រុមហ៊ុន និងមិននិយាយកាន់ជើងខាងបងប្អូនទេ បងប្អូនយើងទម្លាប់ថាអត់ចង់ធ្វើខ្ញុំគេ»។

អ្នកភូមិឈ្មោះ នួន ម៉ុន អាយុ ៦៥ឆ្នាំ បាននិយាយប្រាប់កាសែត ខឺខេមបូឌាដេលីនៅថ្ងៃសម្ពោធនោះថា ក្រុមហ៊ុន រ៉ួយហ្វេង បានយកដីរបស់គាត់ចំនួនជិត១ហិកតា ហើយជម្លោះបានអូសបន្លាយរយៈពេល ៥ឆ្នាំហើយ ប៉ុន្តែ អ្នកភូមិនៅតែមិនអាចមានការសហការជាមួយនឹងក្រុមហ៊ុន។

លោក នួន ម៉ុន និយាយថាៈ «យើងមិនចង់ធ្វើការឱ្យគេនៅលើដីរបស់យើងនោះទេ។ ពួកគេមិនមានប្រយោជន៍សម្រាប់យើងទេ»។

ច្រើនជាងការផ្តល់នូវកំណើនសេដ្ឋកិច្ចដល់ពួកគេ នៅក្នុងការអនុវត្តចម្ការអំពៅបានធ្វើឱ្យមានផលប៉ះពាល់ ដោយបានកាត់បន្ថយនូវជីវភាពរស់នៅរបស់សហគមន៍នៅជុំវិញក្រុមហ៊ុននោះ។

សហគមន៍ជនជាតិកួយ ដែលត្រូវបានសម្ភាសន៍ដោយអ្នកយកព័ត៌មាន VOD បាននិយាយម្តងហើយម្តងទៀត ដោយលើកពីការបាត់បង់លទ្ធភាពរបស់ពួកគេក្នុងការប្រមូលអនុផលពីព្រៃឈើ ដែលជាប្រភពចំណូលសំខាន់របស់សហគមន៍។

«ខ្ញុំបានបោះបង់ចោលការងារនេះពីព្រោះថា ក្រុមហ៊ុនបានឈូសព្រៃដែលខ្ញុំបានប្រើប្រាស់ដើម្បីប្រមូលអនុផលសម្រាប់សហគមន៍» ពិន ជ័យ អាយុ៤០ឆ្នាំ ដែលជាស្ត្រីជនជាតិកួយក្នុងឃុំប្រមេរុ ប្រាប់អ្នកយកព័ត៌មាន។

លោក ស៊ិន វាសនា ដែលជាឈ្មួញកណ្តាលរស់នៅភូមិបុះធំ ស្រុកត្បែងមានជ័យ ឱ្យដឹងថា នៅមុនឆ្នាំ២០១២ លោកធ្លាប់ទិញជ័រទឹកបានចន្លោះពី ១៥០០លីត្រ ទៅ ១៨០០លីត្រ ក្នុងមួយថ្ងៃ ប៉ុន្តែ ចំនួននេះបានធ្លាក់ចុះមកនៅត្រឹម ១៥០លីត្រ ទៅ ៣០០លីត្រ ប៉ុណ្ណោះក្នុង១ថ្ងៃ។

លោកប្រាប់ថា៖ **«មានការធ្លាក់ចុះដោយសារពីមុនមានដើមឈើច្រើនទៅ មានគេយកជ័របានច្រើន។ ដល់ពេលឥឡូវគេកាត់អស់ហើយជ័រនៅសល់តិចតួច ដល់ពេលហើយទៅឯងជ័រវាបានតិចតាមហ្នឹងដែរ»។**

យោងតាមអង្គការពន្លកខ្មែរ សហគមន៍ប្រមូលអនុផលព្រៃឈើ ដែលមានការជួយពីអង្គការមិនមែនរដ្ឋាភិបាល នៅក្នុងឃុំប្រមេរុ ត្រូវបានបិទនៅក្នុងឆ្នាំ២០១៦ ដោយសារតែការធ្លាក់ចុះខ្លាំងនៃអនុផលព្រៃឈើ។ របាយការណ៍អង្គការមិនមែនរដ្ឋាភិបាលបង្ហាញថា ចន្លោះពីឆ្នាំ២០១០ ដល់២០១៦ ចំណូលរបស់សហគមន៍ពីផលិតផល អនុផលព្រៃឈើបានធ្លាក់ចុះយ៉ាងគំហុក។

នៅក្នុងខែធ្នូ ឆ្នាំ២០១០ នៅពេលដែលចម្ការបានចាប់ផ្តើមផ្តល់អនុផល សហគមន៍រកចំណូលបាន ២៧លានរៀល ឬប្រហែលនឹង ៦៧៥០ដុល្លារ។ នៅពេលនោះចម្ការត្រូវបានបិទនៅក្នុងខែមិថុនាឆ្នាំ២០១៦ ហើយវាបានកាត់បន្ថយចំណូលជាងពាក់កណ្តាល គឺលើសពី ១៣លានរៀល ឬប្រហែលជា ៣២៥០ដុល្លារ នេះបើយោងតាមឯកសារគណនេយ្យរបស់អង្គការមិនមែនរដ្ឋាភិបាល។

រស់នៅស្រុកត្បែងមានជ័យ អ្នកស្រី ស៊ីង សេត ដែលអះអាងពីភាពរងគ្រោះដោយបាត់បង់ចម្ការ ហើយនឹងធ្លាក់ខ្លួនកាន់តែក្រនៅក្នុងសហគមន៍ ឥឡូវនេះ គឺត្រូវបន្តធ្វើស្រែតាមយថាផល។

អ្នកស្រីនិយាយថា៖ **«ដើម្បីអាចមានចំណូលទ្រទ្រង់ជីវភាពសមាជិកខ្លះក្នុងគ្រួសារ ត្រូវបង្ខំចិត្តចំណាកស្រុក ហើយអ្នកខ្លះទៀតនៅរដូវវស្សាដើរស៊ីឈ្នួលស្ទូងស្រូវឱ្យគេ»។**

លោក សោភ័ណ នៅអង្គការពន្លកខ្មែរនិយាយថា អនុផលព្រៃឈើកន្លងមក បានផ្តល់ចំណូលដែលអាចផ្គត់ផ្គង់ជីវភាពពួកគេតាមរយៈការប្រមូលផលជ័រ ស្លឹក និងអនុផលច្រើនផ្សេងទៀត។ ពួកគេបានផ្តល់បណ្តាញសុវត្ថិភាព នៅពេលដែលដំណាំកសិកម្មមិនទទួលផលដោយសារជំនន់ ឬរាំងស្ងួត។

លោកនិយាយថាឥឡូវនេះគឺមានជម្រើសតិចណាស់នៅពេលដែលអ្នកភូមិខ្លះមិនអាចរកបានចំណូលពីការចញ្ចឹមមាន់ ទា ជ្រូក។

គាត់និយាយថា៖ **«ហេតុអ្វី? ពីព្រោះពួកគេមិនមានដីដែលអាចឱ្យពួកគេចិញ្ចឹមសត្វបាន»។**

## ២. ជនជាតិចិនគ្រប់គ្រងមុខរបរដែលខ្មែរធ្លាប់ធ្វើអាជីវកម្មនៅខេត្តព្រះសីហនុ




*ក្រាហ្វិចបង្ហាញពី អាជីវកម្មដែលគ្រប់គ្រងដោយជនជាតិ នៅខេត្តព្រះសីហនុ ដោយផ្អែកតាមរបាយការណ៍របស់ស្នងការខេត្តព្រះសីហនុ បច្ចុប្បន្នភាព ត្រឹមខែកក្កដា ឆ្នាំ២០១៩*

លោក ចេង យាង គឺជាអ្នកលក់បាយម្នាក់នៅក្នុងក្រុងព្រះសីហនុ។ គាត់និយាយថា សព្វថ្ងៃនេះអ្នកដែលរកចំណូលបានជាធម្យម ៣០០ដុល្លារអាម៉េរិកក្នុងមួយខែគឺ ពិបាករស់នៅណាស់។ សម្រាប់លោក យាង ទំនិញនៅលើទីផ្សារក្នុងខេត្តព្រះសីហនុគឺបានឡើងថ្លៃខ្ពស់។

" ហើយពេលជនជាតិចិនមក សព្វសារពើ ទំនិញខេត្តផ្សេង ខ្ញុំអត់និយាយទេ តែសម្រាប់កំពង់សោមមួយគឺ very very high" ។

លោក យាង និយាយថា ជនជាតិចិនដែលមករស់នៅក្នុងខេត្តព្រះសីហនុ បើកហាងអាហារដើម្បីលក់ឲ្យជនជាតិចិនដូចគ្នា។ លោកបញ្ជាក់ថា អាហារនៅក្នុងហាងចិនគឺមានតម្លៃខ្ពស់។ " របស់ពួកគាត់អត់មានប្រើស្ករ ប្រើប៊ីចេង គឺ ប្រើតែអំបិល និងម្ទេសអីតិចតួច។ ហើយជនជាតិចិនបើកហាងលក់សម្រាប់តែពួកគាត់។ ខ្មែរអត់មានលទ្ធភាពចូលទេ។ ម្ហូបសុទ្ធតែមួយចាន ២០ទៅ៣០ដុល្លារអាមេរិក"។

លោក ចេង យាង មិនមែនតែជាអាជីវករម្នាក់ដែលកំពុងតែបាត់បង់ចំណូលទេ។ អ្នកលក់ដូរផ្សេងៗទៀតនិយាយថាពួកគេរកចំណូលបានតិចជាងមុន។



រូបសំណាកតោពីរ ឈរកំដរសំណង់អគារក្រុមហ៊ុនចិន កណ្តាលក្រុងព្រះសីហនុ

អ្នកស្រី ជន ប៊ិក ប្រកបមុខរបរលក់មឹកអាំងតាមឆ្នេរអូរឈើទាល។ អ្នកស្រីនិយាយថាការរកចំណូលរបស់គាត់បានថយចុះពី ១០ម៉ឺនរៀលមក ៤ម៉ឺនរៀលក្នុងមួយថ្ងៃ។អ្នកស្រីប៊ិកគិតថា ការបាត់បង់ចំណូលរបស់គាត់គឺដោយសារភ្ញៀវក្នុងស្រុកធ្លាក់ចុះ និងសម្ភារៈទិញចូលថ្លៃ។ "ពីមុនបាន តែឥឡូវអត់បានទេ [ចំណូល]។ មឹកឡើងថ្លៃយើងនៅលក់តម្លៃដដែល។ ឥវ៉ាន់ឡើងថ្លៃគ្រប់មុខ។ ម៉ូយទិញក៏ឡើងថ្លៃព្រោះអីបើយើងដេកយូរទៅអត់ទាន់ចិនទេចិនយកអស់។ ចិនទិញកើបយកទាំងអស់ៗហ្នឹង។ វាយកទៅហូប និងលក់ក្នុងហាងចិន។ អត់មានខ្មែរទេសចរមក មានតែពួកសំណង់។ អ្នកភ្នំពេញក៏កម្រមកដែរ ព្រោះផ្ទះសំណាក់ឡើងថ្លៃ"។

អ្នកស្រី អាំ អតីតអ្នកលក់មឹកអាំងនៅតាមឆ្នេរអូរឈើទាលឲ្យដឹងថា តូបខ្មែរនៅសល់ប្រមាណ១០តូបប៉ុណ្ណោះកំពុងដំណើរការអាជីវកម្មនៅលើឆ្នេរអូរឈើទាល ក្នុងខេត្តព្រះសីហនុ។ គាត់និយាយថា ក្នុងចំណោមនេះ មានខ្លះអត់មានភ្ញៀវចូលហូបទេ។ ចំណែកតូបប្រមាណ៩០ភាគរយគឺមានម្ចាស់ជាជនជាតិចិន និងក្រៅពីនេះតូបចំនួន០៤មានម្ចាស់ជាជនជាតិជាតិអឺរ៉ុប។ ទោះបីមានហាងអឺរ៉ុបមួយចំនួននៅបន្តបើកទ្វារធ្វើអាជីវកម្ម ប៉ុន្តែម្ចាស់ហាងខ្លះនិយាយថាពួកគេប្រឈមមុខនឹងការបិទទ្វារនៅពេលខាងមុខ។

ម្ចាស់ហាងអឺរ៉ុបមួយកន្លែងឈ្មោះ សាន់សេត ឡោញ (Sunset Lounge Beach Resort) ដែលស្នើសុំមិនបញ្ចេញឈ្មោះ និងសំឡេងបានលើកឡើងថា ហាងរបស់អ្នកស្រីប្រឈមមុខនឹងបិទទ្វារនៅខែធ្នូចុងឆ្នាំនេះ។ អ្នកស្រីនិយាយថា ដីហាងដែលអ្នកស្រីកំពុងជួលនេះគឺ ត្រូវបានជួលបន្តឲ្យទៅជនជាតិចិនហើយ។ យោងតាមកិច្ចសន្យាដែលម្ចាស់ហាងសាន់សេត ឡោញ បានធ្វើជាមួយនឹងម្ចាស់ដីគឺវាមានរយៈពេល៦ឆ្នាំទៀត។ ស្ត្រីម្ចាស់ហាងរូបនេះនិយាយថាម្ចាស់បានជួលដីនេះទៅឲ្យជនជាតិចិនក្នុងតម្លៃខ្ពស់។ គាត់និយាយដែរថាភ្ញៀវអឺរ៉ុបបានធ្លាក់ចុះ ហើយគាត់មិនទទួលបានភ្ញៀវច្រើនដូចមុនទៀតទេ ដូច្នេះអ្នកស្រីត្រូវបិទទ្វារ និងបញ្ចប់កិច្ចសន្យាជួលដីមុនពេលកំណត់។

លោក អ៊ី វ៉ាង គឺជាអ្នកបើករថយន្តដឹកភ្ញៀវប្រចាំនៅហាងអឺរ៉ុបជិតអតីតព្រះរាជដំណាក់ ក្នុងខេត្តព្រះសីហនុ។ គាត់និយាយថា កាលពី២ឆ្នាំមុន លោកអាចរកចំណូលបានពីការដឹកភ្ញៀវជាមធ្យមក្នុងមួយថ្ងៃចន្លោះពី ៨ម៉ឺនទៅ១២ម៉ឺនរៀល។ លោកបន្តថា អ្នកវិនិយោគចិនចូលមក ភ្ញៀវអឺរ៉ុបធ្លាក់ចុះ ចំណែករូបលោករកចំណូលបានជាមធ្យមប្រហែល៤ម៉ឺនរៀលប៉ុណ្ណោះក្នុងមួយថ្ងៃ។ " បញ្ហាវាពិបាករកស៊ីជាងមុនឆ្ងាយ។កាលជនជាតិអឺរ៉ុបនៅច្រើនយើងអាចរកស៊ីបានច្រើន។ ដល់ពេលជនជាតិចិនមកនៅ គេមានរបស់គេ គេមិនសូវប្រើប្រាស់របស់យើងណា។ ដូច្នេះយើងវាពិបាក។ ក្នុងមួយថ្ងៃ ឥឡូវនេះរកចំណូលជួនកាលរកមិនបាន១០ដុល្លារអាមេរិកផង "។




លោក ឌី វ៉ាង អ្នកបើកបរយន្តដឹកភ្ញៀវប្រចាំនៅហាងអីវ៉ាន់ ជិតវត្តព្រះរាជធំណាក់ ក្នុងខេត្តព្រះសីហនុ

លោក ឃាង ភារម្យ គឺជាអ្នកនាំពាក្យសាលាខេត្តព្រះសីនុ។ គាត់ទទួលស្គាល់ថា មានជនជាតិចិនច្រើនជាងជនជាតិផ្សេងទៀតដែលកំពុងតែរកស៊ីនៅខេត្តព្រះសីហនុ។

«នៅខេត្តព្រះសីហនុយើងនេះ យើងឃើញថា យើងមានចម្រុះជាតិសាសន៍។ សម្រាប់អ្នកមកវិនិយោគហ្នឹងជាជនបរទេសមានច្រើនជាតិសាសន៍។ ប៉ុន្តែក្នុងនោះយើងសង្កេតឃើញថា វិនិយោគិនបរទេសដែលជាជនជាតិចិនមានវត្តមានគាត់ ច្រើនជាងសាសន៍ដទៃទៀត »។

របាយការណ៍ស្តីពីជំរឿនស្ថិតិជនបរទេស របស់រដ្ឋបាលខេត្តព្រះសីហនុ ចេញផ្សាយក្នុងខែកុម្ភៈ ឆ្នាំ២០១៩ ឲ្យដឹងថា មានជនបរទេសស្នាក់នៅអចិន្ត្រៃយ៍ក្នុងខេត្តព្រះសីហនុជាង ៤០៧៧០នាក់ ក្នុងចំណោម ៥៧សញ្ជាតិ។

លោក គង់ សុភក្ត្រា ប្រធាននាយកដ្ឋានស្ថិតិនៃក្រសួងទេសចរណ៍មានប្រសាសន៍ថា គិតត្រឹម៧ខែដើមឆ្នាំ២០១៩ ភ្ញៀវទេសចរណ៍ចិនឈរលំដាប់លេខ១ បន្ទាប់ពីភ្ញៀវទេសចរណ៍ជនជាតិថៃ។ តាមលោក សុភក្ត្រា ចំនួនភ្ញៀវទេសចរណ៍ចិនកើនឡើងជាង ២០ម៉ឺននាក់ស្មើប្រមាណ១០១.៨ភាគរយ ក្នុងចំណោមភ្ញៀវទេសចរណ៍បរទេសសរុប ៤៨ម៉ឺននាក់។

យោងតាមរបាយការណ៍របស់ក្រសួងទេសចរណ៍បង្ហាញថា ភ្ញៀវទេសចរអឺរ៉ុប ដែលទៅទស្សនានៅខេត្តព្រះសីហនុបានថយចុះចាប់តាំងពីខែមករាដើមឆ្នាំ២០១៩នេះ។ បើតាមរបាយការណ៍ដដែលនេះ ចំនួនភ្ញៀវទេសចរមកពីប្រទេសនៅអឺរ៉ុប និងអាមេរិកមានតែជាង ៦ម៉ឺននាក់ គិតត្រឹម៧ខែដើមឆ្នាំ២០១៩នេះ។

កញ្ញា វ៉ន ស្រីណែត អ្នកលក់ដូរនៅឆ្នេរសមុទ្រអូរឈើទាល ឲ្យដឹងថា កាលពី២ឆ្នាំមុន ក្រុមគ្រួសាររបស់ខ្លួនអាចរកចំណូលបានពីការលក់គ្រឿងសមុទ្រ នៅតាមមាត់ឆ្នេរសមុទ្រប្រមាណ ២៥០ ដុល្លារអាមេរិកក្នុងមួយថ្ងៃ។ ប៉ុន្តែ ស្រីណែតអះអាងថា ក្នុងរយៈពេល ២ឆ្នាំចុងក្រោយនេះ ចំណូលធ្លាក់ចុះ ហើយពេលខ្លះរកមិនបាន ១០០ ដុល្លារអាមេរិកផងក៏មានដែរក្នុងមួយថ្ងៃ។ បើតាម វ៉ន ស្រីណែត មូលហេតុនៃការបាត់បង់ចំណូលនេះ ដោយសារមិនមានភ្ញៀវទៅលេងកំពង់សោមដូចមុន។ ម្យ៉ាងវិញទៀត ចិនចាប់ផ្តើមបើកហាងលក់ដូរនៅតាមឆ្នេរសមុទ្រដូចប្រជាពលរដ្ឋខ្មែរដែរ។



ហាងទំនិញ និងក្រុមហ៊ុនអចលនទ្រព្យរបស់ជនជាតិចិន នៅក្រុងព្រះសីហនុ

ស្រីណែត លើកឡើងថា «ពីមុនមួយថ្ងៃបានប្រមាណពី ២០០ទៅ៣០០ដុល្លារអាម៉េរិកអីដែរ។ ប៉ុន្តែថ្ងៃខ្លះវាឡើងហើយថ្ងៃខ្លះវាចុះទៅតាមនឹង។ មកដល់ឥឡូវនេះវិញ យើងរកមិនសូវបានទេចំមួយភ្លៀងជាប់រហូតហើយទីមួយស្ងាត់ភ្ញៀវផងអត់ដូចលើកមុនទេ»។

លោក វី ធឿន អ្នករកស៊ីដឹកភ្ញៀវទេសចរណ៍ប្រចាំប្រលានយន្តហោះកំពង់សោម ឲ្យដឹងថា សព្វថ្ងៃនេះពលរដ្ឋខ្មែរមួយចំនួនធំបានបោះបង់មុខរបរ ហើយចាកចេញទៅខេត្តផ្សេងវិញ។

ប្រភពបន្តថាមូលហេតុសំខាន់ពួកគាត់សម្រេចជួលដីឲ្យចិនព្រោះបានថ្លៃ។ ហើយហេតុផលមួយទៀតដោយសារចំនួនភ្ញៀវក្នុងស្រុក និងអឺរ៉ុបធ្លាក់ចុះ ធ្វើឲ្យអ្នកធ្លាប់រកស៊ីត្រូវបាត់ចំណូល។ លោក ធឿន លើកឡើងទៀតថា ហេតុផលនេះហើយដែលបង្ខំចិត្តឲ្យអ្នកប្រកបអាជីវកម្មមួយចំនួនត្រូវចាកចេញពីកំពង់សោម។ លោកឲ្យដឹងថា

"កត្តាវាមានច្រើនគឺ អ្នកតាមខេត្ត និងទីក្រុងភ្នំពេញពួកគាត់មិនសូវមកលេងដូចមុន ព្រោះដោយសារទីមួយខ្វះផ្ទះសំណាក់។ ផ្ទះសំណាក់ភាគច្រើនពេលនេះអត់មានខ្មែរទេ មានតែចិន។ ជាធម្មតាខ្មែរ និងចិនខុសគ្នា។ ចិនចូលចិត្តមាត់ឮៗ និងរញ៉េរញ៉ៃច្រើន មិនដូចអឺរ៉ុបគាត់រួសរាយ "។

លោក សន ស៊ីផល ប្រធានសាខាពន្ធដារខេត្តព្រះសីហនុ។ គាត់ទទួលបន្ទុកប្រមូលទិន្នន័យការចុះបញ្ជីក្បាលដីនិងផ្ទះ។ លោក ស៊ីផល បដិសេធថា លោកមិនដែលបានដឹងពីតួលេខប្រជាពលរដ្ឋជួលដី ឬផ្ទះឲ្យចិនទេ។

ដោយត្រូវបានជួបសម្ភាសន៍ផ្សេងៗពីគ្នា ពលរដ្ឋនៅខេត្តព្រះសីហនុ៣០នាក់ បានប៉ាន់ប្រមាណថា យ៉ាងហោចណាស់មានពលរ ដ្ឋ ៦០ភាគរយ កំពុងទទួលរងផលប៉ះពាល់អវិជ្ជមានពីការអភិវឌ្ឍក្នុងខេត្តនេះ។ ពួកគេប៉ាន់ប្រមាណថា ពលរដ្ឋប្រហែលជា ៤០ភាគរយបានទទួលផលខ្ពស់ពីការអភិវឌ្ឍន៍។

ហាងទំនិញ និងក្រុមហ៊ុនអចលនទ្រព្យរបស់ជនជាតិចិននៅក្រុងព្រះសីហនុយោងតាមទិន្នន័យរបស់រដ្ឋបាលខេត្តព្រះសីហនុកាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ មានក្រុមហ៊ុនចំនួន ៥២ក្រុមហ៊ុនកំពុងតែវិនិយោគនៅក្នុងខេត្តនេះ។ របាយការណ៍ដដែលបញ្ជាក់ថា ប្រហែល៩០ភាគរយគឺជាក្រុមហ៊ុនមកពីប្រទេសចិន។

របាយការណ៍វិនិយោគចិនដែលវីអូឌីទទួលបានពីទីចាត់ការផែនការនៃរដ្ឋបាលខេត្តព្រះសីហនុ គិតត្រឹមខែមេសា ឆ្នាំ២០១៩ បង្ហាញថា ការវិនិយោគមានទឹកប្រាក់ជាង ៨ពាន់៤៦០លានដុល្លារអាមេរិក(៨.៤៦០.៤១៨.៣៦៤$)។ ទំហំទឹកប្រាក់ដែលគ្រប់ដណ្ដប់គម្រោងទាំង ៥២គម្រោងនេះ គឺក្ដោបទៅលើវិស័យសំខាន់ៗក្នុងខេត្តព្រះសីហនុ ដូចជា វិស័យសេវាកម្មទេសចរណ៍ អចលនទ្រព្យ តំបន់សេដ្ឋកិច្ចពិសេស ហេដ្ឋារចនាសម្ព័ន្ធ និងវិស័យឧស្សាហកម្ម។

និស្សិតនៃមហាវិទ្យាល័យសិង្ហបូរី(Singapore)លោកCarl Khouri Klink បានសិក្សាស្រាវជ្រាវអំពីផលប៉ះពាល់នៃការវិនិយោគរបស់ប្រទេសចិននៅខេត្តព្រះសីហនុ។ របាយការណ៍នេះរកឃើញថា ចន្លោះពីឆ្នាំ១៩៩៤ ដល់ឆ្នាំ ២០១៣ ប្រទេសចិនបានចំណាយថវិកាប្រមាណ ១០ពាន់លានដុល្លារ ក្នុងគម្រោងវិនិយោគក្នុងប្រទេសកម្ពុជា។

តាមរបាយការណ៍ ការវិនិយោគនោះគឺផ្ដោតលើវិស័យកសិកម្ម គម្រោងហេដ្ឋារចនាសម្ព័ន្ធ ទំនប់វារីអគ្គិសនី និងរោងចក្រកាត់ដេរសម្លៀកបំពាក់។ របាយការណ៍ដែលបិទបញ្ចប់ការស្រាវជ្រាវកាលពីខែសីហា ឆ្នាំ២០១៩ បង្ហាញដែរថាចន្លោះពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៧ ប្រទេសចិនបានវិនិយោគទឹកប្រាក់ចំនួន ៥,៣ ពាន់លានដុល្លារអាមេរិកមកកម្ពុជា គឺកើន៥ដងបើប្រៀបធៀបនឹងចន្លោះឆ្នាំ១៩៩៤ ដល់ឆ្នាំ២០១៣។ ក្នុងរបាយការណ៍បញ្ជាក់ថា ខេត្តព្រះសីហនុទទួលបានគម្រោងវិនិយោគ ដែលមានតម្លៃជាទឹកប្រាក់១,១ ពាន់លានដុល្លារនៅក្នុងឆ្នាំ២០១៧។

អ្នកស្រី ជៀប សុធារី អ្នកសម្របសម្រួលសមាគមអាដហុក (A dhoc) ប្រចាំខេត្តព្រះសីហនុ។ អ្នកស្រីប្រាប់ថា ពលរដ្ឋនៅក្នុងខេត្ត ទទួលបានផលតិចតួចពីការចូលមកវិនិយោគរបស់ជនជាតិចិននៅក្នុងខេត្តនេះ។ គាត់អះអាងថា ផលប្រយោជន៍បានតែទៅលើចិនគ្នា ឯងច្រើនជាង។ អ្នកស្រី សុធារី កត់សំគាល់ថា ខ្មែរដែលមានលទ្ធភាពដូចជាមានអាគារ និងដីជាដើម ពួកគេសម្រេចជួលឲ្យចិនរួចបន្តចាកចេញពីខេត្ត ទៅរស់នៅកន្លែងផ្សេងវិញ។

" បើនិយាយពីការប្រកបមុខរបររកស៊ីហ្នឹងភោជនីយដ្ឋានធំៗគឺពួកចិនច្រើនជាងខ្មែរ។ អ៊ីចឹងគាត់ទិញតែផលិតផលដែលក្រុមគ្នាគាត់យកមកទេ។ បើរបស់គ្នាគាត់អត់មានបានគាត់(ចិន)មកទិញរបស់យើង(ខ្មែរ)។ អ៊ីចឹងខ្ញុំសួរថា យើង(ខ្មែរ)លក់ឲ្យពីណាប្រើ?។ បើខ្មែរយើងមួយចំនួនធំគឺគាត់ចាកចេញ។ ហើយខ្មែរយើងមួយចំនួនឈប់លក់ដូរ"។

នៅក្នុងរបាយការណ៍បូកសរុបការងារ ឆមាសទី១ដើមឆ្នាំ ២០១៩ លោក យន្ត មីន បញ្ជាក់ថា ដោយសារការរីកចំរើនយ៉ាងឆាប់រហ័សលើគ្រប់វិស័យនេះហើយ ជំរុញឲ្យខេត្តព្រះសីហនុកាត់បន្ថយភាពក្រីក្រធ្លាក់ចុះមកនូវត្រឹម ១០,៧២ភាគរយ ក្នុងមួយឆ្នាំ។

លោក យន្ត មីន មានប្រសាសន៍ថា ប្រជាពលរដ្ឋក្នុងខេត្តព្រះសីហនុទទួលបានចំណូលគិតជាមធ្យម ៣ពាន់៣៥៨ដុល្លារអាមេរិក ក្នុងមួយឆ្នាំ។

លោក ហ៊ុន សំណាង អតីតប្រធានសមាគមរ៉ឺម៉កកង់បី។ បច្ចុប្បន្នលោក សំណាង គឺជាប្រធានផ្នែកឡានក្រុងក្រុមហ៊ុន វិរៈ ប៊ុនថាំ។ លោកនិយាយថា ការបើកចំហរឲ្យចិនវាយលុកទីផ្សារខ្នាតតូចរាប់ចាប់តាំងពីលក់បន្លែ និងរត់តាក់ស៊ី វាជាការគំរាមកំហែងផ្នែកជីវភាពរបស់ប្រជាពលរដ្ឋខ្មែរម្ចាស់ស្រុក។ លោកបន្តថា ប្រសិនបើចិននៅតែបន្តប្រកួតប្រជែងដូចនេះ ហើយរដ្ឋាភិបាលមិនមានមធ្យោបាយទប់ស្កាត់ទេ នោះគឺជាការបិទផ្លូវសេដ្ឋកិច្ចសម្រាប់ប្រជាពលរដ្ឋនាពេលខាងមុខមិនខានឡើយ។

"បាទមានចិនរត់ តុក តុក និងបើកតាក់ស៊ីមែន។ បើបណ្តោយឲ្យពួកគាត់(ចិន)ធ្វើចឹងថ្ងៃក្រោយទៅពួកខ្ញុំបានអីរកស៊ី "។

យោងតាមការបញ្ជាក់របស់លោក វ៉ន់ ពៅ ប្រធានសមាគម IDEA ឲ្យដឹងថា នៅខេត្តព្រះសីហនុមានអ្នករត់ម៉ូតូកង់បីឬហៅថា តុកតុក និងឡានតាក់ស៊ីចំនួន ៣៥០០គ្រឿង។ លោកបន្តថា នៅមុនពេលអាជ្ញាធររឹតបន្តឹងច្បាប់ មានជនជាតិចិនរត់តាក់ស៊ី និងម៉ូតូកង់បីប្រមាណ ៤០ភាគរយ។ តែក្រោយពីអនុវត្តច្បាប់ចំនួននេះបានថយចុះនៅកំពង់សោមប្រមាណ ២០ភាគរយ។

បើទោះជាបែបណាពួកគេ( ចិន) មួយចំនួននៅបន្តដឹកភ្ញៀវលួចលាក់តាមរយៈអនឡាញ (Online) វីឆាត(WeChart)ខ្លះដែរ។ នៅពេលដែលផលរបរតូចតាចខ្លះ កំពុងរងផលប៉ះពាល់ជាអវិជ្ជមានពីការចូលមករកស៊ីរបស់ជនជាតិចិន អ្នកលក់ដូរគ្រឿងសំណង់ខ្លះនិយាយថា ពួកគេរកចំណូលបានច្រើនជាងមុន។

ម្ចាស់អាជីវកម្មគ្រឿងសំណង់ឈ្មោះ សៀវ គួង ឲ្យដឹងថា ចាប់តាំងពីលំហូរជនជាតិចិនចូលមក លោកអាចរកចំណូលបានពីវិស័យសំណង់ច្រើនគួរសមក្នុងមួយថ្ងៃៗ។ ប៉ុន្តែលោក គួង បដិសេធន៍ពីចំនួនជាក់លាក់នៃចំណូល ដែលរកបានពី វិស័យសំណង់នេះ។ លោក គួង បន្តថា ជនជាតិចិនប្រមាណ៨០ភាគរយមានមុខរបរផ្គត់ផ្គង់គ្រឿងសំណង់ដូចខ្មែរដែរ។ ប៉ុន្តែតួលេខនេះបានថយចុះទៅវិញក្រោយពីរដ្ឋាភិបាលដាក់វិធានការប្រឆាំងបទល្មើសអនឡាញទៅលើជនជាតិចិន។

"ល្បីថាទៅវិញក៏ស្បើយជាងមុនដែរ។ អ្នកអនឡាញវាមកវាដៃទូលាយ ដល់អញ្ចឹងកន្លែងណាក៏ជួលៗ ហើយរកស៊ីស្អីៗក៏វាធូរដែរ។ ដល់ឥឡូវនេះដល់វា(ចិន)ទៅវិញក៏ស្បើយច្រើនដែរ។ ចិនធ្លាក់ចុះប្រហែល៥០ភាគរយ។ ធ្លាក់ចុះនេះធ្លាក់ចុះច្រើនមែនទែន"។

នៅខេត្តព្រះសីហនុ ជនជាតិចិនបើកហាងដូរលុយ ហាងកាត់សក់ ជាងផ្សារដែក រថតាក់ស៊ី ម៉ូតូកង់បីឥណ្ឌា និងហាងម៉ាស្សា ហាងលក់គ្រឿងទេស លក់បន្លែ ត្រី និងសាច់ជ្រូកដូចពលរដ្ឋខ្មែរម្ចាស់ស្រុកដែរ។

ស្នងការខេត្តព្រះសីហនុលោក ជួន ណារិន្ទ ឲ្យដឹងកាលពីខែកក្កដា ឆ្នាំ២០១៩ ថា អាជីវកម្មស្ទើរ៩០ភាគរយ នៅក្នុងខេត្តព្រះសីហនុសព្វថ្ងៃនេះត្រូវគ្រប់គ្រងដោយជនជាតិចិន។អាជីវកម្មទាំងនោះរាប់ចាប់តាំងពីផ្ទះសំណាក់ សណ្ឋាគារ ហាងម៉ាស្សា ភោជនីយដ្ឋាន និងកាស៊ីណូជាដើម។

លោក ជួន ណារិន្ទ បញ្ជាក់ថា សណ្ឋាគារ និងផ្ទះសំណាក់ចំនួន ១៥០ទីតាំងក្នុងចំណោម១៥៦កន្លែង ត្រូវគ្រប់គ្រងដោយចិន។ កាស៊ីណូចំនួន៦ ២ កន្លែងក្នុងនោះ៤ ៨ កន្លែងត្រូវគ្រប់គ្រងដោយជនជាតិចិន។ ក្លិបកម្សាន្ត-ខារ៉ាអូខេ៤១កន្លែង គ្រប់គ្រងដោយចិនចំនួន ១៨កន្លែង។ ហាងម៉ាស្សា៤៦ទីតាំងគ្រប់គ្រងដោយចិនក្នុងចំណោមចំនួនសរុប៦៣។ ភោជនីយដ្ឋាន៩៥ភាគរយ ក្នុងចំណោមហាង ៤៣៦ទីតាំង ត្រូវគ្រប់គ្រងដោយចិន។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញសេចក្តីសម្រេច នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ ដោយកំណត់ប្រភេទមុខរបរ និងការងារដែលត្រូវហាមឃាត់ចំពោះជនបរទេស។ តាមរយៈសេចក្តីសម្រេចនេះ រដ្ឋាភិបាលបានហាមឃាត់មុខរបរ១០ប្រភេទ មិនឲ្យជនបរទេសដែលស្នាក់នៅក្នុងប្រទេសកម្ពុជាប្រកបអាជីវកម្ម។




កាស៊ីណូចិន នៅតាមបណ្ដោយឆ្នេរអូរឈើទាល ក្នុងក្រុងព្រះសីហនុ

មុខរបរទាំងនោះរួមមាន អ្នកបើកបរយានជំនិះគ្រប់ប្រភេទជាលក្ខណៈអាជីវកម្មមានជាអាទិ៍៖ អ្នកបើកទោចក្រយានយន្ត អ្នកបើកត្រីចក្រយានយន្ត អ្នកបើកទោចក្រយានយន្ត សណ្ដោងរ៉ឺម៉ក អ្នកបើកម៉ូតូកង់បួន អ្នកបើករថយន្តដឹកអ្នកដំណើរ និងដឹកទំនិញ។ មុខរបរផ្សេងទៀតរួមមាន អ្នកលក់ដូរដោយមធ្យោបាយថ្មើរជើង ឬយានជំនិះគ្រប់ប្រភេទនៅទីសាធារណៈ អ្នកម៉ាស្សាចាប់សរសៃ តាមទីសាធារណៈ អ្នកកាត់សក់ អ៊ុតសក់ និងថែរក្សាសម្ផស្ស អ្នកផ្ដល់សេវាកម្មដេរ និងសម្អាតស្បែកជើង អ្នកកាត់ដេរ អ្នកប៉ះកង់ និងជាងជួលជុលយានយន្ត អ្នកផលិតវត្ថុអនុស្សាវរីយ៍ខ្មែរ អ្នកផលិតឧបករណ៍ភ្លេងខ្មែរ បាត្រលោក និងព្រះពុទ្ធរូប និងជាងទង ឬជាងថ្មក្បូងពេជ្រ។

ក្រសួងការងារព្រមានថា នឹងមិនបន្តសុពលភាពប័ណ្ណសៀវភៅការងារទេ បើរកឃើញថា ជនបរទេសធ្វើអាជីវកម្មដែលបានហាមឃាត់។

អ្នកនាំពាក្យក្រសួងការងារ លោក ហេង សួរ បញ្ជាក់ថា ជនបរទេសដែលល្មើសនឹងចល្លាកម្មនេះ នឹងត្រូវបណ្ដេញចេញពីកម្ពុជាផ្អែកតាមច្បាប់ស្ដីពីអន្តោប្រវេសន៍។

សម្រាប់អ្នកលក់បាយនៅខេត្តព្រះសីហនុដូចជា លោក ចេងយាង ចង់ឃើញមានចំណាត់ការដែលមានប្រសិទ្ធភាពលើសេចក្ដីសម្រេចដែលចេញដោយក្រសួងការងារ។

"ខ្ញុំដូចជាបានឃើញសេចក្ដីប្រកាសនៅក្នុងហ្វេសប៊ុក គេបង្ហោះដែរ។ ខាងរដ្ឋាភិបាល គេនឹងទប់ស្កាត់មុខរបរតូចតាចហ្នឹងដែរ។ ប៉ុន្តែនៅខេត្តកំពង់សោម ខ្ញុំអត់ឃើញអាជ្ញាធរគេចាត់វិធានការអីផង។ ប្រហែលគាត់ខ្វងស្មារហើយប្រហែលគាត់មិនទាន់ដល់ពេលវាយស្គរ គ្រាន់តែខ្វងឲ្យឮសម្លេងសិន "។

អ្នកស្រី កេន សេងឡាង អនុប្រធានសហព័ន្ធសហជីពជាតិនៃឧស្សាហកម្មវាយនភណ្ឌកាត់ដេរកម្ពុជា។ អ្នកស្រីចង់ឃើញវិធានការរបស់ក្រសួង គ្រប់ដណ្ដប់ទៅលើមុខរបរផ្សេងទៀត ឲ្យមានវិសាលភាពជាងនេះ។

"យើងជជែកច្រើនដែរ។ ដល់ហើយទៅក្រសួងឆ្លើយតបថា មុខរបរ១០ប្រភេទហ្នឹងសាកល្បងសិន។ នេះលើកទីមួយ គាត់ឆ្លើយមកបែបហ្នឹងអ្វីដែលយើងជជែក។ និយាយរួមទៅច្បាប់ហ្នឹងហាមតែអ្នករកស៊ីផ្ទាល់ខ្លួន បើគាត់មានក្រុមហ៊ុន ហើយចុះបញ្ជីត្រឹមត្រូវអត់អីទេ គាត់ធ្វើបាន"។

លោក វ៉ន់ ពៅ ប្រធានសមាគមឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ លោក វ៉ន់ ពៅ ទទូចឲ្យក្រសួងបញ្ចូលជនបរទេសដែលប្រកបរបរនៅក្នុងវិស័យសំណង់ ឲ្យដាក់បញ្ចូលទៅក្នុងបទប្បញ្ញត្តិហាមឃាត់សម្រាប់ជនបរទេសនេះផង។ លោក វ៉ន ពៅ ជម្រុញឲ្យក្រសួងអនុវត្តវិធានការឲ្យមានប្រសិទ្ធភាព។

"យើងឃើញថា វាហាក់ដូចជាមិនបានចំណេញអីទេ ហេតុអីបាននិយាយដូច្នេះពីព្រោះអ្នកធ្វើសរសៃនៅតាមមាត់ឆ្នេរតិចតួចទេ សំខាន់អ្នកបើកហាងម៉ាស្សានៅក្នុងខេត្តទាំងអស់។ នេះទើបជាការត្រឹមត្រូវ និងស៊ីជម្រៅមានន័យថា សេចក្ដីប្រកាសរបស់ក្រសួងការងារធ្វើឲ្យវាស៊ីជម្រៅជាងនេះ វាជាការល្អ និងវាជាការប្រសើរ "។

បើតាម លោក ហេង សួរ តាមពិតប្រកាសរបស់ក្រសួងការងារនេះ មានទម្ងន់ទៅលើតែមុខរបរស្វ័យនិយោជន៍ ឬសេដ្ឋកិច្ចក្រៅប្រព័ន្ធប៉ុណ្ណោះ។ លោកថា ជនបរទេសបម្រើការនៅតាមសហគ្រាស និងគ្រឹះស្ថានគឺអនុវត្តទៅតាមច្បាប់ស្ដីពីការងារ។

លោក ស្រេង វិន់លី ជាអ្នកសម្របសម្រួលអង្គការលីកាដូប្រចាំខេត្តព្រះសីហនុ។ លោកទទូចទៅរដ្ឋាភិបាលឲ្យពិនិត្យពីមុខរបរ

និងតម្រូវការរបស់ពលរដ្ឋក្នុងខេត្តដើម្បីបង្កើនការទទួលបានផលប្រយោជន៍សម្រាប់ពលរដ្ឋខ្មែរ។

**" បើយើងមិនបានកំណត់ទេ នៅថ្ងៃអនាគតប្រហែលជាខ្សត់ទៅៗនូវប្រជាពលរដ្ឋខ្មែរយើងដែលគាត់ប្រកបរបររកស៊ីនៅខេត្តព្រះសីហនុហ្នឹង។ ទី១ប្រជាពលរដ្ឋខ្មែរមិនមានលទ្ធភាពជួលទីតាំង និងទី២ប្រជាពលរដ្ឋបានចាកចេញបណ្ដើរៗ ខ្លះគាត់ជួលឲ្យគេទៅ ហើយខ្លះទៀតមិនមានលទ្ធភាពក្នុងការជួល "។**

លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ប្រាប់ថា ក្រសួងនឹងពិនិត្យមើលលើការងារស្វ័យនិយោជន៍ ឬការងារសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ លោកបញ្ជាក់ថា ប្រសិនបើរកឃើញពិតជាមានមែន នឹងអនុវត្តដូចមានកំណត់នៅក្នុងសេចក្ដីប្រកាសរបស់ក្រសួង។



*សំណង់អគារធំៗរបស់ក្រុមហ៊ុនចិន កំពុងសង់លើដីរាប់សិបហិកតា នៅឆ្នេរអូរត្រេះ ក្រុងព្រះសីហនុ*

លោក ង៉ែត ជូ អ្នកឯកទេសផ្នែកហិរញ្ញវត្ថុ និងការវិនិយោគ។ សម្រាប់លោក ង៉ែត ជូ ការកើនឡើងយ៉ាងឆាប់រហ័សផ្នែកសេដ្ឋកិច្ចក្នុងខេត្តព្រះសីហនុនៅពេលនេះនឹងមិនមានស្ថេរភាពរយៈពេលវែងឡើយ។ លោកនិយាយថា សន្ទុះសេដ្ឋកិច្ចរបៀបនេះ អាចនឹងមានឱនភាពចុះទៅវិញនៅចន្លោះពី ៣ ទៅ៥ឆ្នាំក្រោយ គឺក្នុងពេលសកម្មភាពសាងសង់ត្រូវបានកាត់បន្ថយ។

**"ទៅមុខទៀតយើងក៏ត្រូវប្រុងប្រយ័ត្នដែរ ពីព្រោះការសាងសង់កាស៊ីណូមិនចេះតែសាងសង់រហូតទេ។ កាលណាវាគ្រប់ចំនួន ឬក៏ដល់ដំណាក់កាលមួយឈប់សាងសង់គឺវាត្រូវទាក់ទងនឹងការចូលរួមចំណែកនៅក្នុងវិស័យកាស៊ីណូហ្នឹងវិញ។ បងប្អូនគាត់អាចធ្វើការក្នុងវិស័យហ្នឹង កូនចៅគាត់អាចធ្វើការក្នុងវិស័យហ្នឹង។ អ៊ីចឹងវាត្រូវការជំនាញ និងបទពិសោធន៍មួយផ្សេងទៀត"។**

ទោះយ៉ាងណា ក្នុងបទសម្ភាសន៍ជាមួយអ្នកយកព័ត៌មាន លោក ឃាង ភារម្យ អ្នកនាំពាក្យសាលាខេត្តព្រះសីហនុ ឲ្យដឹងថា សព្វថ្ងៃមុខរបរខ្នាតតូចដែលជនបរទេសប្រកបអាជីវកម្មនេះ ត្រូវបានកាត់បន្ថយជាងមុនច្រើនហើយ។

លោក ឃាង ភារម្យ និយាយថា អាជ្ញាធរនឹងចុះផ្សព្វផ្សាយអំពីគោលការណ៍ច្បាប់បន្ថែមដល់ជនបរទេស ដើម្បីឲ្យប្រាកដថា បញ្ហានេះ[ជនបរទេសដែលបើកមុខរបរដែលស្ថិតក្នុងលក្ខខណ្ឌហាមឃាត់]នឹងលែងកើតមានតទៅទៀត៕

## ៣. អតីតសមាជិកព្រឹទ្ធសភាបក្សកាន់អំណាចជំរុញគម្រោងវិនិយោគតំបន់ឆ្នេរបំពានលើសហគមន៍នេសាទនៅកំពត



*ប្រជានេសាទនៃសហគមន៍នេសាទព្រែកត្នោត ក្នុងស្រុកទឹកឈូ ខេត្តកំពត កំពុងរៀបចំចុះទូកនេសាទ*

ស្ថិតនៅជាប់នឹងព្រំប្រទល់ស្រុកវាលរេញរបស់ខេត្តព្រះសីហនុ និងមានចម្ងាយប្រហែល ៣០គីឡូម៉ែត្រ ភាគខាងលិចទីក្រុងកំពត ព្រែកត្នោត និងត្រពាំងរពៅ គឺជាសហគមន៍នេសាទសមុទ្រចំនួន ២ ស្ថិតក្នុងឃុំព្រែកត្នោត ហើយក៏ស្ថិតក្នុងចំណោមសហគមន៍នេសាទសរុប ៩ នៅក្នុងស្រុកទឹកឈូ របស់ខេត្តកំពត។

ក្រុមប្រជាពលរដ្ឋនៅក្នុងសហគមន៍នេសាទទាំងពីរ បានអះអាងថា របរនេសាទនៅសមុទ្រ បានជួយផ្តល់ចំណូលដល់ពួកគេ ដើម្បីឱ្យពួកគេមានជីវភាពរស់នៅសមរម្យ ប៉ុន្តែ គម្រោងអភិវឌ្ឍន៍ដែលវិនិយោគដោយ ក្រុមហ៊ុនឯកជនរបស់អតីតសមាជិកព្រឹទ្ធសភាមកពីគណបក្សប្រជាជនកម្ពុជា បានបង្កើតក្តីកង្វល់សម្រាប់ពួកគេនាពេលអនាគត។

សហគមន៍នេសាទត្រពាំងរពៅ ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០២ និងត្រូវបានចុះបញ្ជីទទួលស្គាល់ ដោយរដ្ឋាភិបាលនៅក្នុងឆ្នាំ២០០៩ ជាមួយវិសាលភាពគ្របដណ្តប់លើផ្ទៃសមុទ្រ ទំហំ ១,២៥១ហិកតា ពោលគឺគ្របដណ្តប់លើភូមិត្រពាំងរពៅ និងភូមិព្រែកគ្រែង។

ចំណែកឯសហគមន៍នេសាទព្រែកត្នោតវិញ ត្រូវបានបង្កើតឡើងកាលពីឆ្នាំ២០០២ ហើយត្រូវបានចុះបញ្ជីទទួលស្គាល់ដោយរដ្ឋាភិបាលនៅក្នុងឆ្នាំ២០១១ ជាមួយវិសាលភាពគ្របដណ្តប់លើផ្ទៃសមុទ្រសម្បូរទៅដោយព្រៃកោងកាងទំហំ ១,១៦៨ហិកតា។ ប្រជានេសាទខ្មែរឥស្លាមនៅសហគមន៍ព្រែកត្នោត លោក អ៊ួន រីម៉ា អាយុ ៤៦ឆ្នាំ បានប្រាប់ឱ្យដឹងថា ឪពុកម្តាយរបស់លោក និងរូបលោកផ្ទាល់ បានប្រកបរបរអួសអួនចាប់តាំងពីលោកធំដឹងក្តីមកម្ល៉េះ ហើយមុខរបរនេសាទមួយនេះ បានជួយឱ្យលោករកប្រាក់ចំណូលចន្លោះពី ៥ម៉ឺនរៀលទៅ ១២ម៉ឺនរៀលក្នុងមួយថ្ងៃ។

ចំណូលបានមកពីរបរនេសាទនេះ ជួយឱ្យលោក រីម៉ា មានលទ្ធភាពសាងសង់ផ្ទះ ១ខ្នង ទទឹងប្រហែល ៨ម៉ែត្រ និងបណ្តោយប្រហែល ១២ម៉ែត្រ ដែលសង់ឡើងពីថ្មស៊ីម៉ង់ត៍ និងមានតម្លៃប្រហែល ៣ម៉ឺនដុល្លារ។

លោក រីម៉ា ប្រាប់ថា៖ «យើងខ្ចីលុយធនាគារ ៥ពាន់ដុល្លារអាមេរិក ហើយគួបផ្សំគ្នាធ្វើហើយដល់ពេលនេះ។ យើងអាងនេសាទរាល់ថ្ងៃ ហើយរកបានចំណូលមកក្នុង ១ខែបង់ឱ្យគេម្តង។ ក្នុងមួយថ្ងៃៗ រកបានចន្លោះពី ៥ ទៅ ៦ម៉ឺនរៀល ឬ ១០ម៉ឺនជាងអ៊ីចឹងទៅហើយយើងសន្សំទុកបង់គេទៅ។ រួចបង់រំលោះទៅ យើងបាននៅហើយ»។

ប្រកបរបរអួសអួន និងឈឺប(ស្បៀមង) នៅក្នុងសហគមន៍នេសាទព្រែកត្នោត អ្នកស្រី យ៉េម សុខភា បានឱ្យដឹងថា ស្វាមីអ្នកស្រីអាចរកចំណូលបានចន្លោះពី ១០ ទៅ ២០ម៉ឺនរៀលក្នុងមួយថ្ងៃៗ ហើយថ្ងៃខ្លះ អាចរកបានរហូតដល់ទៅ ៥០ម៉ឺនរៀលក៏មានដែរតាមរយៈរបរនេសាទសមុទ្រនេះ។

ប្រជានេសាទរូបនេះ បានអះអាងថា របរនេសាទគ្រឿងសមុទ្រនេះ បានជួយលើកកម្ពស់គ្រួសាររបស់អ្នកស្រី ឱ្យមានជីវភាពប្រហាក់ប្រហែលនឹងប្រជាពលរដ្ឋដទៃទៀត នៅក្នុងសហគមន៍ផងដែរ។

អ្នកស្រី សុខភា ប្រាប់ថា៖ «ខ្ញុំធ្វើផ្ទះធ្វើអីហ្នឹង បានមកពីសមុទ្រទាំងអស់»។

ជាអ្នកប្រមូលទិញគ្រឿងសមុទ្រពីអ្នកភូមិជាច្រើនឆ្នាំមកហើយនោះ លោក សុខ ចិន្ដា ត្រូវបានប្រជានេសាទហៅថា «ឈ្មួញកណ្តាល»។ ឈ្មួលកណ្តាលរូបនេះ បានឱ្យដឹងថា លោកប្រមូលទិញគ្រឿងសមុទ្រពីអ្នកភូមិបានជិត ១០០គីឡូក្រាមក្នុង១ថ្ងៃៗ ប៉ុន្តែ ចំនួននេះធ្លាក់ចុះវិញមកនៅត្រឹមប្រហែល៥០គីឡូក្រាម ក្រោយរដូវវស្សាចូលមកដល់។

ឈ្មួញកណ្តាលរូបនេះ បានឱ្យដឹងថា លោកប្រមូលទិញបង្គាពីប្រជានេសាទតម្លៃ ៤ម៉ឺនរៀលក្នុង ១គីឡូក្រាមនៅថ្ងៃបុណ្យជាតិ ឬថ្ងៃឈប់សម្រាក ហើយទិញចូលតម្លៃជាង ៣ម៉ឺនរៀលក្នុង ១គីឡូក្រាមសម្រាប់ថ្ងៃធម្មតា។ ចំណែកឯមឹកវិញ លោក ចិន្ដាប្រាប់ថា លោកទិញពីប្រជានេសាទតម្លៃ ៣ម៉ឺនរៀលក្នុង ១គីឡូក្រាម។

លោក សុខ ចិន្ដា ប្រាប់ថា៖ «ជួនកាល គេយកមកលក់ដល់ផ្ទះ ហើយពេលខ្លះ ខ្ញុំទៅរកខ្លួនឯងបន្ថែម ទុកឱ្យប្រពន្ធខ្ញុំថ្លឹង។ ខ្ញុំមានឧបករណ៍របស់ខ្ញុំដែរ។ ខ្ញុំទៅសមុទ្រ ខ្ញុំអាចរកបានបន្ថែម ៥ ទៅ ៦ម៉ឺនទៀត។ ការយកចំណេញ វាអាស្រ័យលើគ្រឿងសមុទ្រវារស់ ឬក៏ងាប់។ បើរស់ យើងអាចចំណេញបាន ១គីឡូក្រាម ៥ពាន់ ឬ ៣ពាន់រៀលទៅតាមហាងឆេង»។

ប្រធានសហគមន៍នេសាទត្រពាំងរពៅ លោក ទិត្យ រិន

ឱ្យដឹងថា ប្រជាពលរដ្ឋប្រហែល៧០ភាគរយក្នុងចំណោមប្រជាជនសរុប ១១៧០គ្រួសារក្នុងភូមិត្រពាំងរពៅ និងភូមិព្រែកគ្រែង ប្រកបរបរនេសាទសមុទ្រ។

លោក ទិត្យ រិន ប្រាប់ថា៖ «ការលប់សមុទ្រទី១គឺវាប៉ះពាល់ដល់ជីវៈចម្រុះនៅក្នុងសមុទ្រ មានស្មៅសមុទ្រ មានផ្កាថ្ម មានព្រៃកោងកាង និងការនេសាទជាលក្ខណៈគ្រួសារ។ តាំងពីដូនតាគាត់មក ពួកគាត់រកតែកន្លែងហ្នឹង ហើយបើលុប តើឲ្យពួកគាត់ធ្វើអីវិញ។ ចំណូលដែលបានពីរបរនេសាទសមុទ្រនេះ ទី១ បានកូនរៀន ហើយមួយទៀតមិនមានអ្នកចំណាកស្រុក»។

ប្រធានសហគមន៍នេសាទព្រែកត្នោត លោក អ៊ុក សុវណ្ណឫទ្ធិ បានឱ្យដឹងថា ប្រជាសហ គមន៍របស់លោកចន្លោះពី ៧៥ ទៅ ៨០ភាគរយក្នុងចំណោមអ្នកភូមិជាង ៣០០គ្រួសារក៏ពឹងផ្អែកលើផលនេសាទសមុទ្រផងដែរ។

លោក អ៊ុក សុវណ្ណឫទ្ធិ ឱ្យដឹងថា ថ្វីត្បិតសមាជិកសហគមន៍មានចំនួនតិចតួចជាងគ្រួសារដែលមានជាក់ស្តែង ប៉ុន្តែលំហសមុទ្រនៃសហគមន៍របស់លោក បានផ្តល់ផលប្រយោជន៍ទាំងផ្ទាល់ និងដោយប្រយោលទៅដល់ប្រជានេសាទគ្រប់គ្នា។

របាយការណ៍ស្តីពីការចងក្រងសហគមន៍ បានឱ្យដឹងទៀតថា ជីវៈចម្រុះគ្រប់ប្រភេទ មាននៅក្នុងទឹកសមុទ្រនៃសហគមន៍ទាំងពីរនេះ ក្នុងនោះមានស្មៅសមុទ្រទំហំ ៥០០ហិកតា សារ៉ាយសមុទ្រ ផ្កាថ្ម និងព្រៃកោងកាង ដែលជាជម្រកពពួកបង្គា ក្តាម ត្រី មឹក ងាវ មឹកបំពង់ គ្រែង និងអយស្ទ័រជាដើម។

## ក្រុមហ៊ុន ជីង គ័រ ព្យាយាមជំរុញការវិនិយោគលើតំបន់ឆ្នេររំលោភលើសហគមន៍នេសាទ

សហគមន៍នេសាទទាំងពីរនេះ ត្រូវបានស្នើឡើងសម្រាប់ធ្វើការអភិវឌ្ឍទៅជាកំពង់ផែ មណ្ឌលលម្ហែកាយ និងតំបន់សេដ្ឋកិច្ចពិសេស ដែលសំណើនោះត្រូវបានធ្វើឡើងដោយក្រុមហ៊ុន ជីងគ័រ អ៊ីមផត អិចផត (Ching Kor Import & Export Co. Ltd) ចាប់តាំងពីខែកញ្ញា ឆ្នាំ២០១២មក។

បើតាមបញ្ជីការនៅក្រសួងពាណិជ្ជកម្ម ក្រុមហ៊ុនឯកជនមួយនេះ ស្ថិតក្រោមការកាន់កាប់របស់អ្នកស្រី កែវ ម៉ាលី អតីតសមាជិកព្រឹទ្ធសភារបស់គណបក្សប្រជាជនកម្ពុជា នៅចន្លោះពីឆ្នាំ២០១២ រហូតដល់ចប់អាណត្តិនៅឆ្នាំ២០១៨ និងជាអនុប្រធានសភាពាណិជ្ជកម្មកម្ពុជាផងដែរ។

ក្រុមហ៊ុន ជីង គ័រ បានដាក់លិខិតជាបន្តបន្ទាប់ទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងរដ្ឋបាលខេត្តកំពត ដើម្បីស្នើសុំបូមដីចាក់បំពេញតំបន់ឆ្នេរសមុទ្រទំហំដល់ទៅ ៦៤០ហិកតា ស្ថិតនៅភូមិត្រពាំងរពៅ និងភូមិព្រែកគ្រែង ស្ថិតក្នុងឃុំព្រែកត្នោត ដើម្បីពង្រីកតំបន់អភិវឌ្ឍន៍បង្កើតទៅជាកំពង់ផែ និងតំបន់សេដ្ឋកិច្ចពិសេស។

ក្រុមហ៊ុននេះ បានស្នើសុំចាក់ដីបំពេញបន្ថែមបែបនេះដើម្បីពង្រីកផ្ទៃដីបន្ថែមលើផ្ទៃដីទំហំ ៣០ហិកតា ដែលក្រុមហ៊ុននេះបានកាន់កាប់ និងបានវិនិយោគរោងចក្រម៉ាស៊ីនកិនស្រូវខ្នាតអន្តរជាតិ និងកំពង់ផែរួចមកហើយចាប់តាំងពីឆ្នាំ២០១៧មក។

ប៉ុន្តែ ផែនទីជាឧបសម្ព័ន្ធដែលត្រូវបានភ្ជាប់ជាមួយសំណើផ្ញើទៅក្រសួងរៀបចំដែន នគរូបនីយកម្ម និងសំណង់ កាលពីខែកញ្ញាឆ្នាំ២០១២ បង្ហាញថា ក្រុមហ៊ុនមួយនេះ បានស្នើបូកដីចាក់លុបឆ្នេរសមុទ្រនៅប្លុក A និងប្លុក B សរុបបញ្ចូលគ្នាមានទំហំដល់ទៅ ១,០០០ហិកតា។

ប្រធាននេសាទខ្មែរឥស្លាមនៅភូមិត្រពាំងរពៅ លោក លិស ឡះ បានលើកឡើងថា សហគមន៍នេសាទទាំងពីរនេះ នឹងបាត់បង់ទាំងស្រុង ប្រសិនបើសំណើសុំចាក់ដីលុបឆ្នេរសមុទ្ររបស់ក្រុមហ៊ុន ជីងគ័រ ត្រូវបានរដ្ឋាភិបាល និងអាជ្ញាធរ អនុញ្ញាតនោះ។

លោក លិស ឡះ ប្រាប់ថា៖ «ទំហំដីរបស់សហគមន៍វាមាន ១,២៥១ហិកតា។ អ៊ីចឹង ទំហំដីដែលក្រុមហ៊ុនដាក់ពោងវាទយក គឺ ៦៤០ហិកតា ប៉ុន្តែ បើយើងពិនិត្យទៅលើផ្ទៃទាំង ១,២៥១ហិកតា អស់រលីងហ្មង អស់រលីងហ្មង។ ដូច្នេះ អ្នកនេសាទតូចៗទៅនេសាទលែងកើតហើយ»។

មេឃុំព្រែកត្នោត លោក គង់ ប៊ុនរ៉ា ឱ្យដឹងថា អាជ្ញាធរមូលដ្ឋាន មិនមានសិទ្ធិក្នុងការសម្រេចទេថា ត្រូវវិនិយោគ ឬក៏អត់នោះទេ ប៉ុន្តែ លោកបន្តថា មកដល់ដំណាក់កាលនេះ ភាគីពាក់ព័ន្ធកំពុងសិក្សាពីផលប៉ះពាល់ជាមុនសិន។

លោកឱ្យដឹងថា៖ «យើងបានធ្វើវេទិកាសាធារណៈហើយដែរជាមួយប្រជាពលរដ្ឋ ប៉ុន្តែក្រុមហ៊ុនមិនទាន់បានចាប់ផ្តើមវិនិយោគនៅឡើយទេ»។

អ្នកស្រី កែវ ម៉ាលី បានដាក់លិខិត ១ច្បាប់កាលពីចុងខែកក្កដាក្នុងឆ្នាំនេះ ដោយបានស្នើសុំការគាំទ្រពីចៅហ្វាយខេត្តកំពតទៅលើគម្រោងវិនិយោគរបស់ក្រុមហ៊ុនឱ្យបានឆាប់។

អ្នកស្រីបញ្ជាក់ថា ការស្នើសុំដូចនេះ ព្រោះប្រជាពលរដ្ឋបានបើកផ្លូវឱ្យក្រុមហ៊ុនចូលវិនិយោគ ហើយតាមរយៈការរំកិលសហគមន៍ទៅតំបន់ផ្សេង។

ប្រធានសហគមន៍ត្រពាំងរពៅ លោក ទិត្យ រីនច្រានចោលការអះអាងរបស់អ្នកស្រី កែវ ម៉ាលី ហើយលោកបញ្ជាក់ថា មានអ្នកភូមិចន្លោះពី ២០ ទៅ ៣០នាក់ប៉ុណ្ណោះ ក្នុងនោះមានទាំងអាជ្ញាធរមូលដ្ឋានផងដែរ បានផ្តិតមេដៃយល់ព្រម ដែលលោកចាត់ទុកថាមិនមែនជាក្រុមតំណាងឱ្យសហគមន៍នោះឡើយ។ លោក រីនអះអាងបន្ថែមថា អ្នកដែលយល់ព្រមទាំងនោះ គឺជាអ្នកដែលគេទិញទឹកចិត្តបានប៉ុណ្ណោះ។

លោកបញ្ជាក់ថា៖ «គ្មានពីណាគេព្រមព្រៀងទេ ប៉ុន្តែដូចខ្ញុំថា អញ្ចឹង គឺទី១ អាជ្ញាធរគេគាប់សង្កត់ និងហាមឃាត់អស់ហើយ និងទី២ យកលោក ឈាង វុន ទៅសម្លុតពួកគាត់។ ដូច្នេះ មិនដឹងធ្វើម៉េចទេ មានតែដោះយកតែមួយរួចខ្លួនប៉ុណ្ណោះ ហើយវេទិកាប៉ុន្មានកន្លែងប្រជាពលរដ្ឋមិនដែលព្រមទេ»។

សមាជិកសភាគណបក្សប្រជាជនកម្ពុជា លោក ឈាង វុន បានច្រានចោលការចោទប្រកាន់ថា លោកបានគំរាមកំហែងទៅលើប្រជាពលរដ្ឋនៅក្នុងសហគមន៍នេសាទទាំងពីរនោះ ដោយលោក អះអាងថា វត្តមានរបស់លោកជាមួយអ្នកស្រី កែវ ម៉ាលី នៅឯសហគមន៍នោះ គ្រាន់តែជាដំណើរកម្សាន្តលក្ខណៈឯកជនតែប៉ុណ្ណោះ។

សមាជិកសភាបក្សកាន់អំណាចរូបនេះ បានទទួលស្គាល់ថា លោកបានចូលរួមស្តាប់កិច្ចពិភាក្សារវាងតំណាងប្រជាពលរដ្ឋ និងតំណាងភាគីក្រុមហ៊ុន ជឹង គ័រ ប៉ុន្តែ លោកបដិសេធថា លោកមិនជាប់ពាក់ព័ន្ធនឹងគម្រោងវិនិយោគរបស់អ្នកស្រី កែវ ម៉ាលី នៅទីនោះទេ។

លោក ឈាង វុន ប្រាប់ថា៖ «បើសិនជាគាត់មានចិត្តវិនិយោគដូចដែលគាត់បានជជែកគ្នាជាមួយប្រជាពលរដ្ឋ និងផ្តិតមេដៃជាមួយប្រជាពលរដ្ឋា អាហ្នឹង ខ្ញុំអរណាស់ បើគាត់ធ្វើបាន ហើយសន្យាជាមួយប្រជាពលរដ្ឋស្អីហ្នឹង។ អាហ្នឹង ខ្ញុំអង្គុយស្តាប់ទេ ហើយខាងក្រសួងក៏បានពិភាក្សាជាមួយគាត់ (អ្នកស្រី កែវ ម៉ាលី) តាមខ្ញុំឮនៅថ្ងៃដែលជជែកគ្នាជាមួយប្រជាពលរដ្ឋ»។

ចំណែកឯអ្នកស្រី កែវ ម៉ាលី អះអាងថា ខាងក្រុមហ៊ុនរបស់អ្នកស្រីមិនបានបង្ខំឱ្យប្រជាពលរដ្ឋផ្តិតមេដៃទេ។ អ្នកស្រី ម៉ាលី លើកឡើងថា អ្នកដែលយល់ព្រមទាំងអស់នៅក្នុងបញ្ជីវត្តមាន ក្នុងកិច្ចប្រជុំ និងពិគ្រោះយោបល់កាលពីខែកក្កដា ឆ្នាំ២០១៩ គឺសុទ្ធតែយល់ព្រម និងឯកភាពដោយស្ម័គ្រចិត្ត។

អ្នកស្រី កែវ ម៉ាលី ប្រាប់ថា៖ «មានតែមួយចំនួនទេ វាទៅចាក់រុកចាក់ដោតគេយកលេសថា ប្រជាជនមិនព្រម។ យើងសួរថា បើប្រជាជនមិនព្រម ខ្ញុំបានមេដៃមកពីណា ហើយមេដៃទាំងអស់ហ្នឹង ខ្ញុំឱ្យពួកគាត់ផ្តិតខ្លួនឯង។ ខ្ញុំឱ្យពួកគាត់ផ្តិត ហើយខ្ញុំនៅនឹងមុខ ហើយថតរូបទុកទៀត ហើយខ្ញុំថា តិចប្រកែកថា អត់ផ្តិត ហើយហៅប៉ូលិសពីក្រសួងមហាផ្ទៃឱ្យមកពិនិត្យម្រាមដៃ»។

សេចក្តីប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចេញកាលពីខែ មេសាឆ្នាំ២០១៩ ស្តីពីការបង្កើតតំបន់គ្រប់គ្រងជលផលសមុទ្រ ក្នុងខេត្តកំពតកំណត់ថា បទប្បញ្ញត្តិនេះ ធ្វើឡើងដើម្បីការពារ អភិរក្ស និងប្រើប្រាស់ធនធានជលផលសមុទ្រដោយនិរន្តរភាព។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លោក វេង សាខុន បានលើកឡើងថា ក្រសួងរបស់លោកបានផ្ដួចផ្ដើមឱ្យមានសហគមន៍នេសាទនៅតាមតំបន់ឆ្នេរដើម្បីចូលរួមអភិរក្សសមុទ្រ ប៉ុន្តែ លោកថា លោកទើបតែបានដឹងពីគម្រោងវិនិយោគរបស់ក្រុមហ៊ុន ជឹងតំរ កាលពីពេលថ្មីៗនេះប៉ុណ្ណោះ។

រដ្ឋមន្ត្រីរូបនេះ ប្រាប់ថា ស្ថាប័នរបស់លោក មិនមានមធ្យោបាយណាមួយដើម្បីទប់ស្កាត់ការអភិវឌ្ឍនោះឡើយ ហើយលោកថា លោកអាចមានសិទ្ធិត្រឹមតែឯកភាពប៉ុណ្ណោះ ហើយក៏មិនចង់ប្រកួតប្រជែងអ្វីនោះដែរ។

លោក វេង សាខុន ប្រាប់ថា៖ «គេសម្រេចទៅហើយ គេជាអ្នកបរិស្ថាន និងអ្នកគេរៀបចំដែនដី គេយល់ឃើញថា នេះជាការអភិវឌ្ឍន៍។ អ៊ីចឹង គេជំរុញការអភិវឌ្ឍ ប៉ុន្តែ ចំពោះខ្ញុំ ខ្ញុំមិនដឹងនិយាយថាម៉េច។ ចំពោះខ្ញុំ បើគេសម្រេចហើយ ខ្ញុំចេះតែសម្របសម្រួលហើយ។ គេប្រើឱ្យធ្វើអីធ្វើទៅ ធ្វើតាមគេទៅ»។

របាយការណ៍របស់គណៈកម្មាធិការជាតិ គ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រកម្ពុជា ចេញកាលពីខែ មករា ឆ្នាំ២០១៩ ហាមគ្រប់រូបភាពចំពោះការគ្រប់គ្រងដីនៅតាមឆ្នេរសមុទ្រ។

ប្រកាសនេះ បានកំណត់ថា ដីចំណីឆ្នេរ ដីចំណីដៃសមុទ្រ ស្ទឹង ព្រែក និងផ្លូវទឹកដែលតភ្ជាប់ទៅសមុទ្រ អាជ្ញាធរនៅជាប់មាត់សមុទ្រត្រូវទប់ស្កាត់ និងការទន្ទ្រានកាប់កាប់ដីសាធារណៈ។

រដ្ឋមន្ត្រីក្រសួងរៀបចំដែន នគរូបនីយកម្ម និងសំណង់ លោក ជា សុផារ៉ា បានប្រាប់ថា លោកជាប់រវល់នៅពេលត្រូវបានសាកសួរថា តើមានមូលហេតុអ្វីបានជាក្រសួងលោកសម្រេចផ្ដល់សិទ្ធិវិនិយោគទៅឱ្យក្រុមហ៊ុន ជឹងតំរបូមដីចាក់លុបឆ្នេរសមុទ្រនោះ។

លោក ជា សុផារ៉ា បានប្រាប់ថា៖ «ខ្ញុំជាប់រវល់តិច។ សួរគេទៀតសិនទៅ ខ្ញុំជាប់រវល់ខ្លាំងណាស់»។

លោក វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឱ្យដឹងថា តាមពិតការផ្ដល់សិទ្ធិវិនិយោគឱ្យក្រុមហ៊ុនជឹងតំរលុបសមុទ្រ ដើម្បីអភិវឌ្ឍនេះ គឺជាការសម្រេចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)។ លោកបន្តថា សម្រាប់ក្រសួងកសិកម្មវិញ មានសិទ្ធិត្រឹមអនុវត្តតាមលិខិតដែលមានស្រាប់ ដែលចេញដោយក្រសួងពាក់ព័ន្ធប៉ុណ្ណោះ។

វីអូឌី បានដាក់លិខិតស្នើសុំការពន្យល់ពីមន្ត្រីតំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាផងដែរ ប៉ុន្តែ គ្មានការឆ្លើយតបណាមួយពីស្ថាប័ននេះនោះឡើយរហូតមកដល់ពេលចេញផ្សាយអត្ថបទនេះ។

## ប្រជានេសាទជំទាស់នឹងគម្រោងអភិវឌ្ឍន៍របស់អតីតសមាជិកព្រឹទ្ធសភាបក្សកាន់អំណាច

អ្នកស្រី កែវ ម៉ាលី បានអះអាងថា ក្រុមហ៊ុនអ្នកស្រីទទួលបានអាជ្ញាប័ណ្ណសម្រាប់ការវិនិយោគលើតំបន់ឆ្នេរសមុទ្រនោះរួចមកហើយ ហើយក្រុមហ៊ុននឹងចាប់ផ្ដើមអភិវឌ្ឍន៍ក្នុងពេលឆាប់ៗខាងមុខនេះ បន្ទាប់ពីការសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមរួចមកហើយនោះ។

អតីតសមាជិកព្រឹទ្ធសភាបក្សកាន់អំណាចរូបនេះបានប្រាប់បន្តថា ដំណើរការអភិវឌ្ឍមានភាពយឺតយ៉ាវមកដល់ពេលនេះ ព្រោះអ្នកបច្ចេកទេសនៃការវិនិយោគ កំពុងសិក្សាពីផ្លូវគន្លងនាវាចរណ៍ត្រូវធ្វើយ៉ាងណាអនុវត្តទៅកុំឱ្យមានផលប៉ះពាល់ដល់ជីវៈចម្រុះនៅក្នុងសមុទ្រ។

អ្នកស្រី ម៉ាលី ប្រាប់ថា៖ «ច្បាប់រដ្ឋ គេតឿនរាល់ថ្ងៃហើយឱ្យធ្វើ ហើយយើងក៏ត្រូវគិតឱ្យច្បាស់លាស់ ត្រូវសិក្សាយ៉ាងម៉េចត្រូវធ្វើទំនប់យ៉ាងម៉េចកុំឱ្យទឹកវាល្អក់។ យើងធ្វើឱ្យច្បាស់លាស់ព្រោះយើងស្រលាញ់ជាតិយើង មិនមែនស្រលាញ់តែមាត់ទេ»។

បើទោះជាបែបក្ដីនេះ ប្រធានសហគមន៍ព្រែកត្នោត លោក អ៊ុក សុវណ្ណឫទ្ធិ ថ្លែងថា ប្រជាពលរដ្ឋមិនដែលបានដឹងព័ត៌មានស្ដីពី

ការសិក្សាហេតុប៉ះពាល់បរិស្ថាន និងសង្គមណាមួយទេ។

លោកបន្តថា មកទល់ពេលនេះ ប្រជាពលរដ្ឋទើបជួបក្រុមហ៊ុន បាន ២ដងប៉ុណ្ណោះ តាមរយៈវេទិកាសម្តែងមតិនៅក្នុងសហគមន៍ ប៉ុន្តែ តំណាងសហគមន៍រូបនេះ អះអាងថា ជំនួបទាំង២លើកនេះ ប្រជាពលរដ្ឋបានជំទាស់មិនឱ្យក្រុមហ៊ុនចូលទៅអភិវឌ្ឍន៍ទេ។

លោក អ៊ុក សុវណ្ណឫទ្ធិ ប្រាប់ថា៖ «ប្រជានេសាទនៅក្នុងសហគមន៍ ក៏ពួកគាត់មិនយល់ព្រមដែរ។ វេទិកាសាធារណៈពីរដងហើយ បានលើកឡើង។ ប្រជាពលរដ្ឋនិយាយថា មិនយល់ព្រមឱ្យមានការអភិវឌ្ឍទេ ឬចាក់ដីចូលក្នុងសហគមន៍ទេ»។

បើតាមផែនការវិនិយោគរបស់ក្រុមហ៊ុន ដែលវីអូឌីមើលឃើញ ក្រុមហ៊ុនជីងត័រ បានស្នើសុំវិនិយោគលើគម្រោងអភិវឌ្ឍន៍ «មហាសមុទ្រទេសចរណ៍កំពត» ដែលមានតម្លៃវិនិយោគដល់ទៅជាង ១,៥០០លានដុល្លារ សម្រាប់រយៈពេល ៥០ឆ្នាំ។

អ្នកស្រី កែវ ម៉ាលី បានអះអាងថា គម្រោងវិនិយោគរបស់ក្រុមហ៊ុនអ្នកស្រី មានគោលបំណងបង្កើតការងារសម្រាប់ប្រជាពលរដ្ឋមូលដ្ឋាន និងជួយជំរុញកំណើនសេដ្ឋកិច្ចប្រជាជនឱ្យប្រសើរជាងមុន ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រតាមគោលនយោបាយរបស់រដ្ឋាភិបាលផងដែរ។

អ្នកស្រី កែវ ម៉ាលី ប្រាប់វីអូឌីថា៖ «ខ្ញុំចង់បានឆាប់ណាស់ ដើម្បីឱ្យប្រជាជនខ្ញុំមានការងារធ្វើ ហើយបានប្រាក់ខែច្រើន។ ខ្ញុំខ្មែរ ខ្ញុំចង់ឱ្យខ្មែរខ្មាងឯងមានលុយមានកាក់ទៅណា ហើយឱ្យវាធូរជាទៅ ហើយកូនទៅរៀន មកវិញអាចមានការងារធ្វើ ហើយកាលណាក្រុមហ៊ុនខ្ញុំមានបរទេសវិនិយោគ និងសហការគ្នា មានគ្រប់ជាតិសាសន៍ ម្នាក់តិចៗទៅ ប្រជាជននៅម្តុំហ្នឹងមានប្រាក់ខែច្រើន និងមានការងារធ្វើដែរ»។

ពលរដ្ឋនៅសហគមន៍នេសាទទាំងពីរនេះ បានជំទាស់ទៅនឹងគម្រោងអភិវឌ្ឍន៍នេះ ហើយពួកគេព្រួយបារម្ភថា ប្រាក់ចំណូលរបស់ពួកគេដែលរកបានពីរបរនេសាទនោះ អាចនឹងធ្លាក់ចុះ ហើយប៉ះពាល់ដល់កម្រិតជីវភាពរស់នៅរបស់ពួកគេនាពេលអនាគត។

លោក អ៊ុក សុវណ្ណរិទ្ធ បានឱ្យដឹងថា ក្រុមហ៊ុន ជីងត័រ របស់អ្នកស្រី កែវ ម៉ាលី បានព្យាយាមចូលទៅធ្វើសកម្មភាពចំនួន ២លើករួចមកហើយ ដើម្បីកាន់កាប់ផ្ទៃសមុទ្ររបស់សហគមន៍ទាំងពីរ ប៉ុន្តែប្រជានេសាទ បានរារាំងជំទាស់ទៅនឹងសកម្មភាពរបស់បុគ្គលិកកម្មកររបស់ក្រុមហ៊ុននេះ។

តំណាងសហគមន៍រូបនេះ បានឱ្យដឹងបន្ថែមថា បុគ្គលិកកម្មកររបស់ក្រុមហ៊ុន ជីងត័រ បានដាក់ពង្រាយពោងនៅលើផ្ទៃទឹកសមុទ្រលើកដំបូងនៅឆ្នាំ២០១៥ និងនៅក្រោយការបោះឆ្នោតជាតិកាលពីឆ្នាំ២០១៨ ប៉ុន្តែ សកម្មភាពហ៊ុំព័ទ្ធសមុទ្រពីសំណាក់ក្រុមហ៊ុនមួយនេះ ត្រូវបានផ្អាកទៅវិញ បន្ទាប់ពីប្រជានេសាទជំទាស់តវ៉ា។

ប្រជានេសាទនៅភូមិត្រពាំងរពៅ លោក សុខ មួចបានលើកឡើងថា មិនត្រឹមតែជីវភាពប្រជាពលរដ្ឋទេដែលរងផលប៉ះពាល់ ប៉ុន្តែជីវៈចម្រុះក្នុងសមុទ្ររួមទាំងត្រី និងបង្គារជាដើម ក៏នឹងប្រឈមមុខនឹងការបាត់បង់ផងដែរ ប្រសិនបើគម្រោងលុបសមុទ្រដើម្បីអភិវឌ្ឍទៅជាតំបន់រីសតនេះកើតឡើងមែននោះ។

លោក សុខ មួច រៀបរាប់ថា៖ «វាលំបាកដែរ បើគេលុបសមុទ្រទៅ សូម្បីត្រីសាច់អីក៏អត់មានដែរ ហើយបើយើងទៅរកស៊ីក្រៅ បើសិនជាលុបហើយ ៣ឆ្នាំមិនដឹងជាមានត្រីអត់ផង។ វាស្អុយជាតិដីហើយហួរ គឺត្រីវាថយអស់ វាអត់មានហ៊ានចូលទេ។ ត្រីទឹកប្រៃអត់ដូចត្រីទឹកសាបទេ។ ត្រីទឹកសាបបើត្រីផ្ទក់នៅហ្នឹងយើងចាក់ដីវានៅហ៊ានមក។ ត្រីទឹកប្រៃបើយើងចាក់ដីវាធំក្លិនជាតិដីវាថយអស់ហើយ។ វាអត់មានហ៊ានមកទេ»។

លោក ឡឹម សុខុន សមាជិកគណៈកម្មការបណ្តាញសហគមន៍ព្រែកត្នោតលើកឡើងថាប្រសិនបើគម្រោងរបស់ក្រុមហ៊ុនជោគជ័យមែន ប្រជាពលរដ្ឋមិនដឹងជាត្រូវធ្វើអ្វីនោះទេ។ លោកបន្តថា ភាគច្រើនលើសលប់នៃប្រជាពលរដ្ឋរស់តាមមាត់សមុទ្រនេះ ពឹងផ្អែកទាំងស្រុងលើរបរនេសាទ ហើយមានប្រមាណ ១០ភាគរយ

ប៉ុណ្ណោះ ជាគ្រូបង្រៀន កម្មកររោងចក្រ និងជាមន្ត្រីរាជការ។

លោក សុខុន ឱ្យដឹងទៀតថា ពួកគេមិនព្រមធ្វើការឱ្យក្រុមហ៊ុនទេ ព្រោះប្រាក់ខែបានតិច ហើយមិនមានពេលសម្រាកដូចរបរនេសាទ។ លើសពីនេះទៀត លោកជឿជាក់ថា មនុស្សវ័យចំណាស់មួយចំនួន ក្រុមហ៊ុនមិនទទួលឱ្យចូលធ្វើការឡើយ។ ហេតុផលនេះហើយដែលលោក ឡឹយ សុខុនអះអាងថា ពួកគេនឹងមិនព្រមប្រគល់សមុទ្រធ្លាប់នេសាទឱ្យទៅក្រុមហ៊ុនវិនិយោគនោះឡើយ។

លោក ឡឹយ សុខុន ប្រាប់ថា៖ «សូម្បីចំណូលខែ ក៏តិចជាងយើងរកខ្លួនឯង ជាងធ្វើខ្ញុំប្រពន្ធផង។ ធ្វើខ្ញុំប្រពន្ធចង់ទៅៗ មិនចង់ទៅដេកមួយថ្ងៃ ឬពីរថ្ងៃក៏អត់បញ្ហា។ គ្មានពីណាកាត់លុយយើង។ ជាក់ស្តែងដូចចាស់ៗ ចាស់ៗស្រី គាត់ទៅរាវគ្រែងរាវងាវ រើសនេះរើសនោះនូវផលសមុទ្រហ្នឹង យើងចេះតែបានមកដោះស្រាយ ដូចជា រាវគ្រែងឈាមបានត្រឹមតែ ២គីឡូ ៥ម៉ឺនរៀលហើយ ហើយចាស់ៗដូចខ្ញុំអាយុ ៦០ឆ្នាំជាងទៅហើយ ពីណាគេយកទៅធ្វើការ។ គ្រាន់តែដើរជិត គេមិនឱ្យដើរជិតផង»។

ប្រធានគណៈកម្មការបណ្តាញតស៊ូមតិ នៃសហគមន៍នេសាទត្រពាំងរពៅ អ្នកស្រី ប៉ុន ញូ បានព្រមានថា អ្នកភូមិនឹងធ្វើចំណាកស្រុកទៅស្វែងរកការងារនៅប្រទេសដទៃ ប្រសិនបើគម្រោងលុបសមុទ្ររបស់សហគមន៍ កើតឡើងមែននោះ។

អ្នកស្រី ប៉ុន ញូ មានប្រសាសន៍ថា៖ «ខ្ញុំថា មានតែនេសាទនេះហើយដែលបានជួយបងប្អូនទាន់ពេលវេលា ហើយទីបំផុតវប្បធម៌ខ្មែរយើង យើងមានសមុទ្រ យើងមានតំបន់ឆ្នេរ យើងមានសត្វសមុទ្រ យើងមានដើមកោងកាងសម្រាប់ជួយយើងទាំងអស់គ្នា។ បើយើងឱ្យគេចាក់លុបបាត់បង់អស់ យើងមិនដឹងទៅពឹង ទៅរស់រាននៅណាទេ មុខតែចាកចេញពីភូមិ ពីស្រុកទៅធ្វើការប្រទេសគេ ប្រទេសឯង ហើយត្រូវចោលស្រុកចោលភូមិហើយ»។

លោក ប៊ិល កុសល អភិបាលរងខេត្តកំពត ឱ្យដឹងថា មកដល់ពេលនេះ ក្រុមហ៊ុននៅមិនទាន់ចាប់ផ្តើមវិនិយោគនៅឡើយទេ។

លោកបន្តថា ភាគីដែលពាក់ព័ន្ធរួមមានទាំងខាងក្រុមហ៊ុន និងអាជ្ញាធរកំពុងសិក្សាពីផលប៉ះពាល់ និងពិគ្រោះយោបល់ជាមួយពលរដ្ឋជាមុនសិន។

លោក កុសល លើកឡើងថា ការសិក្សានេះ ផ្តោតសំខាន់រឿងផ្លូវច្បាប់ ឱ្យស្របទៅនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ លោកបន្តថា ការវិនិយោគធ្វើយ៉ាងណាឱ្យស្របទៅនឹគោលការណ៍ច្បាប់ ហើយឱ្យពលរដ្ឋទទួលបានផលពីការវិនិយោគនេដែរ។

លោកបន្តថា៖ «ក្រុមហ៊ុនគេមិនទាន់អភិវឌ្ឍន៍ណាឡើយ។ ហ្នឹងហើយ ខាងក្រុមហ៊ុនគេមានច្បាប់ទម្លាប់អីអស់ហើយ តែក្រសួង និងក្រុមហ៊ុន កំពុងពិនិត្យមើលបន្ថែមទៀតពីនីតិវិធីច្បាប់ ដើម្បីធ្វើទៅកុំឱ្យមានបញ្ហា»។

មន្ត្រីសមាគមការពារសិទ្ធិមនុស្សអាដហុកប្រចាំខេត្តកំពត លោក យន់ ផល្លី បានប្រាប់ថា ប្រសិនបើរដ្ឋាភិបាល និងក្រុមហ៊ុន អាចបង្វែរទីតាំងនៃការវិនិយោគទៅតំបន់ផ្សេងក្រៅពីតំបន់សមុទ្រនេះវាជាការប្រសើរ។

លោក ផល្លី យល់ឃើញថា នៅក្នុងសមុទ្រនេះ បើវិនិយោគទៅ វាប៉ះពាល់ទៅលើស្មៅសមុទ្រ ផ្កាថ្មប៉ប្រះទឹក ជីវៈចម្រុះ សារ៉ាយសមុទ្រ និងព្រៃកោងកាង។ លោកបន្ថែមថា មិនតែប៉ុណ្ណោះ ផលប៉ះពាល់ជាវិជ្ជមានកាន់តែខ្លាំង គឺទៅលើមុខរបរនេសាទប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ផ្ទាល់។

លោកបន្តថា៖ «ប្រជាពលរដ្ឋដែលគាត់ធ្វើអាជីវកម្មជាលក្ខណៈគ្រួសារ គាត់នេសាទបានតែទឹករាក់ទេ ហើយបើយើងលុបតំបន់ឆ្នេរហ្នឹងចេញពីទឹករាក់ហើយ រួចឱ្យពួកគាត់ទៅទឹកជ្រៅវិញ គឺថាអាជីវកម្មរបស់ពួកគាត់នឹងត្រូវបាត់បង់ទាំងអស់»។

សេចក្តីប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចេញកាលពីខែ មេសាឆ្នាំ២០១៩ ស្តីពីការបង្កើតតំបន់គ្រប់គ្រងជលផលសមុទ្រក្នុងខេត្តកំពតកំណត់ថា បទប្បញ្ញត្តិនេះធ្វើឡើងដើម្បីការពារអភិរក្ស និងប្រើប្រាស់ធនធានជលផលសមុទ្រដោយនិរន្តរភាព។

ជាងនេះទៀត រួមចំណែកក្នុងការលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ។ គោលការណ៍ដែលក្រសួងកសិកម្មបានកំណត់នេះមានទិសដៅសំខាន់ៗរួមមាន៖ ១.កន្លែងអភិរក្សជលផលដែលចំណុចនេះ ក្រសួងបានកំណត់ផ្ទៃក្រឡាជិត ៧០០ហិកតា(៦៤៦)។ ២. កន្លែងការពារជលផលៈ ទីតាំងនេះមានផ្ទៃក្រឡាជាង៣ពាន់ហិកតា(៣០៩២)។ ៣. ដែនជម្រកសុវត្ថិភាពជលផលៈ មានផ្ទៃដីសរុប ៣១៦ហិកតា។ ៤. ទីតាំងអេកូទេសចរណ៍បាតសមុទ្រៈមានផ្ទៃក្រឡា ៧៤ហិកតា។៥ទីតាំងសហគមន៍នេសាទៈ ទីតាំងនេះមាន៣កន្លែងស្មើផ្ទៃក្រឡាសរុបជាង៤ពាន់ហិកតា(៤៣៥៨)។

ដោយឡែក សេចក្ដីប្រកាសរបស់រដ្ឋាភិបាលចេញកាលពីខែកុម្ភៈ ឆ្នាំ២០១២ កំណត់ពីតំបន់ឆ្នេរសមុទ្រ។

ប្រកាសនេះឱ្យដឹងថា ការចាត់ទុកជាឆ្នេរសមុទ្រ ត្រូវកំណត់ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតនៃទឹកសមុទ្រឡើងមកលើ រហូតដល់ខ្សែបន្ទាត់ហាមឃាត់។

សេចក្ដីប្រកាសបញ្ជាក់ថា ការវិនិយោគត្រូវហាមឃាត់ រួមមានការកាន់កាប់ ឬសាងសង់នានាជាថ្មី ឬខ្សាច់ដែលបានកំណត់ទុកជាតំបន់សម្រាប់ប្រើប្រាស់ជាសាធារណៈ និងចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ។ ទន្ទឹមនឹងនេះ ឆ្នេរជម្រាលត្រូវកំណត់យ៉ាងតិច ៣០ម៉ែត្រ ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតទៅខាងដីគោក៕

## ៤. ជនជាតិដើមភាគតិចព្នងនៅភូមិចក់ចារបាត់បង់ចំណូល ក្រោយក្រុមហ៊ុនវៀតណាមវិនិយោគទាំងភាពចម្រូងចម្រាស់

តំណាងសហគមន៍ចក់ចារ លោក ប្រប់ ជីប លើកឡើងថា ជនជាតិដើមភាគតិចព្នង ត្រូវធ្លាក់ចុះចំណូលនៅក្រោយពេលក្រុមហ៊ុនវៀតណាមឈ្មោះថា ប៊ិញភឿក១ ចូលមកអភិវឌ្ឍន៍។



មន្ត្រីនគរបាលនៅឃុំស្រែឈូក ស្ថិតក្នុងស្រុកកែវសីមា ខេត្តមណ្ឌលគិរី សាកសួរអ្នកយកព័ត៌មានវីអូឌី ដែលបានចុះសម្ភាសពលរដ្ឋជនជាតិដើមភាគតិចព្នង កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩។ (រូបថត៖ ជន ចាន់រ៉េន)

តំណាងសហគមន៍រូបនេះ ដែលមានវ័យ ៤១ឆ្នាំ ឱ្យដឹងថា សព្វថ្ងៃនេះ ជនជាតិដើមភាគតិចព្នង លែងមានចំណូលទៀតហើយ ពីដើមជ័រច្បោះនេះ **«គ្មានអីទេឥឡូវហ្នឹងមុខរបរស្អីក៏គ្មានដែរ។ ពីមុនយើងសង្ឃឹមរឿងដើមជ័រទឹក ជ័រចុង និងផ្ការអ៊ុកកាដេរ។ ឥឡូវនេះក៏អស់ដែរ»។**

បើតាមលោក ប្រប់ ជីប លើកឡើងថានៅមុនពេលក្រុមហ៊ុនចូលមកដល់ ក្រុមគ្រួសាររបស់លោកមានដើមជ័រច្បោះប្រមាណ ៥០០ដើម។ ក្នុងមួយខែៗ ក្រុមគ្រួសារលោកអាចរកចំណូលគិតជាមធ្យមចន្លោះពី ៤លានទៅ ៨លានរៀល(ខ្ទង់២០០០ដុល្លារ) ដែលទទួលបានពីអនុផលព្រៃឈើនេះ។

ស្ថិតក្នុងស្ថានភាពបែបនេះហើយដែលលោក ជីប បញ្ជាក់ថា ជនជាតិដើមភាគតិចព្នង រស់នៅដោយមិនព្រួយបារម្ភពីជីវភាពអ្វីឡើយ។

លោកបន្តថា៖ **«ខ្ញុំជួលគេឱ្យជួយដងជ័រទឹក ១ខែ អាចរកចំណូលបានជាង ២៥០០ដុល្លារ។ ប៉ុន្តែ ទូទាត់ការចំណាយ នៅសល់ប្រមាណជាង ១ពាន់ដុល្លារអីដែរ»។**

មិនមែនតែគ្រួសារលោក ប្រប់ ជីប ម្នាក់ទេដែលអាចរកចំណូលបានខ្ពស់ពីវិស័យជ័រច្បោះនេះ។ មានក្រុមគ្រួសារផ្សេងទៀតនៃជនជាតិដើមភាគតិចព្នង នៅភូមិចក់ចារ ឃុំស្រែឈូកនេះ ក៏មិនខុសគ្នាប៉ុន្មានដែរ។

តំណាងសហគមន៍ផ្សេងទៀត ដែលបានផ្ដល់សម្ភាសន៍បានឱ្យវីអូឌីដឹងថា ក្រៅពីដើមជ័រទឹកនេះ អនុផលព្រៃឈើដទៃទៀត

ដូជា ដកផ្សិត ដំរចុង និងផ្ការអកគេដេ ជាដើម ក៏ជាចំណូលបន្ថែមផងដែរសម្រាប់អ្នកភូមិផងដែរ។

លោក យ៉ិន សិង្ហ អាយុ ៣៥ឆ្នាំជាជនជាតិដើមភាគតិចព្នង ថ្លែងថា ក្រុមគ្រួសាររបស់ខ្លួនមានដើមជ័រច្បោះប្រមាណ២ពាន់ដើម។ តែជាអកុសល ដើមជ័រទឹកទាំងនោះមានជាងពាក់កណ្ដាលទៅហើយ ត្រូវបានក្រុមហ៊ុនឈូសឆាយផ្ដួលឱ្យរៀបដល់ដី។ លោក សឹង្ហ បន្តថានៅពេលដើមច្បោះទាំងនោះត្រូវបាត់បង់ ហើយតម្លៃក៏ធ្លាក់ចុះថែមទៀត ធ្វើឱ្យក្រុមគ្រួសារលោកត្រូវជួបបញ្ហាផ្នែកជីវភាពយ៉ាងខ្លាំង។

លោ កបន្តថា៖ «នៅខ្លះគ្រាន់បានដោះស្រាយជីវភាពប្រចាំថ្ងៃ។ យើងគ្រាន់ផ្សែផ្សំគ្នាខ្លះទៅ។ ឥឡូវនេះ នៅសល់ ១កានត្រឹម ៤ម៉ឺនទៅ៤ម៉ឺន៥ពាន់រៀលអីទេ។ យើងលក់នៅក្នុងភូមិ»។

លោក ប្រប ជឹប លើកឡើងថា មានអ្នកភូមិខ្លះក្នុងចំណោម ២១១គ្រួសារ ដែលរងគ្រោះដោយការឈូសឆាយនេះ បានធ្លាក់ខ្លួនជាប់បំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឯកជន។ បើតាមលោក ជឹប សម្រាប់គ្រួសារលោកម្នាក់ ត្រូវជាប់បំណុលមីក្រូហិរញ្ញវត្ថុ ៥០០០ដុល្លារអាមេរិក។

ប្រភពបន្តថាមូលហេតុដែលបង្ខំចិត្តខ្ចីបុលធានាគារនេះ គឺដើម្បីទិញគោយន្តសម្រាប់ជាមធ្យោបាយរកចំណូល ក្រោយពីលែងមានជ័រច្បោះ ប៉ុន្តែ លោក ជឹប ឱ្យដឹងថា គ្រួសាររបស់លោកបានសងរំលោះបានជាង ១ពាន់ដុល្លារហើយ។

មិនខុសពីលោក ជឹប ទេ ដែលលើកឡើងថាមានពលរដ្ឋជាប់បំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដោយឡែក លោក យ៉ិន សិង្ហក៏អះអាងដូចនេះដែរ។ បើតាមលោក សិង្ហ មានគ្រួសារខ្លះជាប់ជំពាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រហែល១ពាន់ដុល្លារអាមេរិកក៏មានដែរ។

មេឃុំស្រែឈូក លោក ឃិត ខិត អះអាងថា សព្វថ្ងៃនេះពិតជាមានពលរដ្ឋជំពាក់បំណុលមីក្រូហិរញ្ញវត្ថុមែន។ បើតាមលោក ខិត ចំនួនអ្នកជាប់បំណុលគ្រឹះស្ថានឯកជននេះ មានប្រមាណ ២០ ភាគរយប៉ុណ្ណោះក្នុងចំណោមប្រជាជនសរុបប្រមាណជាង ៩០០គ្រួ-សារ នៅក្នុងឃុំស្រែឈូកនេះ។ លោកបន្តថា «អាខ្ចីលុយរបស់រដ្ឋហ្នឹងមែន។ អរ! មានខ្ចីតើ មានតើ ប៉ុន្តែ មានភាគតិច»។

បើទោះជាបែបណា អភិបាលស្រុកកែវសីមា លោក នួន សារ៉ន បដិសេធថា ក្រុមហ៊ុនបានផ្ដល់សំណងរួចរាល់អស់ហើយចំពោះអ្នកដែលរងផលប៉ះពាល់ពិតប្រាកដគិតមកដល់ពេលនេះ។ លោកបន្ថែមទៀតថា ភាគីក្រុមហ៊ុនក៏បានសិក្សាយ៉ាងលម្អិតដែរអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គម មុននឹងដាក់គម្រោងវិនិយោគ។ លោកបន្តថា « អរ ! ក្រុមហ៊ុនមានកិច្ចសន្យាជាមួយរាជរដ្ឋាភិបាលត្រឹមត្រូវណាស់»។

បើតាមលោក នួន សារ៉ន ដើម្បីបញ្ចប់ជម្លោះភាគីក្រុមហ៊ុន និងអាជ្ញាធរថ្នាក់ដោះស្រាយទំនាស់ដីធ្លីថ្នាក់ខេត្ត កាលពីថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៤ បានសម្រេចកាត់ដីចំនួន ៣៧៥ហិកតា ពីក្រុម-ហ៊ុនឱ្យសហគមន៍វិញ។

បើទោះជាបែបក្ដីនេះ ទាំងអង្គការមិនមែនរដ្ឋាភិបាល និងតំណាងសហគមន៍មួយចំនួន បានប្រាប់វីអូឌីថា ដីដែលក្រុមហ៊ុនកាត់ចេញនេះ គឺមិនបានទៅប្រជាពលរដ្ឋរងគ្រោះពិតប្រាកដទេ។ បើតាមប្រភពដដែល អះអាងថា អ្នកដែលទទួលបានដីភាគច្រើន គឺអាជ្ញាធរមូលដ្ឋាន និងអ្នកចំណូលពីខាងក្រៅ ដែលក្រុមអាជ្ញាធរចាត់ចែង និងរៀបចំឱ្យប៉ុណ្ណោះ។

យ៉ាងនេះក្ដី មេឃុំស្រែឈូក លោក ឃិត ខិត បដិសេធ ក្នុងការផ្ដល់ព័ត៌មានលម្អិតជុំវិញរឿងនេះ។ ចំណែកអភិបាលស្រុក កែវសីមា លោក នួន សារ៉ន បានហៅក្រុមអ្នកតវ៉ាដីធ្លីទាំងនេះថា គឺជាពលរដ្ឋដែលមកពីតំបន់ផ្សេង ដែលមិនមែនស្ថិតនៅក្នុងដីទំនាស់ទេ។

ជនជាតិដើមភាគតិចព្នង បាត់បង់សិទ្ធិជាមូលដ្ឋាននៃការតស៊ូមតិលោក យ៉ិន សិង្ហ ដែលជាតំណាងសហគមន៍ម្នាក់ក្នុងចំណោមតំណាង ៦នាក់ មានប្រសាសន៍ថា ដោយការគំរាមកំហែងឥតឈប់ឈរ និងឥតស្រាកស្រានពីអាជ្ញាធរមូលដ្ឋានប្រជាពលរដ្ឋជាងពាក់កណ្ដាលដែលរងគ្រោះសម្រេចចិត្តផ្អាកការតស៊ូមតិ។ ការដកឃ្លាពីការទាមទារសិទ្ធិនេះ ព្រោះតែតំណាងរបស់ពួកគាត់ ត្រូវចាប់ខ្លួន និងចោទប្រកាន់តាមផ្លូវតុលាការក្នុងពេលកន្លងទៅ។

របាយការណ៍មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ឱ្យដឹងថា អ្នករងគ្រោះនៅភូមិចក់ចារ មានចំនួន ២១១គ្រួសារក្នុងចំណោមគ្រួសារសរុបប្រមាណ ៩០០គ្រួសារ ស្មើប្រជាជនប្រមាណជាង ៤ពាន់នាក់។

ភូមិចក់ចារ ដែលស្ថិតនៅចម្ងាយជិត៤០គីឡូម៉ែត្រពីផ្លូវជាតិលេខ៧៦ និងទីប្រជុំជន ហើយជាទីតាំងដែលខ្វះព័ត៌មានស្រាប់ផងនោះ បានជំរុញឱ្យអាជ្ញាធរ មានភាពងាយស្រួលក្នុងការបំភិតបំភ័យពលរដ្ឋ។ មុននឹងទៅដល់ភូមិចក់ចារនេះ គឺអ្នកដំណើរត្រូវប្រើប្រាស់មធ្យោបាយដោយម៉ូតូ ឆ្លត់កាត់ព្រៃចម្ការកៅស៊ូរបស់ក្រុមហ៊ុនប៊ិញភឿក១ និងផ្លូវជាច់ដោយកងៗ។ មានគោលដៅ និងផ្លូវខ្លះត្រូវឆ្លងកាត់ភក់ ជ្រាំ ទឹក និងផ្លូវអិលថែមទៀត មុននឹងទៅដល់ភូមិចក់ចារនោះ។

តំណាងសហគមន៍ដែលឆ្លងកាត់បទសម្ភាសន៍ជាមួយវីអូឌីឱ្យដឹងថា អាជ្ញាធរមូលដ្ឋាន នៅក្នុងឃុំស្រែឈូកនេះ គឺអនុវត្តច្បាប់តឹងរឹងបំផុត។ មនុស្សដែលប្លែកមុខ គឺចូលទៅក្នុងសហគមន៍នេះ មិនបានទេ កុំថាឡើយទៅសម្រាក សូម្បីទៅដើម្បីសម្ភាសន៍ពលរដ្ឋក្នុងសហគមន៍នេះមិនបានផង។

កាលពីថ្ងៃទី១០ ខែ តុលា អ្នកយកព័ត៌មានវីអូឌី ២នាក់ ត្រូវបានអនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាល ដែលទទួលបញ្ជាពីមេឃុំ បានរាំងមិនឱ្យជួបពលរដ្ឋឡើយ។ ពួកគាត់តែងរំខានរាល់ពេលចង់ជួបពលរដ្ឋ និងបន្ទាប់មកទៀត អ្នកកាសែតទាំង ២នាក់ ត្រូវបាននគរបាលតម្រូវឱ្យរាយការណ៍ពីប្រវត្តិរូប ការងារ និងគោលបំណងនៃការចុះទៅក្នុងមូលដ្ឋាន។

តំណាងសហគមន៍ភូមិចក់ចារ លោក ប្រប ជីប លើកឡើងថា នេះមិនមែនជាលើកទី១ទេ ដែលអាជ្ញាធរ និងនគរបាល បិទសិទ្ធិអ្នកកាសែតមិនឱ្យសម្ភាសន៍ពលរដ្ឋ។ អ្នកតំណាងរូបនេះ បន្តថា នៅអំឡុងឆ្នាំ២០១៥ ក៏មានបុគ្គលិកអង្គការសហប្រជាជាតិ ២រូប ត្រូវបានកម្លាំងនគរបាល និងសន្តិសុខក្រុមហ៊ុន ឃាត់ខ្លួនពេញ១យប់ មុននឹងដោះលែងវិញនៅថ្ងៃបន្ទាប់ ក្រង់បរិវេណក្រុមហ៊ុនដែរ។




*ក្រាហ្វិចបង្ហាញពីជនជាតិដើមភាគតិចព្នងនៅភូមិចក់ចារ ខេត្តមណ្ឌលគិរី បាត់បង់ចំណូល ក្រោយក្រុមហ៊ុនវៀតណាមវិនិយោគទាំងភាពចម្រូងចម្រាស់*

## ប្រជាពលរដ្ឋមិនដែលបានដឹងពីការសិក្សាហេតុប៉ះពាល់បរិស្ថាន និងសង្គមរបស់ក្រុមហ៊ុន

តំណាងសហគមន៍មួយចំនួន ដែលបានផ្តល់បទសម្ភាសន៍ឱ្យវីអូឌី អះអាងថា ពួកគាត់មិនដែលបានទទួលសំណងពីការឈូសឆាយដីព្រៃ ដីបម្រុងទុក ព្រៃកប់សព ព្រៃចម្ការវិលជុំ និងព្រៃសែនព្រេនទេពីខាងក្រុមហ៊ុនម្តងណាឡើយ។ លើសពីនេះទៀត ក្រុមហ៊ុនប៊ិញភឿក ១ ចាប់ឈូសឆាយយកតែម្តង ដោយពុំបានចុះសិក្សា និងពិគ្រោះយោបល់ជាមុនជាមួយពលរដ្ឋក្នុងសហគមន៍ថែមទៀតផង។

លោក វណ្ណ សុផាត មន្ត្រីអង្គការនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា មានប្រសាសន៍ថា ក្នុងពេលលោកចុះអង្កេត និងសិក្សាស្រាវជ្រាវជាលទ្ធផល គឺភាគីក្រុមហ៊ុន មិនបានបង្ហាញពីការសិក្សាហេតុប៉ះពាល់បរិស្ថាន និងសង្គមទេ។ បើតាមលោក សុផាត ទាំងអាជ្ញាធរនៅថ្នាក់មូល ដ្ឋាន ក៏បានអះអាងដែរថា ពួកគាត់មិនដែលឃើញលើទាល់តែសោះ ពីគម្រោងវិនិយោគរបស់ក្រុមហ៊ុនវៀតណាមនេះនៅគ្រាដំបូង។

លោកបញ្ជាក់ថា៖ «ជាការរកឃើញនេះមុនក្រុមហ៊ុនចុះទៅនិងប្រតិបត្តិការ គឺក្រុមហ៊ុនមិនបានធ្វើវាយតម្លៃពីហេតុប៉ះពាល់សង្គម និងបរិស្ថានទេ។ គ្មានការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋហើយ សូម្បីអាជ្ញាធរមូលដ្ឋានក៏មិនបានដឹងដែរ ហើយយើងបានជួបអាជ្ញាធរ

ផ្ទាល់គាត់ពីដើមក៏អត់ដឹងដែរ។ស្រាប់ដល់ពេលគ្រឿងចក្រចូល បាន គេប្រាប់ពីលើមកថាឥឡូវនេះ ក្រុមហ៊ុន ប៊ិញភឿក១ បានចុះមកដំណើការនេះដោយសាររដ្ឋាភិបាល និងក្រសួងកសិកម្មផ្ដល់សម្បទានដីសេដ្ឋកិច្ចទៅឱ្យគាត់»។

យោងរបាយការណ៍ របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ដែលស្រង់សម្ដីរបស់អគ្គនាយកក្រុមហ៊ុន ប៊ិញភឿក១ គឺលោក ប៊ូ វ៉ាន់តាប់ ប្រាប់ ម.ស.ម.ក ថា រដ្ឋាភិបាល បានបើកផ្លូវឱ្យក្រុមហ៊ុនវិនិយោគនៅទីនេះ។ តាមរយៈអនុក្រឹត្យរបស់រដ្ឋាភិបាលចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ ក្រុមហ៊ុនទទួលបានដីទំហំជិត ៩ម៉ឺនហិកតា (៨.៨៩០) ដើម្បីដាំកៅស៊ូ។

បើទោះជាបែបណា មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបញ្ជាក់ថា ផ្អែកលើការស្រាវជ្រាវ រកឃើញថា គឺទំហំផ្ទៃដីពិតប្រាកដដែលរដ្ឋាភិបាលផ្ដល់ឱ្យក្រុមហ៊ុននេះគឺ ១ម៉ឺនហិកតា។ ប៉ុន្តែ មានតែផ្ទៃដី ៥.១០០ ហិកតាប៉ុណ្ណោះ ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទតម្រូវឱ្យដាំដំណាំកៅស៊ូ។ ដោយឡែក ផ្ទៃដីសល់ពីនេះ ត្រូវកាត់ចេញ ដូចជាដីព្រៃទ្រនាប់ជងអូរ និងដីព្រៃត្រូវរក្សាទុក។

របាយការណ៍ដដែល ដែលចេញផ្សាយកាលពីខែ កញ្ញា ឆ្នាំ ២០១៥ ស្ដីពីការឈូសឆាយដីដោយក្រុមហ៊ុនប៊ិញហ្វៀក១ សរសេរថា ពួកគាត់បានកាន់កាប់ដីដែលស្ថិតនៅក្នុងភូមិចក់ចារ ឃុំស្រែឈូក ស្រុកកែវសីមា ខេត្តមណ្ឌលគិរីនេះ ចាប់តាំងពីពាក់កណ្ដាលទសវត្សរ៍ឆ្នាំ១៩៤០មកម្ល៉េះ។

ប៉ុន្តែ នៅក្នុងរបបខ្មែរក្រហម ជនជាតិដើមភាគតិចព្នងនៅទីនេះ ត្រូវបានទាហានខ្មែរក្រហមជម្លៀសចេញពីភូមិឋានដូចពលរដ្ឋដទៃទៀតនៅទូទាំងប្រទេសដែរ។ របាយការណ៍បន្តថាក្រោយសមាហរណកម្មឆ្នាំ១៩៩៨ ពួកគាត់បានមកតាំងទីលំនៅឡើងវិញ។

ការកកើតនៃទំនាស់នេះ បើតាមរបាយការណ៍នៃ ម.ស.ម.ក បញ្ជាក់ថា វិវាទដីនៅភូមិចក់ចារនេះ បានផ្ទុះឡើងនៅអំឡុងឆ្នាំ ២០១២។ ដោយជំហានដំបូង ក្រុមហ៊ុនបានដាក់កម្លាំងកម្មករជាជនជាតិវៀតណាមសុទ្ធប្រមាណពី២០ ទៅ ៣០នាក់ ដើម្បីបញ្ឆោតថា ជាកម្មករដឹកឈើ។ ក្រោយមកទៀត នៅអំឡុងឆ្នាំ២០១៣ ក្រុមហ៊ុន ប៊ិញភឿក១នេះចាប់ផ្ដើមឈូសឆាយដីព្រៃយកតែម្ដង។

លោក វណ្ណ សុផាត អ្នកសម្របសម្រួលគម្រោងធុរកិច្ច និងសិទ្ធិមនុស្ស នៃ ម.ស.ម.ក បញ្ជាក់ថា ក្រុមហ៊ុនទទួលបានសិទ្ធិវិនិយោគលើផ្ទៃដីជាង ៨ពាន់ហិកតា។ យោងរបាយការណ៍របស់មជ្ឈមណ្ឌលសិទ្ធិកម្ពុជា ក្រុមហ៊ុនប៊ិញភឿក១នេះ ចាប់ផ្ដើមឈូសឆាយដីបង្ហើយ ដែលនៅសល់ចុងក្រោយ ១៥០០ហិកតា នៅថ្ងៃទី៣១ ខែមិថុនា ឆ្នាំ២០១៥។

លោក ប្រុប ជឹប តំណាងពលរដ្ឋជនជាតិដើមភាគតិចព្នង អះអាងថា នៅក្នុងឃុំស្រែឈូកនេះ មានភូមិចំនួន០៩ភូមិ។ ប៉ុន្តែក្នុងចំណោមនេះ ភូមិដែលរងគ្រោះ និងប៉ះពាល់ខ្លាំងជាងគេពីគម្រោងវិនិយោគរបស់ក្រុមហ៊ុន ប៊ិញភឿក១ គឺភូមិចក់ចារនេះ។

តំណាងសហគមន៍រូបនេះថ្លែងថានៅមុនឆ្នាំ២០១២ទីតាំងនេះ គឺជាប្រភពនៃជម្រកសត្វព្រៃគ្រប់ប្រភេទរស់នៅ។មិនតែប៉ុណ្ណោះ ព្វាគឺជាតំបន់ដែលមានព្រៃស្រោង ព្រៃពាក់កណ្ដាលស្រោង ព្រៃរបោះ និងវាលស្មៅជាដើម។

បន្ថែមពីលើនេះ តំបន់ដែលមានទំនាស់នេះ ថែមទាំងមាន បឹង អូរ និងស្ទឹងហូរខ្វេបខ្វាងខ្វេបវង្វេង។កត្តាអំណោយផលពីធម្មជាតិទាំងនេះហើយ ដែលត្រូវបានលោក ជឹប អះអាងថា ជនជាតិដើមភាគព្នងតែងប្រមូលអនុផលមិនដែលដាច់ឡើយ។

លោក ភ្លឺប ប៉ា វ័យប្រមាណ ៦០ ឆ្នាំ ដែលមានទីលំនៅក្នុងឃុំស្រែឈូកដែរ អះអាងថា ក្រុមគ្រួសាររបស់លោកមានដើមជ័រច្បោះប្រមាណ២០ដើមប៉ុណ្ណោះ បើប្រៀបធៀបអ្នកភូមិដូចគ្នាគឺលោកមានតិចជាងគេ។លោក ប៉ា ឱ្យដឹងបន្ថែមថា សព្វថ្ងៃនេះ រូបលោក និងអ្នកភូមិផ្សេងទៀតកាន់តែប្រឈមមុខនឹងជីវភាពប្រចាំថ្ងៃជាងមុនទៅទៀត។

បើតាមលោក ប៉ា បច្ចុប្បន្ននេះក្នុងក្រុមគ្រួសាររបស់លោករកចំណូលមិនបាន១០ម៉ឺនរៀលផង ជាង២ខែទៅហើយ។ ប្រភពដដែលបញ្ជាក់ថាកាលពី៣ឆ្នាំមុន លោកអាចរកចំណូលបានពីជ័រ

ច្បោះនេះគិតជាមធ្យមប្រមាណ២០ម៉ឺនរៀល។មូលហេតុនៃការធ្លាក់ចុះចំណូលនាពេលនេះ ដោយសារតម្លៃជ័រទឹកធ្លាក់ចុះ ហើយពុំមានទីផ្សារដូចមុន ជាពិសេសប្រភពចំណូលដ៏សំខាន់គឺជ័រទឹកនេះ ត្រូវបានក្រុមហ៊ុនឈូសឆាយព្រៃឈើដែលអ្នកភូមិតែងអាស្រ័យផលអស់ថែមទៀត។

លោកបន្តថា៖ « ខ្ញុំរាល់ថ្ងៃនេះរកចំណូលមិនបាន១០ម៉ឺនរៀលផងក្ដួយ។ឥឡូវនេះចូលដល់២ ខែទៅហើយទើបបានលក់លក់មួយកាន់ឡើយផង(១ កានស្មើ៣០ លីត្រ)។បើពីមុនអីក្នុង១ ខែខ្ញុំជងជ័រទឹកបាន២ កាន។ក្នុង១ កាន់គេទិញចូល៧ ម៉ឺនរៀលបើសរុប២ កាន់វាស្មើ១៤ម៉ឺនរៀលដែរ »។

លោក គ្រឿង តុលា អ្នកសម្របសម្រួលបណ្ដាញក្រុមសហគមន៍ជនជាតិដើមភាគតិច ដែលមានទីតាំងនៅខេត្តមណ្ឌលគិរីបញ្ជាក់ថានេះជាការអភិវឌ្ឍន៍ដែលមិនបានជួយធ្វើឱ្យសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋរីកចំរើនទេ។បើតាមលោក តុលា មុនអនុញ្ញាតឱ្យក្រុម-ហ៊ុនឯកជនវិនិយោគ រដ្ឋាភិបាលត្រូវពិនិត្យពីតម្រូវការរបស់ប្រជាជននិងផលប៉ះពាល់ឱ្យបានល្អិតល្អន់សិន មុននឹងត្រូវផ្ដល់សិទ្ធិវិនិយោគ។

លោកបន្តថា៖ « នេះជាការអភិវឌ្ឍន៍ ដែលរំលោភសិទ្ធិមនុស្ស និងជាការអភិវឌ្ឍន៍ មានន័យថាមិនគោរពសិទ្ធិអ្នកដទៃ។ ចំណុចទាំងនេះហើយ ដែលជនជាតិដើមភាគតិចតែងទាមទារ។ ហើយការទាមទារសិទ្ធិនេះនាំឱ្យមានការយល់ច្រឡំ រួចចោទពួកខ្ញុំថាប្រឆាំងនឹងរាជរដ្ឋាភិបាល ឬធ្វើអប្បគមន៍អីហ្នឹងហែអ៊ីចឹងទៅ។ ចំណុចទាំងអស់ហ្នឹងគឺពួកខ្ញុំមិនអាចទទួលយកបានទេ» ។

អ្នកស្រី សូ ណាង ដែលអះអាងថាជាឈ្មួយកណ្ដាលស្ថិតនៅក្នុងស្រុកកែវសីមា ឱ្យដឹងថា ក្រុមគ្រួសារអ្នកស្រីបានប្រមូលទិញជ័រច្បោះពីអ្នកភូមិជាប្រចាំ។ប៉ុន្តែអ្នកស្រីលើកឡើងថាមួយរយៈពេលចុងក្រោយនេះ ខ្សត់ជ័រទឹកណាស់។ ម្យ៉ាងវិញទៀតបើតាមអ្នកស្រីណាង តម្លៃជ័រទឹកក្នុងរយៈ១ឆ្នាំចុងក្រោយនេះធ្លាក់ថ្លៃថែមទៀតផង។ ប្រភពបន្តថា ក្នុង១កានជ័រទឹកអ្នកស្រី អាចចំណេញបានប្រមាណ៥ពាន់រៀលប៉ុណ្ណោះ។ប៉ុន្តែមកដល់ពេលបច្ចុប្បន្ននេះ ការបញ្ជាទិញជ័រទឹកនេះ ឈ្មួយគេលែងទទួលទៀតហើយ។

អ្នកស្រីបន្តថា៖ «កាលពីមុនជ័រទឹកនេះវាបានថ្លៃ ដល់ឥឡូវនេះបានតែ៤ម៉ឺនរៀលទេ។កាលពីឆ្នាំ២០១៨ តម្លៃជ័រទឹក១កាន់៨ម៉ឺន៥ពាន់រៀល។នៅឆ្នាំ២០១៨ តម្លៃស្ថិតនៅចន្លោះពី៨ទៅ៩ម៉ឺនរៀលក្នុង១កាន់។តែឥឡូវនេះធ្លាក់មកនៅត្រឹម៤ម៉ឺនរៀលក្នុង១កាន។តម្លៃត្រឹម៤ម៉ឺនរៀលក្នុង១កានហើយគេអត់យកទៀត»។

វីអូឌី ទទួលបានលិខិតមួយចំនួនដែលចុះកាលបរិច្ឆេទផ្សេងៗគ្នាអំឡុង ឆ្នាំ២០១៣ និងឆ្នាំ២០១៥ អំពីបណ្ដឹងសុំអន្តរាគមន៍ពីថ្នាក់ជាតិរបស់ពលរដ្ឋចំនួន២១១គ្រួសារ ស្មើប្រមាណ១ពាន់៥៥នាក់ ។ លិខិតរបស់តំណាង៥រូប ដែលតំណាងឱ្យពលរដ្ឋ២១១គ្រួសារ ជាជនជាតិដើមភាគតិចព្នង បានស្នើសុំឱ្យស្ថាប័នពាក់ព័ន្ធដូចជារដ្ឋសភា ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងខុទ្ទកាល័យរបស់លោកនាយករដ្ឋមន្ត្រីជាដើម ជួយអន្តរាគមន៍បញ្ឈប់ក្រុមហ៊ុន ប៊ិញភឿក១ និងប្រគល់ដីឱ្យពួកគាត់វិញ។

បើទោះជាបែបណា នៅក្នុងលិខិតរបស់តំណាងស្ថាប័នជាតិសំខាន់ៗទាំងនោះ បានឆ្លើយតបមកវិញថា ការដោះស្រាយ ដូចការស្នើសុំនេះ វាមិនមែនជាដែនសមត្ថកិច្ចរបស់ពួកគេឡើយ។

នៅក្នុងអំឡុងឆ្នាំ២០១៣ និងឆ្នាំ២០១៥ លិខិតដែលវីអូឌីទទួលបានទាំង រដ្ឋសភា ទីស្ដីការគណៈរដ្ឋមន្ត្រី ខុទ្ទកាល័យលោកនាយករដ្ឋមន្ត្រី ក្រសួងដែនដី និងក្រសួងមហាផ្ទៃជាដើម បានប្រគល់សិទ្ធិដោះស្រាយវិវាទនេះ ឱ្យថ្នាក់ខេត្តជាអ្នកទទួលខុសត្រូវវិញ។

ប៉ុន្តែ នៅក្នុងរបាយការណ៍សិក្សាមួយរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ចេញផ្សាយនៅលើគេហទំព័ររបស់ខ្លួនកាលពីខែកញ្ញា ឆ្នាំ២០១៥ រកឃើញថា តំណាងសហគមន៍ចំនួន ៦នាក់ក្នុងនោះមានលោក ប្រប់ ជីប លោក ស្រួច ថៃវ លោក ភៅ អាន លោកឃិន សិង្ហ លោក ប៉ែន សុគន្ធា និងលោក ម៉ៅ ឃិន ត្រូវរងការប្ដឹងបកវិញពីភាគីក្រុមហ៊ុន។ អ្នកទាំង៦នាក់នោះ ត្រូវបានចោទប្រកាន់ថា

ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន។

នៅក្នុងរបាយការណ៍ដដែលនេះបញ្ជាក់ទៀតថា នៅអំឡុងខែមេសា ឆ្នាំ២០១៥ លោក យ៉ាន ម៉ៅ តំណាងពលរដ្ឋម្នាក់ក្នុងចំណោមអ្នក៥នាក់ផ្សេងទៀត ត្រូវបានតុលាការចាប់ខ្លួន។ មូលហេតុនៃការចាប់ខ្លួនដោយតុលាការខេត្តមណ្ឌលគិរីនេះ ចោទពីបទផ្សេងទៅវិញ គឺបទរួមភេទជាមួយអនីតិជន មិនគ្រប់អាយុ។

តាមរយៈរបាយការណ៍របស់ ម.ស.ម.ក ដែលស្រង់សំដីលោក យ៉ាន ម៉ៅ អះអាងថា ការចោទប្រកាន់របស់តុលាការប្រឆាំងរូបខ្លួននេះ គឺមិនពិតទេ។ ហើយមូលដ្ឋាននៃបទល្មើសនេះត្រូវបានលោក ម៉ៅ ចាត់ទុកថាអាជ្ញាធរបានកំណត់មុខសញ្ញាជនបង្គោល និងអ្នកដែលហ៊ានតស៊ូមតិតែប៉ុណ្ណោះ។

ប្រហែលជា ២សប្តាហ៍បន្ទាប់ពីចោទប្រកាន់លោក យ៉ាន ម៉ៅ ។ នៅអំឡុងខែ ឧសភា ឆ្នាំ២០១៥ លោក ប្រប ជីប តំណាងសហគមន៍ម្នាក់ផ្សេងទៀត ក្នុងចំណោមមនុស្សទាំង៦នាក់នោះ ត្រូវបានតុលាការខេត្តមណ្ឌលគិរីចេញដីកាឱ្យចូលខ្លួនបំភ្លឺ ជុំវិញសំណុំរឿងធ្វើឱ្យខូចខាតទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន។

យ៉ាងនេះក្តីប្រធានមន្ទីរកសិកម្មខេត្តមណ្ឌលគិរី លោក សុង យាង អះអាងថា ការពិតទំនាស់ដីធ្លីជាមួយក្រុមហ៊ុន ប៊ិញភឿក១ នេះ បានបិទបញ្ចប់រួចរាល់អស់ទៅហើយ។ លោកបន្តថា ភាគីទាំងសង្ខាងបានទទួលយល់ព្រមឯកភាព ទៅតាមការដោះស្រាយរបស់អាជ្ញាធរថ្នាក់ខេត្តហើយដែរ។

លោកបន្តថា៖ «អាហ្នឹងដូចគេដោះចប់អស់ហើយ។ បាទ អាហ្នឹងគេដោះចប់អស់ហើយ អត់មានឃើញជាំជុះអីទៀតផង។ អាជ្ញាធរស្រុកដូចគេដោះចប់អស់ហើយ។គេដោះចប់អស់ហើយ» ។

ចំណែក អភិបាលស្រុកកែវសីមា លោក នួន សារ៉ន បានចាត់ទុកអ្នកដែលតវ៉ាកន្លងទៅនេះថា មិនមែនជាពលរដ្ឋនៅរស់នៅក្នុងទីតាំងដែលមានទំនាស់ជាមួយក្រុមហ៊ុនទេ។ បើតាមលោក សារ៉ន អ្នកដែលមានទំនាស់ពិតប្រាកដ បានទទួលយកសំណងរួចរាល់អស់ហើយ ហើយវិវាទនេះក៏បានដោះស្រាយបញ្ចប់រួចរាល់ហើយដែរ។

លោកបន្តថា៖ «ថ្នាក់ខេត្តក៏បានធ្វើសេចក្តីជូន និងសេចក្តីប្រកាសព័ត៌មានឱ្យប្រជាពលរដ្ឋអស់ ដែលថាមានបញ្ហាហ្នឹងហើយ កំណត់រយៈពេលដើម្បីដោះស្រាយជូន ប៉ុន្តែ នៅពេលខាងខេត្តធ្វើសេចក្តីជូនដំណឹង និងដាក់ឱ្យសានវាទអីត្រឹមត្រូវ អត់មានអ្នកណាចូលរួមទេ។ អ៊ីចឹង ការដោះស្រាយ យើងក៏បានបញ្ចប់ទៅ។ ដូច្នេះខេត្តក៏បានរក្សាទុកចំនួន ៣៧៥ហិកតាសម្រាប់ជូនពួកគាត់។ អ៊ីចឹងអ្នកប្តឹងទាំង ២១១គ្រួសារដែលប្តឹងទៅនោះ គឺថាជាអ្នកដែលនៅខាងក្រៅទេ»។

មកដល់ពេលនេះ វីអូឌី ពុំអាចស្វែងរកទីតាំងនៃការិយាល័យកណ្តាលរបស់ក្រុមហ៊ុន ប៊ិញហឿក១ ដូចមានចុះបញ្ជីនៅក្រសួងកសិកម្មកាលពីថ្ងៃទី២៤ខែតុលាឆ្នាំ២០១១ដើម្បីស្នើសុំបំភ្លឺបានទេ។

លោក វណ្ណ សុផាត មន្ត្រីរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបញ្ជាក់ថា តាមពិតក្រុមហ៊ុនចំការកៅស៊ូក្រចេះប៊ិញហឿក១ (Benh Hoeurk Kratie Rubber1 Company Limited) ជាមួយនឹងក្រុមហ៊ុន ប៊ិញភឿក១ គឺជាក្រុមហ៊ុនតែ១ជាមួយគ្នា។

ឯកសារដែល វីអូឌី ទទួលបានពី ម.ស.ម.ក ដែលក្រុមហ៊ុននេះចុះបញ្ជីនៅក្រសួងកសិកម្ម គឺមានទីតាំងនៅផ្ទះលេខ៩២ ជាប់នឹងមហាវិថីនរោត្តម ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

នៅពេលអ្នកយកព័ត៌មានវីអូឌី ស្វែងរកទីតាំងដូចបានចុះបញ្ជីនៅក្រសួងកសិកម្ម គឺពុំមានការិយាល័យទេ ប៉ុន្តែ ក្រុមហ៊ុននេះ បានបង្កើតរោងចក្រមួយ ស្ថិតនៅក្នុង ឃុំស្រែឈូក ស្រុកកែវសីមា។ តំណាងសហគមន៍ ដែលបានផ្តល់បទសម្ភាសន៍ឱ្យ វីអូឌី ដឹងថា រោងចក្រដែលក្រុមហ៊ុនបានបង្កើតឡើងនេះគឺជាការិយាល័យផ្លូវការរបស់ក្រុមហ៊ុនហើយ។បច្ចុប្បន្ន រោងចក្រ ដែលស្ថិតនៅចំកណ្តាលដីនេះ កំពុងបង្កើនការផលិតដំណាំចេក សម្រាប់នាំចេញទៅលក់នៅក្រៅប្រទេស។

អ្នកនាំពាក្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ នេសាទ លោកស្រី វុឌ្ឍី បដិសេធថា លោកមិនបានព័ត៌មានស្តីពីក្រុមហ៊ុននេះមានការិយាល័យពិតប្រាកដនៅទីណាទេ។ បើតាមលោក វុទ្ធី អ្វីដែលលោកមិនបានដឹងថែមទៀតនោះ គឺការកំណត់ឱ្យក្រុមហ៊ុនទុកដីប៉ុន្មាន និងដីតម្រូវឱ្យក្រុមហ៊ុនវិនិយោគប៉ុន្មាន។

លោកបន្តថា «ប៊ិញហ្វៀក១ យី ! ដឹងជាមានឬអត់ទេ។ ខ្ញុំដូចអត់ក្តាប់អាហ្នឹងបានទៀតហ្មា។ ចុះបញ្ជីឆ្នាំ២០១១ យី ខ្ញុំដូចអត់ច្បាស់ទេ មិនដឹងវាមាននៅទីនេះ ឬវាមាននៅកន្លែងខេត្ត»។

បើផ្អែកលើឯកសាររបស់ ម.ស.ម.ក ឱ្យដឹងថា ក្រុមហ៊ុននេះទទួលបានអនុក្រឹត្យកាលពីថ្ងៃទី២៥ ខែ មីនា ឆ្នាំ២០១១ ឱ្យវិនិយោគលើដីសម្បទានសេដ្ឋកិច្ចទំហំ១ម៉ឺនហិកតា នៅក្នុងស្រុកកែវសីមា ខេត្តមណ្ឌលគិរី។ ១សប្តាហ៍បន្ទាប់មកពោលកាលពីថ្ងៃទី១ ខែ មេសា ឆ្នាំ២០១១ ក្រុមហ៊ុនប៊ិញហ្វៀក១នេះ ត្រូវបានរដ្ឋាភិបាលបើកផ្លូវឱ្យវិនិយោគ ទៅតាមការស្នើសុំជាដំណាំកៅស៊ូ។

លោក វណ្ណ សុផាត មន្ត្រីអង្គការនៃមជ្ឈមណ្ឌលសិទ្ធិកម្ពុជា ឱ្យដឹងថា លោកធ្លាប់បានជួបភាគីក្រុមហ៊ុនដោយផ្ទាល់ក្នុងពេលកន្លងទៅ នៅទីតាំងក្រុមហ៊ុនក្នុងស្រុកកែវសីមា។

បើតាមលោក សុផាតឯកសារដែលលោកបានឃើញកាលណោះ គឺមានភាពមិនច្បាស់លាស់ខ្លះ ប៉ុន្តែ មន្ត្រីសិទ្ធិមនុស្សរូបនេះអះអាងថា វាជាការដែលគួរឱ្យសោកស្តាយ ដែលឯកសារទាំងនោះមិនត្រូវបានគេអនុញ្ញាតិឱ្យថតទុក ដើម្បីផ្ទៀតផ្ទាត់។

លោកបន្តថា៖ «បាទ យើងឃើញមានលិខិតមានលក្ខណៈលុបអីខ្លះអ៊ីចឹងទៅ។ យើងឃើញមួយភ្លែតទៅ មានឯកសារខ្លះមានកោសលុបអ៊ីចឹង។ យើងក៏បានឃើញច្បាស់អ៊ីចឹង តែយើងក៏មិនបានដឹងការកោសលុបហ្នឹងដោយសារមូលហេតុអី។ ប៉ុន្តែ បើឯកសារធម្មតាជាលក្ខណៈផ្លូវការវាអត់មានកោសលុបទេ»។

សព្វថ្ងៃមានប្រជាពលរដ្ឋចំនួន ១៥០គ្រួសារក្នុងចំណោម ២១១គ្រួសារដែលរងគ្រោះខ្លាំង នៅបន្តទាមទារនៅឡើយនូវដីដែលធ្លាប់កាន់កាប់មកជាដីកម្មសិទ្ធិត្រឡប់មកវិញ។

លោក វណ្ណ សុផាត អ្នកសម្របសម្រួលគម្រោងធុរកិច្ច និងសិទ្ធិមនុស្ស មានប្រសាសន៍ថា ថ្វីបើនៅពេលនេះ ពួកគាត់មិនបានធ្វើយុទ្ធនាការតស៊ូមតិដូចមុន ប៉ុន្តែ មិនមានន័យថា ម្ចាស់ដីដែលបាត់បង់ទាំងនោះ បានបោះបង់សិទ្ធិជាម្ចាស់កម្មសិទ្ធិដីឡើយ។

នៅក្នុងលិខិតរួមគ្នា របស់តំណាងពលរដ្ឋជនជាតិដើមភាគតិចព្នង ដែលស្នើសុំកិច្ចអន្តរាគមន៍ពីស្ថាប័នរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ បញ្ជាក់ថា អ្នកភូមិត្រូវការដីស្រែ និងដីចម្ការមកវិញ ដើម្បីបង្កបង្កើនផល។

ជាងនេះទៀត រាល់ការខូចខាត និងបាត់បង់ទាំងអម្បាម៉ានដែលក្រុមហ៊ុនឈូសឆាយ ត្រូវបង់សងឱ្យពលរដ្ឋវិញ។ មិនតែប៉ុណ្ណោះ ស្នើសុំឱ្យអាជ្ញាធរមូលដ្ឋាន និងកម្លាំងនគរបាលបញ្ឈប់ជាបន្ទាន់នូវការគំរាមកំហែងប្រជាពលរដ្ឋតទៅទៀត។

## ៥. ជម្លោះកំពុងកើតមានជុំវិញសំណើបង្កើតព្រលានយន្តហោះអេកូទេសចរណ៍

ប្រជាពលរដ្ឋពីរនាក់ចង្អុលទៅកាន់ចម្ការរបស់អ្នកភូមិដែលកំពុងស្ថិតនៅក្នុងដែនដី ដែលនឹងក្លាយជាតំបន់អភិវឌ្ឍន៍ព្រលានយន្តហោះថ្មីនៅក្នុងខេត្តមណ្ឌលគិរី។ (VOD/Danielle Keeton-Olsen) ស្រុក អូររាំង ខេត្តមណ្ឌលគិរី - ប្រជាពលរដ្ឋបានរំឭកថា គ្រឿងចក្របានជីកកាយដីកាន់តែជិតទៅៗ មកកាន់ដីសម្រាប់បញ្ចុះសពរបស់សហគមន៍ជនជាតិព្នង ដោយមានសន្តិសុខកំពុងឈរយាមប្រចាំការ ហើយគំរាមថានឹងបង្ក្រាប ប្រសិនបើមានការតវ៉ាណាមួយនោះ ។

អ្នកលក់ឥវ៉ាន់នៅក្នុងភូមិម្នាក់ ឈ្មោះ ប៉ាញ់ បាននិយាយថា៖ "ប្រសិនបើគេខិតមកកាន់តែជិតទៀត នោះពួកគេច្បាស់ជានឹងជីកកាយនៅលើដីបញ្ចុះសពជាក់ជាមិនខាន"។

ប្រជាពលរដ្ឋ បានឮអំពីផែនការកសាងព្រលានយន្តហោះមួយនៅ ក្នុងខេត្តមណ្ឌលគិរីរាប់ឆ្នាំមកហើយ ដើម្បីជំរុញវិស័យអេកូទេសចរ ណ៍ ប៉ុន្តែការសាងសង់ព្រលានយន្តហោះនេះ គឺស្ថិតនៅជិតនឹងភូមិឋានរបស់ពួកគេ ជាងអ្វីដែលអាជ្ញាធរមូលដ្ឋានធ្លាប់បានលើកឡើងទៅទៀត។

ក្រសួងទេសចរណ៍ ហាក់ដូចជាខិតខំប្រឹងប្រែងជំរុញឱ្យផែនការដែលជាប់គាំងយូរមកហើយនេះមានដំណើរការទៅមុខដើម្បីកសាង ព្រលានយន្តហោះមួយក្នុងខេត្តមណ្ឌលគិរី ហើយអាជីវកម្មផ្នែ កវិស័យទេសចរណ៍មួយចំនួន ក៏កំពុងប្រឹងប្រែងក្រសោបយកឱកាសនេះផងដែរ។ ប៉ុន្តែនៅក្នុងមូលដ្ឋានស្រុកអូររាំងវិញ មន្ត្រីនានាហាក់បីដូចជាព្យាយាមគេចវេសមិននិយាយអំពីប្រធានបទនេះទាល់តែសោះ ដែលបណ្តាលឱ្យអ្នកស្រុកមានអារម្មណ៍ភ័យខ្លាចថាដីធ្លីរបស់ពួកគេនឹងត្រូវរឹបអូសក្នុងពេលឆាប់ៗ។

កសិករអាយុ 29 ឆ្នាំម្នាក់ ដែលសុំមិនឱ្យបញ្ចេញឈ្មោះ ដោយភ័យខ្លាចថាអាជ្ញាធរនឹងរករឿងនាង បានរំឭកថានៅពេលដែលពួកគេបានដឹងថាមន្ត្រីកំពុងតែអនុវត្តតាមសំណើកសាងព្រលានយន្តហោះ ដែលបានកប់បាត់មួយរយៈហើយនោះ អ្នកភូមិក៏បាននាំគ្នាទៅឡោមព័ទ្ធការដ្ឋានដើម្បីប្រឈមជាមួយនឹងក្រុមកម្មករ ។

ស្ត្រីកសិកររូបនេះបាននិយាយនៅឯផ្ទះ ដែលស្ថិតនៅចម្ងាយពីបីរយម៉ែត្រពីកន្លែងបញ្ចុះសពថា៖ "នៅពេលដែលយើងនាំគ្នាទៅសាកសួរពួកគេ ពួកគេបានទុកឧបករណ៍ចោលនៅទីនោះ ហើយផ្លាស់ទៅធ្វើការនៅកន្លែងផ្សេងមួយទៀត"។ គាត់លើកឡើងទៀតថាកម្មករបានគំរាមថាពួកគេនឹងបង្ក្រាប ប្រសិនបើមានការតវ៉ាពីអ្នកភូមិកើតឡើង។

គាត់បន្តនិយាយទៀតថា៖ "ដូច្នេះ យើងកាន់តែសង្ស័យខ្លាំងឡើងថា គម្រោងព្រលានយន្តហោះនោះមិនមែនជារបស់រដ្ឋាភិបាលនោះទេ ប៉ុន្តែប្រហែលជារបស់ឯកជនច្រើនជាង"។

ស្ត្រីរូបនោះនិយាយថា គាត់ និងអ្នកភូមិផ្សេងទៀត មានបំណងអត់ឱនចំពោះផែនការដែលបានប្រកាសកាលពីមុន ដែលថានឹង គ្រោងធ្វើការអភិវឌ្ឍនៅលើផ្ទៃដីទំ ហំ 300 ហិចតា ប៉ុន្តែប្រសិនបើពង្រីករហូតដល់ 600 ហិចតា ដូចដែលគាត់បានឮនៅក្នុងកិច្ចប្រជុំរវាងអ្នកភូមិ និងក្រុមផ្តួចផ្តើមឱ្យមានព្រលានយន្តហោះនោះពិតមែន គម្រោងនោះច្បាស់ជាប៉ះពាល់ខ្លាំងដល់ភូមិរបស់គាត់មិនខាន។ គាត់មានប្លង់ទន់ ដែលបានទទួលស្គាល់ពីការលក់ដីធ្លីរវាងរូបគាត់ និងម្ចាស់ដីមុន ប៉ុន្តែគាត់មិនមានឯកសារកម្មសិទ្ធិផ្លូវការដែលទទួលស្គាល់ពីរដ្ឋាភិបាលឡើយ។ ម្ចាស់តូបតវ៉ាន់ ឈ្មោះ ប៉ាញ់ ក៏មានតែប្លង់ទន់ដែរ ហើយតំណាងអង្គការសិទ្ធិមនុស្សអាដហុកប្រចាំខេត្តមណ្ឌលគិរី គឺ លោក អ៊ាង ម៉េងលី បាននិយាយថា អ្នកភូមិជាច្រើនក្នុងតំបន់នេះគឺសុទ្ធតែមានបញ្ហាដូចគ្នានេះទោះបីជាលោកនៅមិនទាន់ដឹងថា តើមានប្រជាជនប៉ុន្មានគ្រួសារ នឹងទទួលរងផលប៉ះពាល់នៅឡើយទេក៏ដោយ។ អ្នកភូមិដែលភាគច្រើនគឺជាជនជាតិដើមភាគតិចព្នងក៏បានបង្ហាញក្តីបារម្ភដែរថាគម្រោងអភិវឌ្ឍន៍នោះ គឺស្ថិតនៅជិតនឹងដីបញ្ចុះសពដូនតារបស់ពួកគេ ដែលជាទីសក្ការៈដ៏សំខាន់បំផុត ពោលគឺជាទីកន្លែង ដែលអ្នកភូមិភាគច្រើន បញ្ចុះសពសាច់ញាតិរបស់ខ្លួននៅទីនោះ។

លោក ដារ៉ាមី អាយុ 48 ឆ្នាំ ដែលដាំដុះដើមព្រីង និងដំណាំផ្លែឈើផ្សេងទៀតនៅលើដីចម្ការ ដែលស្ថិតនៅជិតនឹងគម្រោងព្រលានយន្តហោះនោះ បានលើកឡើងថាអ្នកភូមិបានស្រែកទ្រហោយំនៅពេលដែលបានដឹងដំណឹងថា ដីរបស់ពួកគាត់អាចនឹងត្រូវលក់ឱ្យរដ្ឋាភិបាលវិញ។ ក្នុងអំឡុងពេលកិច្ចប្រជុំនោះ មន្ត្រីដែលចុះមកប្រជុំនៅទីនោះ ប៉ុន្តែពួកគាត់មិនស្គាល់អត្តសញ្ញាណបាននិយាយថាពួកគេនឹងទិញដីក្នុងតម្លៃ 1,000 ដុល្លារក្នុងមួយហិចតា ដែលតម្លៃនេះ លោក ដារ៉ាមី បានចាត់ទុកថាជាតម្លៃទាប។ គាត់បាននិយាថា មានអ្នកភូមិខ្លះត្រូវបានគេដកយកដីត្រលប់ទៅវិញហើយ ប៉ុន្តែការលើកឡើងនេះពុំទាន់មានអ្វីមកបញ្ជាក់ផ្ទៀងផ្ទាត់ឱ្យត្រឹមត្រូវនៅឡើយនោះទេ។

ប៉ុន្តែ លោក ដារ៉ាមី មិនខ្វល់ពីគម្រោងអភិវឌ្ឍន៍នោះទេ

ដោយនិយាយថា លោកសប្បាយរីករាយចម្មតាះ ដីរបស់លោកនៅជុំវិញគម្រោងព្រលានយន្តហោះនោះ ដូច្នេះលោករំពឹងថាគម្រោងអភិវឌ្ឍន៍នេះនឹងបង្កើនតម្លៃដីរបស់លោក ទោះបីជាលោកមានតែប្លង់ទន់ក៏ដោយ។

នៅពេលពណ៌នាអំពីកិច្ចប្រជុំនោះ អ្នកនាងប៉ាញ់បានបញ្ជាក់ថាក្រុមមន្ត្រី ដែលនាងមិនស្គាល់ ប៉ុន្តែគាត់ទាយថាប្រហែលជាមកពីភ្នំពេញនោះ បាននិយាយថាអ្នកភូមិដែលមានដីនឹងទទួលបានប្រាក់ប្រហែល 1,000 ដុល្លារក្នុងមួយហិចតានៅពេលដែលផែនការអភិវឌ្ឍន៍ទទួលបានការអនុម័ត។ ទោះជាយ៉ាងណាក៏ដោយអ្នកនាងនៅពុំទាន់ទទួលបានសំណងណាមួយនោះឡើយ ហើយអ្នកនាងភ័យខ្លាចថា ប្លង់ទន់នោះនឹងមិនអាចធ្វើឱ្យអ្នកនាងមានសិទ្ធិទទួលបានសំណងទូទាត់នោះទេ។

អភិបាលស្រុកស្ទឹង លោក សៀក មុនី មានប្រសាសន៍ថា អាជ្ញាធរមូលដ្ឋាន កំពុងតែធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងទេសចរណ៍ ដើម្បីធ្វើការវាយតម្លៃលើដីធ្លីនិងការបោះបង្គោលព្រំសម្រាប់គម្រោងផែនការនេះ។ លោក មុនី បានថ្លែងថា គម្រោងសាងសង់ព្រលានយន្តហោះនេះ បានធ្វើការពិភាក្សាអស់រយៈពេលជិត 7 ឆ្នាំមកហើយ ដែលរហូតមកទល់នឹងពេលនេះ ក្រុមមន្ត្រីបានកត់ត្រាបណ្តឹងចំនួន 25 ពីក្រុមគ្រួសារដែលមានដីធ្លីនៅក្នុងទីតាំងគម្រោង ហើយក្នុងនោះ មានបណ្តឹងចំនួន 6 ដែលជាបណ្តឹងថ្មីទទួលបានក្រោយពេលមានកិច្ចប្រជុំរបស់ក្រុមការងារ។ លោកបាននិយាយថា បណ្តឹងទាំងនេះនឹងត្រូវដោះស្រាយក្រោយពេលមានការសិក្សាសមិទ្ធលទ្ធភាពរួចរាល់។

ក្រោយពេលមានសកម្មភាពតិចតួចក្នុងរយៈពេលជាច្រើនឆ្នាំទាក់ទងនឹងគម្រោងព្រលានយន្តហោះនេះ លោក ម៉េងលី របស់សមាគមសិទ្ធិមនុស្សអាដហុក បានកត់សម្គាល់ឃើញថា ល្បឿនរបស់គម្រោងអភិវឌ្ឍន៍នេះបានស្ទុះឡើង "យ៉ាងលឿន"។ លោកបានថ្លែងថា៖ " គម្រោងនេះនឹងចាប់ផ្តើមប៉ះពាល់ដល់ប្រជាជនក្នុងពេលឆាប់ៗនេះ "។

កាលពីខែមេសាកន្លងទៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអនុញ្ញាតឱ្យក្រសួងទេសចរណ៍ និងអាជ្ញាធរខេត្តមណ្ឌលគិរី ធ្វើការសិក្សាពីសមិទ្ធលទ្ធភាព ក្នុងការសាងសង់ព្រលានយន្តហោះមួយនៅក្នុងខេត្ត ដែលសម្បូរទៅដោយព្រៃឈើមួយនេះ ប៉ុន្តែមន្ត្រីនានានៅតែអាចជំទាស់គំនិតនេះបាន ប្រសិនបើពួកគេយល់ឃើញថាជារឿងមិនចាំបាច់ នេះបើយោងតាមការលើកឡើងរបស់លោក ជុក ជំនោរ មន្ត្រីអ្នកនាំពាក្យក្រសួងទេសចរណ៍។ លោកមិនបានបង្ហាញអំពីទំហំដីដែលបានស្នើឡើងនោះទេ ឬក្រុមហ៊ុនអភិវឌ្ឍន៍ព្រលានយន្តហោះនោះឡើយ ដោយនិយាយថា អ្វីៗនឹងកំណត់នៅក្រោយពេលបញ្ចប់ការសិក្សាសមិទ្ធលទ្ធភាពប៉ុន្តែលោកស៊ិនចាន់សេរីវុត្ថាដែលជាអ្នកនាំពាក្យលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល បាននិយាយថា ព្រលានយន្តហោះនេះនឹងគ្របដណ្តប់លើផ្ទៃដីទំហំ300 ហិចតា។

ព្រលានយន្តហោះទំហំ 300 ហិចតា គឺប្រហាក់ប្រហែលនឹងទំហំរបស់ព្រលានយន្តហោះបច្ចុប្បន្នក្នុងរាជធានីភ្នំពេញ និងខេត្តព្រះសីហនុដែរ ដែលនៅភ្នំពេញគ្របដណ្តប់លើផ្ទៃដីទំហំ 385 ហិចតា ហើយនៅខេត្តព្រះសីហនុមានទំហំ 400 ហិចតា។

" ដូច្នេះគម្រោងនេះនឹងចាប់ផ្តើមមានផលប៉ះពាល់លើប្រជាជនក្នុងពេលឆាប់ៗ"- លោក អ៊ាង ម៉េងលី សមាគមសិទ្ធិមនុស្សអាដហុកផែនការព្រលានយន្តហោះដ៏មហិមានេះ បានជួយដល់ការអភិវឌ្ឍវិស័យទេសចរណ៍ និងពង្រីកតម្រូវការដីធ្លី។ កាលពីដើមឆ្នាំនេះ ក្រុមហ៊ុនអាកាសយានដ្ឋានកម្ពុជា បានប្រកាសអំពីការពង្រីកព្រលានយន្តហោះរបស់ខ្លួននៅខេត្តព្រះសីហនុ ដោយចំណាយទឹកប្រាក់ចំនួន 21 លានដុល្លារដើម្បីបង្កើតផ្លូវយន្តហោះរត់ ដែលមានចម្ងាយវែងជាងគេបំផុតនៅក្នុងប្រទេសកម្ពុជា ដើម្បីឱ្យកម្ពុជាអាចមានសមត្ថភាពទទួលយន្តហោះមានតួខ្លួនធំ និងយន្តហោះហោះហើរចម្ងាយឆ្ងាយ។ ហើយកាលពីឆ្នាំកន្លងទៅលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានចុះកិច្ចព្រមព្រៀងជាមួយនឹងនាយករដ្ឋមន្ត្រីប្រទេសចិន លោក លី ខឺឈាំង ស្តីពីការសាងសង់ព្រលានយន្តហោះថ្មីដ៏ធំសម្បើមនៅក្រៅរាជធានីភ្នំពេញស្ថិតក្នុងខេត្តកណ្តាល ដែលមិនខ្វល់

ពីកិច្ចសន្យាប្រតិបត្តិការ ព្រលានយន្តហោះផ្តាច់មុខនៅក្នុងប្រទេសកម្ពុជា ជាមួយនឹងក្រុមហ៊ុន Vinci Group របស់បារាំងនោះឡើយ ។

អ្នកប្រកបរបរអាជីវកម្មនៅក្នុងខេត្តមណ្ឌលគិរី បានមើលឃើញថា ព្រលានយន្តហោះនោះនឹងមានគុណប្រយោជន៍ បើទោះបីជានៅពុំទាន់មានការសន្និដ្ឋានអំពីទំហំ ឬប្លង់របស់ព្រលានយន្តហោះនេះក៏ដោយ។

ជារួម វិស័យទេសចរណ៍នៅក្នុងខេត្តមណ្ឌលគិរី មានការកើនឡើង ដែលក្នុងនោះភ្ញៀវទេសចរណ៍ក្នុងស្រុក និងបរទេស បានកើនឡើងចំនួន 18% កាលពីឆ្នាំ 2018 បើធៀបនឹងឆ្នាំ 2017 នេះបើយោងតាមស្ថិតិ ដែលផ្តល់ជូនដោយសមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា។ ក្នុងឆ្នាំ 2019 នេះ មានភ្ញៀវទេសចរណ៍ជាតិចំនួនជាង 91,000 នាក់បានមកលេងខេត្តមណ្ឌលគិរី ទោះបីជាចំនួនភ្ញៀវទេសចរណ៍បរទេសមានចំនួនតិចជាងនេះខ្លាំង ត្រឹមតែ 8,024 នាក់ក៏ដោយ។

វិស័យទេសចរណ៍នៅក្នុងខេត្តមណ្ឌលគិរី មិនសូវជាធំដុំឡើយ បើធៀបជាមួយនឹងតំបន់ទេសចរណ៍ដ៏ពេញនិយមរបស់កម្ពុជាផ្សេងទៀត ដូចជា ខេត្តសៀមរាប និងក្រុងព្រះសីហនុ ប៉ុន្តែរដ្ឋាភិបាលកំពុងធ្វើការវិនិយោគ ទៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធដែលធ្វើឱ្យខេត្តភាគឥសាន្តមួយនេះ ក្លាយជាគោលដៅទេសចរណ៍ដែលមានភាពទាក់ទាញ។ កាលពីពេលថ្មីៗនេះ រដ្ឋាភិបាលបានបញ្ចេញទឹកប្រាក់ចំនួន 10 លានដុល្លារ សម្រាប់ការអភិវឌ្ឍសួនកម្សាន្តនៅក្នុងខេត្តមណ្ឌលគិរី ដែលនឹងមានបង្ហាញនូវធនធានធម្មជាតិរបស់ខេត្ត ក៏ដូចជាវប្បធម៌របស់ជនជាតិដើមផងដែរ។

ប្រធានសមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា លោកស្រី ឆាយ ស៊ីវលីន បានមានប្រសាសន៍ថាក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ ភ្ញៀវទេសចរណ៍ក្នុងស្រុកកាន់តែច្រើនឡើងៗ កំពុងតែសម្រុកទៅកម្សាន្តនៅខេត្តដែលមានពណ៌ខៀវស្រស់បំព្រងមួយនេះ ប៉ុន្តែភ្ញៀវទេសចរណ៍អន្តរជាតិនឹងត្រូវបានទាក់ទាញកាន់តែច្រើនឡើងប្រសិនបើមានព្រលានយន្តហោះ ។

លោកស្រី បានលើកឡើងនៅក្នុងអ៊ីមែលថា៖ "តាមរយៈព័ត៌មានដែលខ្ញុំបានប្រមូលពីភ្ញៀវទេសចរណ៍អន្តរជាតិតាមរយៈកិច្ចប្រជុំរបស់ខ្ញុំនៅឯក្រៅប្រទេស ពួកគេចាប់អារម្មណ៍ក្នុងការបន្តការធ្វើដំណើររបស់ខ្លួនទៅកាន់ភាគឥសាន្តប្រទេសកម្ពុជាផងដែរ"។ "ប៉ុន្តែការធ្វើដំណើរប្រើពេលច្រើនម៉ោង គឺជាឧបសគ្គដ៏ធំក្នុងការទទួលបានជោគជ័យលើការទាក់ទាញឱ្យពួកគេទៅលេងតំបន់ផ្នែកមួយនេះរបស់ប្រទេសកម្ពុជា"។

លោក ថន ភារកិច្ច ដែលជាមគ្គុទេសក៍ទេសចរណ៍របស់ក្រុមហ៊ុន Mondulkiri Eco Tours បានថ្លែងថា ការកែលម្អផ្លូវជាតិលេខ 76 ដែលឆ្លងកាត់ខេត្តមណ្ឌលគិរី និងរតនគិរី បានបង្កើនកំណើនវិស័យទេសចរណ៍យ៉ាងខ្លាំងចាប់ទាំងពីឆ្នាំ2008 មក។ ដូច្នេះលោកគិតថា ទោះបីជាព្រលានយន្តហោះត្រូវជម្លៀសប្រជាជនមួយចំនួនចេញក្តី ប៉ុន្តែគម្រោងនេះគឺជាពរជ័យសម្រាប់ខេត្តទាំងមូលផងដែរ។

លោក ភារកិច្ច និយាយថា៖ "ព្រលានយន្តហោះមួយអាចនឹងប៉ះពាល់ដល់ដីធ្លីមួយកន្លែង ប៉ុន្តែមិនមែនទាំងអស់នោះទេ។ មែនហើយយើងមានដីធ្លី និងព្រៃឈើដ៏ធំនៅក្នុងខេត្តមណ្ឌលគិរីនេះ ដូច្នេះ ការអភិវឌ្ឍនឹងនាំមកនូវភ្ញៀវទេសចរណ៍កាន់តែច្រើន ហើយក៏នឹងបង្កើតការងារកាន់តែសម្បូរសម្រាប់ប្រជាជនក្នុងមូលដ្ឋានផងដែរ"។

ភ្ញៀវទេសចរណ៍កម្រិតអ្នកមានកំពូលមួយចំនួន អាចធ្វើដំណើរមកទស្សនាខេត្តមណ្ឌលគិរីតាមរយៈការជិះឧទ្ធម្ភាគចក្រ ប៉ុន្តែអ្នកស្រី Corinne Darquey នាយកគ្រប់គ្រង សណ្ឋាគារ Mayura Hill ដ៏ប្រណីត បានមានប្រសាសន៍ថា ក្នុងរយៈពេលពីរឆ្នាំដែលអ្នកស្រីមកធ្វើការនៅសណ្ឋាគារនេះ អ្នកស្រីឃើញមានតែភ្ញៀវទេសចរណ៍ចំនួនពីរនាក់ប៉ុណ្ណោះ ដែលធ្វើដំណើរតាមឧទ្ធម្ភាគចក្រមកកាន់ខេត្តនេះ។

ផ្ទុយមកវិញ អ្នកស្រីសម្តែងនូវក្តីបារម្ភថាការហូរចូលច្រើននូវភ្ញៀវទេសចរណ៍ អាចនឹងធ្វើឱ្យខូចដល់សម្រស់ធម្មជាតិរបស់ខេត្តមណ្ឌលគិរីនេះ ដោយអ្នកស្រីលើកឡើងថាការអភិវឌ្ឍយ៉ាងគំហុក

នៅខេត្តព្រះសីហនុឱ្យទៅជាមជ្ឈមណ្ឌលទេសចរណ៍ល្បែងស៊ីសងគឺជាឧទាហរណ៍។

អ្នកស្រីបានថ្លែងថា៖" កាលណាមានមនុស្សច្រើនមកកាន់ទីនោះ នោះធម្មជាតិក៏នឹងបាត់បង់កាន់តែលឿនដូច្នោះដែរ"។ "ខ្ញុំសង្ឃឹមថា ខ្ញុំនិយាយខុសទៅចុះ"។

ប្រជាជន ដែលនឹងទទួលរងផលប៉ះពាល់ខ្លាំងជាងគេបំផុតដោយសារគម្រោងអភិវឌ្ឍន៍ព្រលានយន្តហោះនេះ គឺប្រជាជនដែលរស់នៅជិតទីតាំងព្រលានយន្តហោះ។ កសិករម្នាក់អាយុ 29 ឆ្នាំដែលបាននិយាយដោយក្ដីបារម្ភចំពោះគម្រោងនោះ បានថ្លែងថាការប្រកបរបរចិញ្ចឹមជីវិតរបស់គាត់ ក៏ដូចជាអ្នកភូមិជាច្រើនទៀតនឹងត្រូវបំផ្លាញប្រសិនបើព្រលានយន្តហោះនេះនៅតែបន្តសាងសង់នៅត្រង់ចំណុចទីតាំងដែលបានស្នើឡើងនោះ។ ការដាំដំណាំនិងការចិញ្ចឹមគោ គឺជាប្រភពចំណូលតែមួយគត់របស់គាត់ ហើយគាត់មានការខ្វាយខ្វល់យ៉ាងខ្លាំងជុំវិញការបាត់បង់មុខរបរចិញ្ចឹមជីវិត ដែលមានភាពមិនទៀងទាត់បាត់ទៅហើយនៅពេលនេះ។

អ្នកស្រីនិយាយថា៖ "យើងមានក្ដីបារម្ភយ៉ាងខ្លាំងអំពីរឿងនេះ"។ គម្រោងអភិវឌ្ឍន៍ព្រលានយន្តហោះ ដែលប៉ះចំលើដីរបស់គាត់ និងតំបន់បញ្ចុះសពដូនតា "គឺប្រៀបបាននឹងការកាត់ផ្ដាច់ដង្ហើមចុងក្រោយរបស់ពួកយើងដូច្នោះដែរ"។

Published with the support of Rosa-Luxemburg-Stiftung Southeast Asia with financial means of the Federal Ministry of Economic Cooperation and Development.

Not for sale

Rosa-Luxemburg-Stiftung Southeast Asia72 Xuan Dieu, Tay Ho, Hanoi, Vietnamwww.rls-sea.deHanoi, June 2019

Disclaimer

The opinions expressed in the publication are those of the authors and do not necessarily reflect the views of the Rosa-Luxemburg-Stiftung Southeast Asia (RLS SEA)

FOR MORE INFORMATION:
House No. 14A, St. 392, Sangkat Beoung Keng Kang I,
Khan Chamkarmon, Phnom Penh, Kingdom of Cambodia
www.ccimcambodia.org
communications@ccimcambodia.org
+855 (0)23 726 842







CCiM
cambodian center for independent media

ROSA LUXEMBURG STIFTUNG SOUTHEAST ASIA